សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
UNIVERSITÉ ROYALE DE DROIT ET DES SCIENCES ÉCONOMIQUES
ROYAL UNIVERSITY OF LAW AND ECONOMICS

## សារណាបញ្ចប់ការសិក្សា

# ការស៊ើបអង្កេតរឿងក្តីព្រហ្មទណ្ឌក្នុងដំណាក់កាលនគរបាលយុត្តិធម៌

ស្រាវជ្រាវចាប់ពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១ ដល់ថ្ងៃទី២៥ មិថុនា ឆ្នាំ២០២១

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ ៖ កញ្ញា **ហ៊ុំ ចណ្ឌារី**

កញ្ញា **ឆូសោភា អេលីនតា**

សាស្ត្រាចារ្យណែនាំ

លោក **ជួន ម៉ុនធី**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២៦ (អាហារូបករណ៍)

ឆ្នាំចូលសិក្សា ២០១៧

ឆ្នាំសរសេរសារណា ២០២១

# សេចក្តីថ្លែងអំណរគុណ

ជាដំបូងនាងខ្ញុំឈ្មោះ **ធូសោភា អេលីនតា** និង **ហ៊ុំ ចណ្ណារី** ជានិស្សិតថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រឆ្នាំទី ៤ ជំនាន់ ២១ ក្នុងឆ្នាំសិក្សា ២០១៧-២០២១ សូមសម្តែងនូវកតញ្ញូ និងដឹងគុណដ៏ជ្រាលជ្រៅមិនអាចកាត់ថ្លៃបានដល់លោកអ្នកមានគុណទាំងបួនរួមមាន លោកឪពុក **ខាន់ ចាន់ធូ** និងអ្នកម្តាយ **ជួប សោភា** និងលោកឪពុក **ចន សុផាត** និងអ្នកម្តាយ **ផុន សុភាព** ដែលបានផ្តល់នូវកំណើតដល់រូបយើងខ្ញុំ និងចិញ្ចឹមបីបាច់ថែរក្សា ព្រមទាំងបានផ្តល់នូវការស្នាក់នៅ និងផ្គត់ផ្គង់ការរៀនសូត្ររបស់កូនតាំងពីថ្នាក់មត្តេយ្យរហូតមកដល់កម្រិតថ្នាក់បរិញ្ញាបត្រ ដោយលោកទាំងទ្វេរតែងតែបានលើកទឹកចិត្តនិងជម្រុញកូនក្នុងការរៀនសូត្រ ក៏ដូចជាបានការអប់រំ ទូន្មានប្រៀនប្រដៅកូនឱ្យប្រព្រឹត្តតែអំពើល្អ និងចេះផ្តល់នូវព្រហ្មវិហារធម៌ចំពោះអ្នកដទៃ។ សេចក្តីដឹងគុណសំរាប់លោកទាំងសងខាងទាំងអស់នេះ ពិតជាធំធេងពុំអាចកាត់ថ្លៃបានឡើយសម្រាប់ជីវិតពួកកូនៗទាំងពីរ។

ទន្ទឹមនឹងនេះផងដែរយើងខ្ញុំទាំងពីរ ក៏សូមថ្លែងអំណរគុណដល់ **ក្រសួងអប់រំ យុវជននិងកីឡា** ដែលបានផ្តល់អាហារូបករណ៍សំរាប់ការសិក្សារយៈពេល ០៤ឆ្នាំ ដល់រូបយើងខ្ញុំទាំងពីរនាក់ រួមទាំងសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានផ្តល់នូវកន្លែងបណ្តុះបណ្តាលចំណេះដឹងសមត្ថភាព ក៏ដូចជាការស្រាវជ្រាវក្នុងផ្នែកនីតិសាស្ត្រ នេះតាំងពីឆ្នាំទីមួយរហូតមកដល់ការបញ្ចប់ថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រ ប្រកបដោយភាជោគជ័យ ទទួលបាននូវផ្លែផ្កា និងសមិទ្ធផលចំណេះដឹងយ៉ាងគាប់ប្រសើរ ។

ក្នុងឱកាសនេះផងដែរ យើងខ្ញុំទាំងពីរនាក់ សូមលំឱនកាយសម្តែងនូវគោរវកិច្ចដឹងគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ **ថ្នាក់ដឹកនាំប្រទេសកម្ពុជា ដែលលោកបានខិតខំដឹកនាំប្រទេស** ប្រកបដោយសុខសន្តិភាពហើយព្រមទាំងជួយលើកស្ទួយវិស័យអប់រំឱ្យមានភាពល្អប្រសើរ ប្រសិនបើប្រទេសជាតិគ្មានសន្តិភាពទេ យើងខ្ញុំទាំងពីរនាក់ក៏មិនមានឱកាសបានសិក្សាមកដល់សព្វថ្ងៃនេះដែរ។ ម្យ៉ាងវិញទៀត យើងខ្ញុំសូមធ្វើការថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ **ឯកឧត្តមសាកលវិទ្យាធិការ និងលោកគ្រូ អ្នកគ្រូសាស្ត្រាចារ្យ** ទាំងអស់ ដែលលោកបានខិតខំបង្ហាត់បង្រៀន ដល់យើងខ្ញុំទាំងពីរនាក់ក៏ដូចជាសិស្សនិស្សិតគ្រប់ៗគ្នាអស់ពីកម្លាំងកាយកម្លាំងចិត្ត ព្រមទាំងអប់រំទូន្មាន ប្រៀនប្រដៅ ដល់រូបយើងខ្ញុំឱ្យក្លាយខ្លួនទៅជាពលរដ្ឋល្អនៅក្នុងសង្គម។ ជាពិសេសទៅទៀតនោះគឺ យើងខ្ញុំទាំងពីរនាក់ សូមគោរព និងថ្លែងអំណរគុណដ៏ជ្រាលជ្រៅបំផុតចំពោះលោកគ្រូសាស្ត្រាចារ្យ **ជួន ម៉ុនធី** ដែលលោកគ្រូបានលះបង់កម្លាំងកាយ និងកម្លាំងចិត្ត ព្រមទាំងពេលវេលាដ៏មានតម្លៃរបស់លោកគ្រូ ក្នុងការណែនាំបង្ហាត់បង្រៀនផ្តល់ដំបូន្មានល្អៗ និងការបំភ្លឺមាគ៌ា

សម្រាប់យើងខ្ញុំទាំងពីរក្នុងការស្រាវជ្រាវសារណាប្រធានបទមួយនេះ។ យើងខ្ញុំទាំងពីរនាក់ ពិតជាសូមគោរពនូវទឹកចិត្តសន្ដោសប្រណីរបស់លោកគ្រូយ៉ាងក្រៃលែង ចំពោះការលះបង់របស់លោកគ្រូសម្រាប់និស្សិតគ្រប់ៗគ្នា ។

ជាទីបញ្ចប់នេះ យើងខ្ញុំសូមប្រសិទ្ធពរជ័យជូនដល់ លោកអ្នកមានគុណ ឯកឧត្តម លោកជំទាវ លោកលោកស្រី និងលោកគ្រូ អ្នកគ្រូសាស្ត្រាចារ្យទាំងអស់ សូមឱ្យបានសមប្រកបតែជោគជ័យគ្រប់ភារកិច្ច និងសូមទទួលបាននៅពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាត់ឡើយ។

# អារម្ភកថា

សារណាមួយនេះ គឺជាជំនួយទៅដល់អ្នកដែលមានបំណងចង់សិក្សាអំពីវិស័យនីតិសាស្ត្រជាពិសេសនោះ គឺការស៊ើបអង្កេតនៅក្នុងដំណាក់កាលទីមួយ ដែលអាចហៅបានថាការស៊ើបអង្កេតក្នុងដំណាក់កាលមន្ត្រីនគរយុត្តិធម៌ និងនិស្សិតដែលកំពុងសិក្សាផ្នែកនីតិសាស្ត្រផ្ទាល់តែម្តង ។ ក្រុមយើងខ្ញុំបានសង្ឃឹមយ៉ាងមុតមាំថាស្នាដៃនេះនឹងអាចចូលរួមចំណែកមួយចំនួន ក្នុងការពង្រឹងនីតិរដ្ឋក្នុងប្រទេសជាតិ ក៏ដូចជាលើកស្ទួយវិស័យយុត្តិធម៌តាមរយៈខ្លឹមសារនៃការបកស្រាយនៅក្នុងសារណាមួយនេះដែលបង្ហាញជូនជនរួមជាតិ និងសាធារណៈជន នូវមតិទូទៅនឹងគោលបំណងឧត្តមគតិ និងការប្តេជ្ញាចិត្តរបស់នគរបាលយុត្តិធម៌ ក្នុងការពុះពារបម្រើជាតិ និងប្រជាជនគ្រប់កាលៈទេសៈ ព្រមទាំងបង្ហាញឱ្យបានច្បាស់អំពីចក្ខុវិស័យពាក់ព័ន្ធនឹងយុត្តិធម៌ដើម្បីបន្តស្តារ និងការពារមាតុភូមិឱ្យបានរុងរឿង នៃជាតិយើងឲ្យឆ្ពោះទៅរកអនាគតមួយយ៉ាងត្រចះត្រចង់ស្របតាមឆន្ទៈ និងបំណងប្រាថ្នារបស់ប្រជាពលរដ្ឋខ្មែរគ្រប់រូបដែលចង់បាននូវភាពយុត្តិធម៌ ។

គោលបំណងក្នុងការស្រាវជ្រាវរបស់ក្រុមយើងខ្ញុំ គឺចង់ឲ្យមានការរីកចម្រើននៅក្នុងវិស័យច្បាប់ទាក់ទងនឹងផ្នែកព្រហ្មទណ្ឌទាំងមូល រួមទាំងក្នុងដំណាក់កាលនៃការស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌ ពីព្រោះនៅក្នុងដំណាក់កាលមួយនេះ គឺត្រូវពឹងផ្អែកទាំងស្រុងទៅលើសមត្ថភាពនិងបច្ចេកទេស ឬជំនាញរបស់មន្ត្រីនគរបាលយុត្តិធម៌ ដើម្បីបង្ការ និងបង្ក្រាបបទល្មើសដែលបានកើតមានឡើងនានា ក្នុងការរក្សាសណ្តាប់ធ្នាប់សាធារណៈ ព្រមទាំងការពារសង្គមកុំឱ្យមានភាពរីករដើម្បើជៀសវាងកុំឱ្យមានភាពអសកម្មនៅក្នុងសង្គមជាតិ។ ក្នុងការសិក្សាស្រាវជ្រាវនេះ ក្រុមយើងខ្ញុំបានព្យាយាមស្រាវជ្រាវ ដោយយកចិត្តទុកដាក់ជាអតិបរមាដើម្បីធ្វើឱ្យសារណានេះ ទុកជាផលប្រយោជន៍ក្នុងការសិក្សាស្រាវជ្រាវដល់សាធារណៈជនគ្រប់រូប ក៏ដូចជាមន្ត្រីនគរបាលយុត្តិធម៌ ដែលទទួលបាននូវនីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ ឬជាភ្នាក់ងារនគរបាលយុត្តិធម៌ មន្ត្រីរាជការភ្នាក់ងារសាធារណៈដទៃទៀតដែលមាននីតិសម្បទា ជាពិសេសក្នុងការស៊ើបអង្កេតស្វែងរកបទល្មើសព្រហ្មទណ្ឌរួមទាំងសំរាប់និស្សិតជំនាន់ក្រោយ ដែលមានបំណងស្វែងយល់ទាក់ទងទៅនឹងប្រធានបទសារណាមួយនេះ ។

ដោយសារណានេះជាស្នាដៃដំបូងរបស់នាងខ្ញុំទាំងពីរនាក់ ហេតុនេះ យើងខ្ញុំសូមខន្តីអភ័យទោសចំពោះចំណុចខ្វះខាត ឬបង្កើតនូវចន្លោះប្រហោងត្រង់ចំណុចណាមួយជាយថាហេតុ។ យើងខ្ញុំទាំងពីរនាក់ ព្រមទទួលដោយក្តីសោមនស្សនូវការរិះគន់ដើម្បីកែលម្អ ក្នុងន័យស្ថាបនាចំពោះស្នាដៃនេះគ្រប់ពេលវេលា ឆ្លៀតក្នុងឱកាសនេះយើងខ្ញុំសូមសម្តែងនូវសេចក្តីគោរព និងដឹងគុណយ៉ាងជ្រាលជ្រៅចំពោះជនរួមជាតិនៅគ្រប់ទិសទី ដែលបានផ្តល់ជំនឿ និងការគាំទ្រយ៉ាងធំធេងចំពោះស្នាដៃនេះ ។

# មាតិកា


ទំព័រ

សេចក្តីផ្តើម ........................................................................................................ ១

## ជំពូកទី ១

## គោលការណ៍នៃការស៊ើបអង្កេតក្នុងរឿងព្រហ្មទណ្ឌ

ផ្នែកទី១ សញ្ញាណទូទៅនៃការស៊ើបអង្កេត ..................................................................៣

កថាខណ្ឌទី១ គោលបំណងនៃការស៊ើបអង្កេត ..........................................................៣

១.១ មូលដ្ឋានស្របច្បាប់នៃការស៊ើបអង្កេត ..........................................................៤

១.២ សមាសភាពអ្នកស៊ើបអង្កេត ..........................................................................៦

១.២.១ សមាសភាពនគរបាលយុត្តិធម៌ ..........................................................៧

១.២.១.១ មន្ត្រីនគរបាលយុត្តិធម៌ ....................................................................៧

ក. សមត្ថកិច្ចដែនដីរបស់មន្ត្រីនគរបាលយុត្តិធម៌ ..............................................៩

១.២.១.២ ភ្នាក់ងារនគរបាលយុត្តិធម៌ ..............................................................១០

១.២.១.៣ មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀត ......................................១០

១.៣ តួនាទី និងភារកិច្ចរបស់នគរបាលយុត្តិធម៌ ....................................................១១

១.៣.១ ការពិនិត្យស្វែងរកបទល្មើស ...........................................................១២

១.៣.២ ការស៊ើបអង្កេតស្វែងរកភស្តុតាង ......................................................១២

ផ្នែកទី២ សញ្ញាណទូទៅនៃភស្តុតាង ......................................................................១២

កថាខណ្ឌ១ និយមន័យនៃភស្តុតាង ..........................................................................១២

១.១ កម្មវត្ថុនៃការស្វែងរកភស្តុតាង .......................................................................១៣

កថាខណ្ឌ២ ចំណាត់ថ្នាក់ភស្តុតាង ..........................................................................១៤

២.១ ប្រភេទវត្ថុ សំណល់ សរីរៈ ..............................................................................១៤

២.២ ប្រភេទសក្ខីកម្ម ..........................................................................................១៥

២.២.១ ការបំភ្លឺរបស់សាក្សី ..........................................................................១៥

២.២.២ ការបំភ្លឺរបស់ជនរងគ្រោះ ....................................................................១៥

២.៣ ប្រភេទឯកសារ ............................................................................................១៥

២.៣.១ កំណត់ហេតុអង្កេត ..........................................................................១៥

២.៣.២ ឯកសារសំណេរនានា ........................................................................................................ ១៦

២.៤ សេចក្តីពន្យល់របស់ជនជាប់ចោទ .................................................................................... ១៦

# ជំពូកទី ២

# នីតិវិធីនៃការស៊ើបអង្កេតក្នុងរឿងព្រហ្មទណ្ឌ

**ផ្នែកទី១៖ ការស៊ើបអង្កេតដោយមន្ត្រីនគរបាលយុត្តិធម៌** ................................................ ១៧

**កថាខណ្ឌ១៖ ការស៊ើបអង្កេតបទល្មើសជាក់ស្តែងដោយមន្ត្រីនគរបាលយុត្តិធម៌** ............. ១៧

**១.១ លក្ខខណ្ឌករណីបទល្មើសជាក់ស្តែង** ..................................................................... ១៧

១.១.១ ការកំណត់ពីបទល្មើសជាក់ស្តែង ...................................................................... ១៨

១.១.២ បទល្មើសកំពុងប្រព្រឹត្ត ..................................................................................... ២០

១.១.៣ បទល្មើសកំពុងប្រព្រឹត្តរួចភ្លាម ........................................................................... ២០

១.១.៤ ការបន្សល់ទុកនូវតម្រុយលើជនសង្ស័យ ................................................................ ២០

១.១.៥ ជនសង្ស័យត្រូវបានសាធារណៈជនស្រែកប្រដាប់ចាប់ប្រកីង
ក្រោយពេលប្រព្រឹត្តបទល្មើសរួចបន្តិច ............................................................... ២១

១.១.៦ ការចាត់ទុកជាបទល្មើសជាក់ស្តែង ...................................................................... ២២

**១.២ វិធានពាក់ព័ន្ធនឹងទីកន្លែងកើតហេតុ** ...................................................................... ២២

១.២.១ ការចុះទៅទីកន្លែងកើតហេតុ ............................................................................. ២២

១.២.២ ការធ្វើកំណត់ហេតុរបស់មន្ត្រីនគរបាលយុត្តិធម៌ ................................................... ២៣

**កថាខណ្ឌ២៖ ការស៊ើបអង្កេតបឋម ដោយមន្ត្រីនគរបាលយុត្តិធម៌** ................................. ២៣

**២.១ បុព្វហេតុនៃការស៊ើបអង្កេត** .................................................................................. ២៤

**២.២ វិធានអនុវត្តចំពោះការស៊ើបអង្កេតបឋម** .................................................................. ២៤

**កថាខណ្ឌ៣៖ ដីកាចាត់ឲ្យស៊ើបសួរជំនួស** ..................................................................... ២៤

**៣.១ អត្ថន័យដីកាចាត់ឲ្យស៊ើបសួរជំនួស** ........................................................................ ២៥

**៣.២ ដីកាចាត់ឲ្យស៊ើបសួរចេញឲ្យមន្ត្រីនគរបាលយុត្តិធម៌** ................................................... ២៥

**ផ្នែកទី២៖ វិធានស្រាវជ្រាវក្នុងករណីបទល្មើសជាក់ស្តែង និងការស៊ើបអង្កេតបឋម** .. ២៦

**កថាខណ្ឌ១៖ ការឆែកឆេរ** ........................................................................................... ២៦

**១.១ ករណីបទល្មើសជាក់ស្តែង** ....................................................................................... ២៦

**១.២ ករណីបទល្មើសមិនជាក់ស្តែង** .................................................................................. ២៨

**កថាខណ្ឌ២៖ ការឃាត់ខ្លួន** ....................................................................................... ២៨
**២.១ រយៈពេលនៃការឃាត់ខ្លួន** ................................................................................ ២៩
២.១.១ នីតិជន ...................................................................................................... ២៩
២.១.២ អនីតិជន .................................................................................................... ៣០
**២.២ បែបបទនៃការឃាត់ខ្លួន** .................................................................................. ៣១
២.២.១ សិទ្ធិជួបប្រាស្រ័យមេធាវីក្នុងពេលឃាត់ខ្លួន ............................................................ ៣២
២.២.២ សិទ្ធិជំនួយគ្រូពេទ្យនៅពេលឃាត់ខ្លួន ...................................................................... ៣២
២.២.៣ ការជូនដំណឹងអំពីការឃាត់ខ្លួន ............................................................................ ៣៣
២.២.៤ បញ្ជីឃាត់ខ្លួន ................................................................................................. ៣៣
២.២.៥ កំណត់ហេតុសរុបនៃការឃាត់ខ្លួន ......................................................................... ៣៣
**កថាខណ្ឌ៣៖ ការបញ្ជូនខ្លួនជនសង្ស័យ** ........................................................................ ៣៤
**៣.១ រយៈពេលនៃការឃាត់ខ្លួន** ................................................................................ ៣៤
**កថាខណ្ឌ៤៖ ទណ្ឌកម្មចំពោះកិច្ចមិនគោរពវិធាន** ........................................................... ៣៥
**សេចក្ដីសន្និដ្ឋាន** .................................................................................................. ៣៧
**អនុសាសន៍** ......................................................................................................... ៣៨
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

គ្រប់អំពើដែលល្មើសនឹងច្បាប់ព្រហ្មទណ្ឌ គឺជាបទល្មើស ម្យ៉ាងវិញទៀតបទល្មើសព្រហ្មទណ្ឌជាអំពើទាំងឡាយណាដែលបង្កគ្រោះថ្នាក់ដល់សង្គមជាតិ ហើយអំពើទាំងនោះគឺជាការបំពានទៅនឹងច្បាប់ព្រហ្មទណ្ឌ។ បទសល្មើសមានការកើនឡើង ឬថយចុះវាអាស្រ័យទៅនឹងជំនាញ ឬសមត្ថភាពរបស់មន្ត្រីនគរបាលយុត្តិធម៌ថា តើការបង្ក្រាបបទល្មើសដែលបានកើតឡើងអាស្រ័យទៅនឹងជំនាញ ឬសមត្ថភាពរបស់មន្ត្រីនគរបាលយុត្តិធម៌ស្របតាមវិជ្ជាជីវៈដែរឬទេ? ហើយវាស្របទៅនឹងអ្វីដែលមានចែងនៅក្នុងច្បាប់ដែរឬទេ? ជាក់ស្តែង ក្នុងការស្វែងរកប្រមូលនូវភស្តុតាង ការសាកសួរ ការឃាត់ខ្លួន ការចាប់ខ្លួន ការបញ្ជូនខ្លួន គឺជាបច្ចេកទេសរបស់មន្ត្រីនគរបាលយុត្តិធម៌ ដែលមានតួនាទីសម្រាប់ធ្វើការស៊ើបអង្កេត និងស្វែងរកបទល្មើសព្រមទាំងបង្ការ និងបង្ក្រាបបទល្មើសនៅក្នុងសង្គមជាតិ។ ម្យ៉ាងវិញទៀត យុត្តិសាស្ត្រ ឬ បច្ចេកទេសរបស់មន្ត្រីនគរបាលនេះ គឺជាមូលដ្ឋានសម្រាប់ធ្វើការស្វែងរកនូវភាពយុត្តិធម៌ជូនសង្គមជាតិ ព្រមទាំងជនរងគ្រោះឱ្យទទួលបាននូវសមភាពយុត្តិធម៌ចំពោះអំពើដែលពួកគេបានទទួលរង។

ដើម្បីឱ្យការស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌ទទួលបានភាពជោគជ័យនោះ ត្រូវមានដំណោះស្រាយមួយចំនួនហើយដំណោះស្រាយនោះ គឺមានការពាក់ព័ន្ធទៅនឹងសិទ្ធិនិងកាតព្វកិច្ចរបស់មន្ត្រីនគរបាលយុត្តិធម៌ព្រមទាំងសិទ្ធិ និងកាតព្វកិច្ចរបស់ជនសង្ស័យ សាក្សីឬក៏ជនរងគ្រោះ ។

នៅក្នុងប្រធានបទមួយនេះ គឺមានវិសាលភាពគ្របដណ្តប់ទៅលើបទល្មើសព្រហ្មទណ្ឌទាំងឡាយណាដែលបានកើតឡើង រហូតដល់ដំណាក់កាលស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌ និងស្ថាប័ននគរបាលយុត្តិធម៌ ដែលមានចែងយ៉ាងច្បាស់លាស់នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧។ និយាយជារួមវាមានវិសាលភាពគ្របដណ្តប់ទូទាំងព្រះរាជាណាចក្រកម្ពុជា ចាប់តាំងពីឆ្នាំ២០០៧ នៅពេលដែលក្រមនីតិព្រហ្មទណ្ឌបានចូលជាធរមានរហូតមកដល់បច្ចុប្បន្ននេះ។ ការស្រាវជ្រាវលើប្រធានបទមួយនេះ គឺមានអត្ថប្រយោជន៍សម្រាប់ពលរដ្ឋ និងមិត្តនិស្សិតទាំងអស់ដែលមានបំណងចង់ធ្វើការស្វែងយល់នូវចំណេះដឹងទូទៅ នៃការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌក្នុងដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ ជាពិសេសនោះគឺសម្រាប់អ្នកធ្វើការស្រាវជ្រាវ និងសម្រាប់អ្នកសិក្សាផ្នែកនីតិសាស្ត្រផងដែរ។ គួរបញ្ជាក់ផងដែរថា សារណារបស់ក្រុមយើងនាងខ្ញុំនេះលើកយកតែនៅក្នុងដំណាក់កាល នៃការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌក្នុងដំណាក់មន្ត្រីនគរបាលយុត្តិធម៌តែប៉ុណ្ណោះ។ អាស្រ័យហេតុនេះហើយ ទើបក្រុមរបស់នាងខ្ញុំបានខិតខំព្យាយាមពន្យល់លម្អិតអំពីការស៊ើបអង្កេតរឿងព្រហ្មទណ្ឌក្នុងដំណាក់កាលទីមួយននេះ ឬក៏អាចហៅបានថាដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌។ ជាក់ស្តែងតាមរយៈសារណាស្រាវជ្រាវមួយនេះ ក្រុមនាងខ្ញុំបានបែងចែកជា ០២ ជំពូក ដែលនៅក្នុង **ជំពូកទី១** ផ្តោតសំខាន់ទៅ

លើ "**គោលការណ៍នៃការស៊ើបអង្កេតក្នុងរឿងក្តីព្រហ្មទណ្ឌ**" ព្រមទាំងបានបែងចែកជាពីរផ្នែកធំៗ ដែលរួមមាន៖

**ផ្នែក១៖** សញ្ញាណទូទៅនៃការស៊ើបអង្កេត

**ផ្នែក២៖** សញ្ញាណទូទៅនៃភស្តុតាង ។

ហើយចំពោះ**ជំពូកទី២** វិញក្រុមយើងខ្ញុំនឹងធ្វើការបកស្រាយអំពី "**នីតិវិធីក្នុងការស៊ើបអង្កេតក្នុងរឿងក្តីព្រហ្មទណ្ឌ**" ដែលមានបែងចែកជា ពីរផ្នែកធំៗ រួមមាន៖

**ផ្នែក១៖** ការស៊ើបអង្កេតដោយមន្ត្រីនគរបាលយុត្តិធម៌

**ផ្នែក២៖** វិធានស្រាវជ្រាវក្នុងករណីបទល្មើសជាក់ស្តែង និងការស៊ើបអង្កេតបឋម ។

# ជំពូកទី ១
# គោលការណ៍នៃការស៊ើបអង្កេត
# ក្នុងរឿងក្តីព្រហ្មទណ្ឌ

# ជំពូកទី ១

# គោលការណ៍នៃការស៊ើបអង្កេតក្នុងរឿងព្រហ្មទណ្ឌ

## ផ្នែកទី១ សញ្ញាណទូទៅនៃការស៊ើបអង្កេត

ក្រមនីតិវិធីព្រហ្មទណ្ឌ មានគោលដៅសម្រេចឲ្យបាននូវគោលបំណងច្បាប់ព្រហ្មទណ្ឌ ហើយនីតិវិធីព្រហ្មទណ្ឌបានកំណត់វិធានដែលត្រូវគោរព និងប្រតិបត្តិតាមយ៉ាងម៉ឺងម៉ាត់ដើម្បីកំណត់ឲ្យច្បាស់នូវអត្ថិភាពនៃបទល្មើសព្រហ្មទណ្ឌ ។[1] ដោយឡែក ក្នុងការយកបុគ្គលណាម្នាក់ទៅដាក់ទណ្ឌកម្មត្រូវតែ គោរពតាមគន្លងនៃវិធានដែលមានបញ្ញត្តិក្នុងក្រមនីតិវិធីព្រហ្មទណ្ឌជាចាំបាច់ ពុំដូច្នេះទេកិច្ចនីតិវិធីនឹងត្រូវមោឃភាពដោយសភាស៊ើបសួរ ជាក់ស្តែងដូចជាដំណើរការស៊ើបអង្កេតរឿងក្តីព្រហ្មទណ្ឌព្រះរាជអាជ្ញា ឬមន្ត្រីនគរបាលយុត្តិធម៌ ត្រូវបំពេញបេសកកម្មរបស់ខ្លួនដែលដាច់ខាតត្រូវតែគោរពតាមបទប្បញ្ញត្តិដែលមានចែងជាក់ស្តែងដូចនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឱ្យបានហ្មត់ចត់ ក្នុងគោលបំណងរក្សាឱ្យបាននូវផលប្រយោជន៍រួមជាធំដោយមិនគិតតែប្រយោជន៍បុគ្គល។ ជាក់ស្តែង ក្នុងដំណើរការស៊ើបអង្កេតរឿងក្តីព្រហ្មទណ្ឌក្នុងដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ ការស៊ើបអង្កេត គឺជាផ្នែកមួយនៃដំណាក់កាលនីតិវិធីព្រហ្មទណ្ឌ ដោយឡែកនៅក្នុងដំណើរការព្រហ្មទណ្ឌចាំបាច់ត្រូវតែធ្វើនិងជាមធ្យោបាយត្រឹមត្រូវមិនថាឡើយតែមានអនុវត្តក្នុងប្រព័ន្ធច្បាប់ Civil Law ឬ នៅក្នុងប្រព័ន្ធច្បាប់ Common Law ក៏ដូចគ្នា គឺតុលាការព្រហ្មទណ្ឌមានយុត្តាធិការជំនុំជម្រះបុគ្គលមួយក្នុងរឿងក្តីព្រហ្មទណ្ឌ លុះត្រាតែមានការស៊ើបអង្កេតរកឃើញថាមានកំហុសក្នុងបទល្មើសព្រហ្មទណ្ឌ និងមានសេចក្តីសម្រេចចោទប្រកាន់។ ការស៊ើបអង្កេត គឺជាការស្វែងរកពត៌មានដែលត្រឹមត្រូវ ដើម្បីកំណត់ការពិតដែលនៅក្នុងនោះភស្តុតាង គឺដើរតួយ៉ាងសំខាន់នោះក្នុងទិដ្ឋភាពនៃការស៊ើបអង្កេត។ ការស៊ើបអង្កេតទាមទារឲ្យធ្វើដោយហ្មត់ចត់គោរពឲ្យបានត្រឹមត្រូវតាមវិធានច្បាប់ដែលតម្រូវឲ្យធ្វើការស្រាវជ្រាវរហូតទាល់តែរកឃើញចម្លើយថា មានរឿងអ្វីកើតឡើង? នរណាជាអ្នកទទួលខុសត្រូវ?

### កថាខណ្ឌ១ គោលបំណងនៃការស៊ើបអង្កេត

ការស៊ើបអង្កេត គឺជាកិច្ចនីតិវិធីមួយដែលជាដំណាក់កាលត្រៀមនៃរឿងក្តីព្រហ្មទណ្ឌ ចំពោះកិច្ចនីតិវិធីនេះត្រូវបានប្រព្រឹត្តទៅមុនពេលចាប់ផ្តើមការចោទប្រកាន់ក្នុងគោលដៅស្វែងរកភស្តុតាង និងដើម្បីកសាងសំណុំរឿងព្រហ្មទណ្ឌ សុំឲ្យអនុវត្តច្បាប់នៅចំពោះមុខយុត្តាធិការស៊ើបសួរ និងយុត្តាធិការជំនុំជម្រះ ។[2] ក្នុងគោលបំណងដែលសុំឲ្យយុត្តាធិការទាំងពីរនេះ ធ្វើការវិនិច្ឆ័យសេចក្តីចំពោះជនល្មើសតាមរយៈការចោទប្រកាន់របស់

[1] ក្រមនីតិវិធីព្រហ្មទណ្ឌលេខ នស/រកម/០៨០៨/០២៤ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០៧ មាត្រា ១

[2] ក្រមនីតិវិធីព្រហ្មទណ្ឌលេខ នស/រកម/០៧០៨/០២៤ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០៧ មាត្រា ៤

ស្ថាប័នអយ្យការដើម្បីស្វែងរកពិរុទ្ធភាពនៃបទល្មើស និងតាមរយៈការសម្រេចផ្តន្ទាទោស ឬសម្រេចឲ្យរួចខ្លួន។ ការបង្កើតវិធានស៊ើបអង្កេតនិងអនុវត្តនៅក្នុងដំណើរការព្រហ្មទណ្ឌគឺ ដើម្បីធានាការពារកិត្តិយស សេចក្តីថ្លៃថ្នូរ និងអាយុជីវិតរបស់ពលរដ្ឋ

មិនឲ្យមានបុគ្គល ដែលគ្មានកំហុសត្រូវរងទណ្ឌកម្ម និងត្រូវដោះលែងឲ្យមានសេរីភាព។ ពោលគឺត្រូវធានាឲ្យបាន មិនឲ្យមានបុគ្គល ដែលបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌរួចផុតពីការទទួលខុសត្រូវនោះទេ។ នៅក្នុងវិធាននៃការស៊ើបអង្កេតនេះទៀតសោត តើមន្ត្រីនគេបាលយុត្តិធម៌ត្រូវមាននីតិវិធីយ៉ាងដូចម្តេចខ្លះ នៅក្នុងដំណើរការនៃរឿងក្តីព្រហ្មទណ្ឌមួយ? ជាទូទៅដោយយោងតាមស្មារតីនៃក្រមនីតិវិធីព្រហ្មទណ្ឌនគរបាលយុត្តិធម៌ គឺជាជំនួយរបស់តុលាការនៅក្នុងរឿងក្តីព្រហ្មទណ្ឌ។ ហើយនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌមានដូចជានីតិវិធីនៃការស៊ើបអង្កេត នីតិវិធីនៃការស៊ើបសួរ នីតិវិធីនៃការជំនុំជម្រះ និងនីតិវិធីមួយចំនួនទៀតដូចជានីតិវិធីប្រតិបត្តិ និងនីតិវិធីដោយឡែក។ ប្រសិនបើធ្វើការពិនិត្យឱ្យបានហ្មត់ចត់ចាប់ពីមាត្រា១ រហូតដល់មាត្រា ៦១២ នៃក្រមនីតិវិធីព្រហ្មទណ្ឌបានបង្ហាញអំពីមុខងារមួយចំនួនរបស់មន្ត្រីនគរបាលយុត្តិធម៌ ដែលបានកំណត់យ៉ាងជាក់ច្បាស់នៅក្នុងមាត្រានីមួយៗនៃក្រមនេះ ក្នុងគោលបំណងដើម្បីជួយសម្រួលដល់ស្ថាប័នអយ្យការតុលាការក្នុងការស្វែងរកយុត្តិធម៌ជូនដល់ប្រជាពលរដ្ឋដែលរងគ្រោះក៏ដូចជារងនូវភាពអយុត្តិធម៌ជាដើម ។

## ១.១ មូលដ្ឋានស្របច្បាប់នៃការស៊ើបអង្កេត

ការស៊ើបអង្កេត ធ្វើបានតែលើអំពើទាំងឡាយណាដែលជាបទល្មើស ដោយយោងតាមស្មារតីនៃក្រមនីតិវិធីព្រហ្មទណ្ឌមាត្រា ៥៦ បានបញ្ញត្តិថា នគរបាលយុត្តិធម៌មានភារកិច្ចត្រួតពិនិត្យ បទឧក្រិដ្ឋ បទមជ្ឈិម បទលហុ។ ចំពោះមូលដ្ឋានស្របច្បាប់នៃការស៊ើបអង្កេត បេសកម្មរបស់នគរបាលយុត្តិធម៌ត្រូវបានកំណត់រួមមាន៖

- ត្រួតពិនិត្យបទល្មើស
- ប្រមូលភស្តុតាង
- កំណត់អត្តសញ្ញាណ និងចាប់ខ្លួនចោរ[3] ។

**នគរបាលយុត្តិធម៌ ត្រូវបើកការស៊ើបអង្កេតមួយនៅពេលដែលបានដឹងពីអត្ថិភាពបទល្មើសមួយដោយ៖**

- ការស្រាវជ្រាវរបស់ខ្លួនផ្ទាល់
- ពាក្យបណ្តឹងពីជនរងគ្រោះ
- ឮដោយបណ្តឹងបរិហារពីតតិយជន ។

[3] ក្រមនីតិវិធីព្រហ្មទណ្ឌលេខ នស/រកម/០៧០៨/០២៤ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ៥៦

ម្យ៉ាងវិញទៀត ការស៊ើបអង្កេតនេះមានដំណើរការនីតិវិធីប្លែកៗពីគ្នាគួរឱ្យកត់សម្គាល់ អាស្រ័យទៅតាមក្របខណ្ឌតតិយុត្តិនៃការស៊ើបអង្កេតដែលមានចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ៖

- ការស៊ើបអង្កេតបទល្មើសជាក់ស្តែង
- ការស៊ើបអង្កេតបឋម
- ការអនុវត្តដីកាចាត់ឱ្យស៊ើបសួរជំនួស ។

ចំពោះការស៊ើបអង្កេតទាំងបីប្រភេទខាងលើនេះ គឺតម្រូវឱ្យអ្នកស៊ើបអង្កេតត្រូវចេះយ៉ាងស្ទាត់ជំនាញក្នុងការបំពេញភារកិច្ចរបស់ខ្លួន ។

នៅក្នុងរឿងក្តីព្រហ្មទណ្ឌ កាលណាបានដឹងអំពីបទល្មើស ដែលអាចជាបទឧក្រិដ្ឋ បទមជ្ឈិម បទលហុ មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការស៊ើបអង្កេតដោយឯកឯង ឬតាមការសុំរបស់ព្រះរាជអាជ្ញា។[4] នៅក្នុងដំណាក់កាលនៃការស៊ើបអង្កេតនេះ បន្ទាប់ពីមន្ត្រីនគរបាលយុត្តិធម៌បានដឹងអំពីហេតុការណ៍នោះរួចមក ជាបឋមត្រូវតែវាយតម្លៃអំពីប្រភេទនៃបទល្មើសជាមុនសិន ថាតើជាបទល្មើសជាក់ស្តែងឬជាបទល្មើសមិនជាក់ស្តែង ដើម្បីធ្វើជាជំនួយក្នុងការស៊ើបអង្កេតឱ្យបានសមស្របទៅតាមនីតិវិធីដែលច្បាប់បានកំណត់? ។ លើពីនេះទៅទៀត ដើម្បីជាកាតាលីករក្នុងការងាយស្រួលក្នុងការពិនិត្យបទល្មើស គួរតែមានការបែងចែកជាពីរផ្នែកសំខាន់តូចៗមានដូចជាការពិនិត្យរកបទល្មើសដោយខ្លួនឯង និងការពិនិត្យស្វែងរកបទល្មើសតាមរយៈពាក្យបណ្តឹងដែលអត្ថន័យក្នុងផ្នែកតូចៗទាំងពីរនេះរួមមាន៖

**ផ្នែកទី១៖** ការពិនិត្យបទល្មើសដោយខ្លួនឯង (សមាសភាពមន្ត្រីនគរបាលយុត្តិធម៌) មានន័យថា ចំពោះមន្ត្រីនគរបាលយុត្តិធម៌នៅពេលដែលគាត់រកឃើញថាកើតមានបទល្មើសជាក់ស្តែង ឬមិនជាក់ស្តែង គឺមន្ត្រីនគរបាលយុត្តិធម៌ មានសិទ្ធិធ្វើកិច្ចការតាមដំណើរការនីតិវិធីដោយខ្លួនឯងបានដោយពុំចាំបាច់មានបណ្តឹងពីប្រជាពលរដ្ឋឡើយ មានន័យថាជាបទល្មើសជាក់ស្តែង ដោយត្រូវអនុវត្តនីតិវិធីជាក់ស្តែងដែលច្បាប់បានកំណត់ក្នុងមាត្រា ៨៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

**ផ្នែកទី២៖** ការពិនិត្យស្វែងរកបទល្មើសតាមរយៈពាក្យបណ្តឹង គឺជាការពិនិត្យស្វែងរកបទល្មើសតាមរយៈពាក្យបណ្តឹង មានន័យថា នៅពេលដែលមានបទល្មើសកើតឡើងមួយរួចហើយមន្ត្រីនគរបាលយុត្តិធម៌ពុំបានដឹងអំពីហេតុការណ៍ទាំងនោះ ដូច្នេះ តើមន្ត្រីនគរបាលយុត្តិធម៌អាចទទួលបណ្តឹងពីអ្នកណាខ្លះ? ដោយជាក់ស្តែងចំពោះផ្នែកនេះ ការទទួលបណ្តឹងទាំងនេះអាចទទួលពីប្រជាពលរដ្ឋដែលរងគ្រោះផ្ទាល់ ឬក៏ជាតតិយជនដែល

[4] ក្រមនីតិវិធីព្រហ្មទណ្ឌលេខ នស/រកម/០៧០៨/០២៤ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ១១១

បានដឹងអំពីហេតុការណ៍នៃបទល្មើសទាំងនោះ ឬក៏ជារបាយការណ៍របស់ភ្នាក់ងារមន្ត្រីនគរបាលយុត្តិធម៌[5] ដើម្បីស្វែងរកនូវយុត្តិធម៌ទៅឱ្យជនរងគ្រោះ ម្យ៉ាងវិញទៀតចំពោះពាក្យបណ្ដឹងដែលមន្ត្រីនគរបាលយុត្តិធម៌អាចទទួលបានមានពីរ គឺ**ទី១**.បណ្ដឹងទាមទារ និង**ទី២**.បណ្ដឹងបរិហារ។

ក្នុងករណីមាន បទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្ដែង មន្ត្រីនគរបាលយុត្តិធម៌ត្រូវរាយការណ៍ភ្លាមទៅព្រះរាជអាជ្ញា ដោយមន្ត្រីនគរបាលយុត្តិធម៌ត្រូវចុះទៅកាន់ទីកន្លែងកើតហេតុដើម្បីធ្វើការពិនិត្យបទល្មើស[6]។ មូលដ្ឋានស្របច្បាប់នៃការចាប់ផ្ដើមស៊ើបអង្កេតបទល្មើសនេះទៀតសោត គឺអាចកើតចេញពីប្រភពជាច្រើនដែលក្នុងនោះរួមមានប្រភពមនុស្ស តាមរយៈការដាក់ពាក្យបណ្ដឹង, ប្រភពចេញពីបណ្ដាញសង្គម (Facebook) និងបណ្ដាញសាព័ត៌មាន ដែលមានដូចជាការចុះផ្សាយតាមរយៈកាសែត, ទូរទស្សន៍, វិទ្យុជាដើម។ល។ ក្រៅពីនេះក៏មានប្រភពជាឯកសារ ដែលពេលខ្លះជនសង្ស័យបានដាក់ឯកសារក្នុងគោលបំណងក្លែងនូវអង្គហេតុជាដើម។

### ១.២ សមាសភាពអ្នកស៊ើបអង្កេត

នៅក្នុងការស៊ើបអង្កេតរឿងក្ដីព្រហ្មទណ្ឌ សមាសភាពដែលមានតួនាទីស៊ើបអង្កេតក្នុងដំណាក់កាលដំបូងមុននឹងឈានទៅដល់ដំណាក់កាលនីតិវិធីបន្តបន្ទាប់នោះគឺ នគរបាលយុត្តិធម៌ ។ នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌបានបញ្ញត្តិចំពោះសមាសភាពរបស់នគរបាលយុត្តិធម៌ ព្រមទាំងបានកំណត់និងបែងចែកយ៉ាងជាក់លាក់ផងដែរថា សមាសភាពរបស់នគរបាលយុត្តិធម៌រួមមាន មន្ត្រីនគរបាលយុត្តិធម៌ ភ្នាក់ងារនគរបាលយុត្តិធម៌ និងមន្ត្រីរាជការសាធារណៈដទៃទៀត ដែលច្បាប់ដោយឡែកបានប្រគល់អំណាចឱ្យធ្វើការពិនិត្យនូវបទល្មើសខ្លះក្នុងរង្វង់ដែនសមត្ថកិច្ចរបស់ខ្លួន[7] ។

មន្ត្រីនគរបាលយុត្តិធម៌ គឺជាអ្នកបម្រើសេវាយុត្តិធម៌ផ្ទាល់ដែលស្ថិតនៅជិតប្រជាពលរដ្ឋបំផុតនៃដែនដីរដ្ឋបាលមូលដ្ឋានរបស់ខ្លួន។ មន្ត្រីនគរបាលយុត្តិធម៌ គឺជាជំនួយរបស់អំណាចតុលាការមានន័យថា នគរបាលយុត្តិធម៌ ជាជំនួយការរបស់ព្រះរាជអាជ្ញា ឬចៅក្រមស៊ើបសួរក្នុងការត្រួតពិនិត្យបទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុកំណត់អត្តសញ្ញាណ និងចាប់ជនល្មើសព្រមទាំងប្រមូលភស្តុតាង[8]។

[5] យោងតាមប្រសាសន៍របស់ ឯកឧត្តម ប៊ុន ហ៊ុន អនុរដ្ឋលេខាធិការនៃក្រសួងយុត្តិធម៌ ក្នុងកម្មវិធីផ្សព្វផ្សាយច្បាប់ ស្ដីពីក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

[6] ក្រមនីតិវិធីព្រហ្មទណ្ឌលេខ នស/រកម/០៧០៨/០២៤ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ៨៩

[7] ក្រមនីតិវិធីព្រហ្មទណ្ឌលេខ នស/រកម/០៧០៨/០២៤ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ៥៧

[8] ក្រមនីតិវិធីព្រហ្មទណ្ឌលេខ នស/រកម/០៧០៨/០២៤ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ៥៦

### ១.២.១ សមាសភាពនគរបាលយុត្តិធម៌

យោងតាមក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ ក៏បានបញ្ញត្តិផងដែរទាក់ទងទៅនឹងសមាសភាពរបស់នគរបាលយុត្តិធម៌ ដែលក្នុងនោះរួមមាន៖

១-មន្រ្តីនគរបាលយុត្តិធម៌

២-ភ្នាក់ងារនគរបាលយុត្តិធម៌

៣-មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដ៏ទៃទៀត ដែលច្បាប់ដោយឡែកប្រគល់ អំណាចឲ្យធ្វើការពិនិត្យបទល្មើសខ្លះៗក្នុងរង្វង់សមត្ថកិច្ចរបស់ខ្លួន[9] ។

#### ១.២.១.១ មន្ត្រីនគរបាលយុត្តិធម៌

បុគ្គលដែលមានគុណសម្បត្តិជាមន្រ្តីនគរបាលយុត្តិធម៌[10]៖

១-មន្រ្តីនគរបាលជាតិ មានឋានន្តរសក្តិចាប់ពីអនុសេនីយ៍ត្រីឡើងទៅ ដែលបានបំពេីការងារយ៉ាងតិចបំផុត០២ឆ្នាំក្នុងនគរបាលជាតិរួចហើយ ហើយបន្ទាប់ពីទទួលបានសញ្ញាបត្រជាន់ខ្ពស់ខាងនគរបាលយុត្តិធម៌។

២-នាយទាហាននៃកងរាជអាវុធហត្ថដែលបានបំពេីការងារយ៉ាងតិចបំផុត ០២ឆ្នាំ ក្នុងកងរាជអាវុធហត្ថរួចហើយបន្ទាប់ពីបានទទួលសញ្ញាបត្រជាន់ខ្ពស់ខាងនគរបាលយុត្តិធម៌។

៣-អ្នកមានឋានន្តរសក្តិ និងមុខងារដូចខាងក្រោម៖

ក-អភិបាល និងអភិបាលរង រាជធានី ខេត្ត, អភិបាល និងអភិបាលរង ក្រុង ស្រុក ខណ្ឌ និងមេឃុំចៅសង្កាត់។

ខ- ប្រធាន និងអនុប្រធាននាយកដ្ឋានកណ្តាលនគរបាលយុត្តិធម៌, ប្រធាន និងអនុប្រធាននាយកដ្ឋានកណ្តាលសន្តិសុខ, ប្រធាន និងអនុប្រធានកណ្តាល សណ្តាប់ធ្នាប់សាធារណៈ នៃអគ្គស្នងការនគរបាលជាតិ។

គ- ប្រធាន និងអនុប្រធាន, ប្រធាន និងអនុប្រធានការិយាល័យ, ប្រធាន និងអនុប្រធានផ្នែកដែលទទួលបន្ទុកកិច្ចការព្រហ្មទណ្ឌ និងស្ថិតក្រោមឱវាទរបស់នាយកដ្ឋានកណ្តាលនគរបាលយុត្តិធម៌នាយកដ្ឋានសន្តិសុខ និងនាយកដ្ឋាន កណ្តាលសណ្តាប់ធ្នាប់សាធារណៈ។

ឃ-ប្រធាន និងអនុប្រធាននាយកដ្ឋាន, ប្រធាន និងអនុប្រធានការិយាល័យ, ប្រធាន និងអនុប្រធានផ្នែកនៃ៖

- នាយកដ្ឋាននគរបាលព្រំដែន

[9] ក្រមនីតិវិធីព្រហ្មទណ្ឌលេខ នស/រកម/០៧០៨/០២៤ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ៥៧

[10] ក្រមនីតិវិធីព្រហ្មទណ្ឌលេខ នស/រកម/០៧០៨/០២៤ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ៦០

- មន្ទីរប្រឆាំងគ្រឿងញៀន
- ប្រធាននគរបាលទេសចរណ៍
- ស្នងការពិសេសការពារបេតិកភណ្ឌ។

ង- ស្នងការ ស្នងការរងនគរបាលខេត្ត-ក្រុង ។

ច- ប្រធាន និងអនុប្រធានការិយាល័យប្រធាន និងអនុប្រធានផ្នែក ដែលទទួលបន្ទុកការងារព្រហ្មទណ្ឌចំណុះស្នងការនគរបាលរាជធានី-ខេត្តដូចជា៖

- ការិយាល័យនគរបាលព្រហ្មទណ្ឌកំរិតធ្ងន់ និងការិយាល័យព្រហ្មទណ្ឌកំរិតស្រាល
- ការិយាល័យប្រឆាំងការជួញដូរមនុស្ស និងអនីតិជន
- ការិយាល័យនគរបាលសេដ្ឋកិច្ច
- ការិយាល័យបច្ចេកទេសវិទ្យាសាស្ត្រព្រហ្មទណ្ឌ
- ការិយាល័យប្រឆាំងគ្រឿងញៀន
- ការិយាល័យប្រឆាំងភេរវកម្ម និង
- ការិយាលល័យជនបរទេស។

ឆ- អធិការ និងអធិការរង ប្រធាន និងអនុប្រធានផ្នែកព្រហ្មទណ្ឌនៃអធិការដ្ឋាននគរបាលក្រុងស្រុក/ខណ្ឌ។

ជ- ប្រធាន និងអនុប្រធានការិយាល័យនគរបាលចរាចរណ៍, ប្រធាន និងអនុប្រធានផ្នែកនគរបាលចរាចរណ៍ "ចំពោះបទល្មើសចរាចរណ៍" ។ ប្រធាន និងអនុប្រធានការិយាល័យគ្រប់គ្រងអាវុធជាតិផ្ទុះ និងប្រធាន និងអនុប្រធានផ្នែកនៃការិយាល័យគ្រប់គ្រងអាវុធជាតិផ្ទុះ"ចំពោះបទល្មើសអាវុធជាតិផ្ទុះ"។ ប្រធាន និងអនុប្រធានអង្គភាពប្រធាននិងអនុប្រធានការិយាល័យនគរបាលទេសចរណ៍ ប្រធាននិងអនុប្រធានផ្នែកនៃការិយាល័យនគរបាលទេសចរណ៍។

ឈ- ប្រធាន និងអនុប្រធានប៉ុស្តិ៍នគរបាលឃុំ សង្កាត់ ចំពោះបទល្មើស ព្រហ្មទណ្ឌ។

ញ- មេបញ្ជាការ និងមេបញ្ជាការរងនៃកងរាជអាវុធហត្ថ ដែលទទួលបន្ទុក កិច្ចការព្រហ្មទណ្ឌ។

ដ- មេបញ្ជាការ និងមេបញ្ជាការរងនៃកងរាជអាវុធហត្ថ ប្រចាំរាជធានី/ខេត្ត ដែលទទួលបន្ទុកកិច្ចការព្រហ្មទណ្ឌ។

ឋ- មេបញ្ជាការ និងមេបញ្ជាការរងនៃកងរាជអាវុធហត្ថ ប្រចាំក្រុង/ស្រុក/ខណ្ឌ ដែលទទួលបន្ទុកកិច្ចការព្រហ្មទណ្ឌ។

ឌ- ប្រធាន និងអនុប្រធានការិយាល័យប្រធាន និងអនុប្រធានផ្នែកនៃកងរាជអាវុធហត្ថទទួលបន្ទុកកិច្ចការព្រហ្មទណ្ឌ។

ឍ- ប្រធាន និងអនុប្រធានអង្គភាពផ្សេងៗទៀតដែលទទួលបន្ទុកកិច្ចការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌដែលត្រូវបានបង្កើតក្នុងករណីចាំបាច់។

រដ្ឋមន្ត្រីនៃក្រសួងយុត្តិធម៌ គឺជាអាណាព្យាបាលនៃមន្ត្រីនគរបាល ព្រមទាំងក៏ជាអាណាព្យាបាលនៃនាយទាហានកងរាជអាវុធហត្ថទាំងឡាយដែលមានចែងនៅក្នុងចំណុចទី១ ទី២ និងទី៣ នៃមាត្រា ៦០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ មានភារកិច្ចតែងតាំងមន្ត្រីនគរបាល និងនាយទាហានកងរាជអាវុធហត្ថទាំងឡាយណាដែលត្រូវបំពេញមុខងារជាមន្ត្រីនគរបាលយុត្តិធម៌ដោយប្រកាសរួមជាមួយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។ ម្យ៉ាងទៀត មុននឹងឈានដល់ការទទួលបាននូវការតែងតាំងនិងការផ្ដល់នីតិសម្បទាជានគរបាលយុត្តិធម៌ គឺត្រូវតែមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែលប្បញ្ញត្តិក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ដោយត្រូវមានការឆ្លងកាត់ការប្រឡងបែបបទវិជ្ជាជីវៈជាមុនសិន។

**កំណត់សម្គាល់៖** បែបបទនៃការទទួលបានសញ្ញាបត្រជាន់ខ្ពស់, បែបបទសម្បថនៃមន្ត្រីនគរបាលយុត្តិធម៌ នីតិវិធីខាងវិន័យ និងទណ្ឌកម្មរបស់មន្ត្រីនគរបាលយុត្តិធម៌ត្រូវបានកំណត់នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ[11] ។

### ក. សមត្ថកិច្ចដែនដីរបស់មន្ត្រីនគរបាលយុត្តិធម៌

មន្ត្រីនគរបាលយុត្តិធម៌ម្នាក់ៗ មានសមត្ថកិច្ចនៅក្នុងព្រំប្រទល់ដែនដីនៃអង្គភាពដែលខ្លួនត្រូវបានចាត់តាំងឲ្យទៅបំពេីការងារ។ ដោយឡែកចំពោះរាជធានីភ្នំពេញ មន្ត្រីនគរបាលយុត្តិធម៌មានសមត្ថកិច្ចនៅលើវិសាលភាពនៃរាជធានីទាំងមូល ទោះបីអង្គភាពដែលខ្លួនផ្លាស់ទៅកាន់នោះនៅកន្លែងណាក៏ដោយ[12] ។

តាមមាត្រា ៦៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ក្នុងករណីបទឧក្រិដ្ឋ ឬមជ្ឈិមជាក់ស្ដែង ប្រសិនបើមានការបន្ទាន់ ព្រះរាជអាជ្ញាអាចអនុញ្ញាតឲ្យមន្ត្រីនគរបាលយុត្តិធម៌ ធ្វើប្រតិបត្តិការនៅលើវិសាលភាពនៃដែនដីជាតិទាំងមូល។ ការអនុញ្ញាតអាចធ្វើដោយផ្ទាល់មាត់ ប៉ុន្តែការអនុញ្ញាតនេះត្រូវតែចុះនិទ្ទេសនៅក្នុងលិខិតស៊ើបអង្កេត។

ក្នុងក្របខ័ណ្ឌនៃការស៊ើបសួរ កាលណាចៅក្រមចេញដីកាចាត់ឲ្យស៊ើបសួរជំនួសក្នុងករណីបន្ទាន់ ចៅក្រមនេះអាចអនុញ្ញាតឲ្យមន្ត្រីនគរបាលយុត្តិធម៌ធ្វើប្រតិបត្តិការនៅលើវិសាលភាពដែនដីជាតិទាំងមូលបាន។

កាលណាធ្វើប្រតិបត្តិការនៅក្រៅមណ្ឌលរបស់ខ្លួននោះ មន្ត្រីនគរបាលយុត្តិធម៌ត្រូវសុំជំនួយពីមន្ត្រីនគរបាលយុត្តិធម៌ដែលមានសមត្ថកិច្ចខាងដែនដីនោះ។

[11] ក្រមនីតិវិធីព្រហ្មទណ្ឌលេខ នស/រកម/០៧០៨/០២៤ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០៧, ចាប់ពីមាត្រា ៦១ រហូតដល់មាត្រា ៦៦

[12] ក្រមនីតិវិធីព្រហ្មទណ្ឌលេខ នស/រកម/០៧០៨/០២៤ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ៦៧

ចៅក្រមស៊ើបសួរ ដែលបានអនុញ្ញាតឲ្យមានការពន្លាតសមត្ថកិច្ចត្រូវជូនព័ត៌មានតាមគ្រប់ធ្យោបាយដល់ព្រះរាជអាជ្ញាដែលមានសមត្ថកិច្ចខាងដែនដី[13] ។

### ១.២.១.២ ភ្នាក់ងារនគរបាលយុត្តិធម៌

ដោយយោងតាមមាត្រា ៧៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ក៏បានបញ្ញត្តិអំពីបុគ្គលដែលមានគុណសម្បត្តិជាភ្នាក់ងារនគរបាលយុត្តិធម៌រួមមាន៖

- នាយនគរបាល និងនាយនគរបាលរង ដែលមិនមានគុណសម្បត្តិជាមន្ត្រីនគរបាលយុត្តិធម៌
- ភ្នាក់ងារនគរបាលជាតិផ្សេងទៀត
- នាយទាហាននៃកងរាជអាវុធហត្ថ
- យោធិនផ្សេងទៀតនៃកងរាជអាវុធហត្ថ ។

និយាយជារួម ក្រៅពីសមាសភាពមន្ត្រីនគរបាលយុត្តិធម៌ ភ្នាក់ងារនគរបាលយុត្តិធម៌ក៏មានតួនាទីជួយដល់មន្ត្រីនគរបាលយុត្តិធម៌ ដែលភ្នាក់ងារនគរបាលយុត្តិធម៌ មានបេសកម្មមួយចំនួនរួមមានដូចជា ពិនិត្យបទល្មើសជាអាទិ៍ បទលហុ និងជួយដល់មន្ត្រីនគរបាលយុត្តិធម៌ក្នុងការបំពេញមុខងាររបស់គេ[14]។ ដោយចំពោះការពិនិត្យបទល្មើស ភ្នាក់ងារនគរបាលយុត្តិធម៌ជាអ្នកធ្វើរបាយការណ៍ ដែលរបាយការណ៍នេះទៀតសោតមានតម្លៃត្រឹមតែពត៌មានធម្មតាតែប៉ុណ្ណោះ។ **កំណត់សម្គាល់៖** ក្នុងករណីណាក៏ដោយ ភ្នាក់ងារនគរបាលយុត្តិធម៌ពុំអាចបំពេញកិច្ចទាំងឡាយដែលត្រូវរក្សាទុកជូនតែមន្ត្រីនគរបាលយុត្តិធម៌ ប្រសិនបើមានការបំពេញភារកិច្ចទាំងឡាយណាដែលត្រូវបានបំពេញដោយបំពានការហាមឃាត់នេះ នឹងត្រូវចាត់ទុកជាមោឃៈ។

### ១.២.១.៣ មន្ត្រីរាជការនិងភ្នាក់ងារសាធារណៈដ៏ទៃទៀត ដែលមាននីតិសម្បទាពិសេសសម្រាប់ពិនិត្យបទល្មើសមួយចំនួន

មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដែលច្បាប់ដោយឡែកប្រគល់អំណាចឲ្យធ្វើការពិនិត្យបទល្មើសត្រូវដាក់ឲ្យស្ថិតនៅក្រោមអំណាចរបស់ព្រះរាជអាជ្ញាក្នុងពេលបំពេញមុខងារនេះ។ បែបបទ និងនីតិវិធីនៃការផ្តល់នីតិសម្បទាត្រូវកំណត់ដោយប្រកាសរួមរវាងក្រសួងយុត្តិធម៌ និងក្រសួងពាក់ព័ន្ធ។ មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដ៏ទៃទៀតត្រូវស្បថថា "បំពេញមុខងាររបស់ខ្លួនដោយស្មោះត្រង់"។ សម្បថត្រូវធ្វើនៅចំពោះមុខសាលាដំបូង ចំណែកឯរូបមន្តនៃពាក្យសម្បថត្រូវ កំណត់ដោយប្រកាសរបស់ក្រសួងយុត្តិធម៌។ ចំពោះការពិនិត្យបទល្មើស មន្ត្រីរាជការ និងភ្នាក់ងារទាំងនេះ ធ្វើរបាយការណ៍។ របាយការណ៍នេះមានតម្លៃត្រឹមតែព័ត៌មានធម្មតាប៉ុណ្ណោះ។

[13] ក្រមនីតិវិធីព្រហ្មទណ្ឌលេខ នស/រកម/០៧០៨/០២៤ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ៦៨

[14] ក្រមនីតិវិធីព្រហ្មទណ្ឌលេខ នស/រកម/០៧០៨/០២៤ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ៧៨

រាល់កំហុសទាំងឡាយដែលបានប្រព្រឹត្តដោយ មន្ត្រីរាជការនិងភ្នាក់ងារសាធារណៈដ៏ទៃទៀតនៅក្នុងពេលបំពេញមុខងាររបស់ខ្លួន ត្រូវតែឲ្យដំណឹងដោយព្រះរាជអាជ្ញា ឬដោយចៅក្រមស៊ើបសួរជូនចំពោះអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍។ អគ្គព្រះរាជអាជ្ញា ប្រកាសប្រាប់រដ្ឋមន្ត្រីដែលមន្ត្រី ឬភ្នាក់ងារនោះនៅក្រោមឱវាទដើម្បីចាប់ផ្ដើមនីតិវិធីខាងវិន័យ ទណ្ឌកម្មខាងវិន័យមិនមែនជាឧបសគ្គដល់ការធ្វើបណ្ដឹងអាជ្ញា ប្រសិនបើមានបទល្មើសត្រូវបានប្រព្រឹត្ត[15] ។

### ១.៣ តួនាទី និងភារកិច្ចរបស់មន្ត្រីនគរបាលយុត្តិធម៌

តួនាទី និងភារកិច្ចរបស់មន្ត្រីនគរបាលយុត្តិធម៌ គឺជានាការពារសិទ្ធិរបស់ប្រជាពលរដ្ឋ ព្រមទាំងបង្ការនិងបង្ក្រាបបទល្មើសឲ្យមានប្រសិទ្ធភាពខ្ពស់ ដើម្បីការពារសន្តិសុខសុវត្ថិភាព និងសណ្ដាប់ធ្នាប់សាធារណៈក៏ដូចជាផ្ទៃជាតិនិងអន្តរជាតិ។ មន្ត្រីនគរបាលយុត្តិធម៌ ត្រូវភារកិច្ចចម្បងគឺត្រួតពិនិត្យ បទឧក្រិដ្ឋ បទមជ្ឈិម បទលហុ ព្រមទាំងប្រមូលភស្តុតាងតាមរយៈការបំពេញកិច្ចស៊ើបអង្កេត ហើយបញ្ជូនជនល្មើសទៅសាលាជម្រះក្ដីដែលមានភារកិច្ចផ្ដន្ទាទោសជននោះ។ ជាក់ស្ដែងដូចជា បទល្មើសដែលកំពុងប្រព្រឹត្តឬបទល្មើសដែលទើបតែប្រព្រឹត្តរួចភ្លាមៗ ដែលគេកំណត់ថាជាបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្ដែង និងត្រូវចាត់ទុកជាបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្ដែងផងដែរ កាលណាបន្តិចក្រោយមក ជនសង្ស័យត្រូវបានសាធារណៈជនស្រែកដេញប្រផាប់ចាប់ប្រកឹង ឬបុគ្គលដែលត្រូវបានគេរកឃើញមានវត្ថុ ឬមានស្លាកស្នាម ឬតម្រុយច្បាស់លាស់ ហើយស៊ីសង្វាក់ផ្សេងទៀតដែលនាំឲ្យគេសន្និដ្ឋានបានថាបុគ្គលនោះបានប្រព្រឹត្តបទល្មើស[16] ។

ជាគោលការណ៍នៃការស៊ើបអង្កេត គឺត្រូវមានភាពបន្ទាន់ដែលតម្រូវឲ្យប្រមូលភស្តុតាងដែលនៅមាននៅឡើយរបស់បទល្មើសដែលទើបតែប្រព្រឹត្តថ្មី ដើម្បីឆ្លើយតបទៅនឹងភាពចាំបាច់នេះ ច្បាប់បានចែងយ៉ាងច្បាស់អំពីការបង្កើតវិធានដែលរហ័ស និងការបង្កើតអំណាចរបស់មន្ត្រីនគរបាលយុត្តិធម៌ ដែលពួកគាត់ត្រូវមានភារកិច្ចឆ្លើយតបមួយដែលលឿន និងមានប្រសិទ្ធភាពដើម្បីជៀសវាងការបាត់បង់ភស្តុតាងនិងការគេចខ្លួនរបស់ជនសង្ស័យ។ មានន័យថាក្នុងស្ថានភាពជាក់ស្ដែងមន្ត្រីនគរបាលយុត្តិធម៌ មានកាតព្វកិច្ចក្នុងការបើកការស៊ើបអង្កេតជាក់ស្ដែង ដោយធ្វើឡើងគោរពតាមប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌយ៉ាងម៉ឺងម៉ាត់បំផុត។

តួនាទីចម្បងរបស់មន្ត្រីនគរបាលយុត្តិធម៌នៅដំណាក់កាលស៊ើបអង្កេត យើងអាចបែងចែកជា ០២ (ពីរ) ប្រភេទ ៖ (ក) នៅក្នុងការពិនិត្យស្វែងរកបទល្មើស និង (ខ) នៅក្នុងការស៊ើបអង្កេតស្វែងរកភស្តុតាង។

[15] ក្រមនីតិវិធីព្រហ្មទណ្ឌលេខ នស/រកម/០៧០៨/០២៤ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ៨២

[16] ក្រមនីតិវិធីព្រហ្មទណ្ឌលេខ នស/រកម/០៧០៨/០២៤ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ៨៦

### ១.៣.១ ការពិនិត្យស្វែងរកបទល្មើស

មន្ត្រីនគរបាលយុត្តិធម៌ មានតួនាទីដោយស្វ័យប្រវត្តិក្នុងការពិនិត្យស្វែងរកបទល្មើសដោយខ្លួនឯងដែលមិនមែនរង់ចាំមានពាក្យបណ្តឹងពីប្រជាពលរដ្ឋនោះទេ ទើបខ្លួនមានសមត្ថកិច្ចត្រួតពិនិត្យនោះទេ ព្រោះថាមន្ត្រីនគរបាលយុត្តិធម៌ ជាអ្នកបម្រើសេវាយុត្តិធម៌ផ្ទាល់ដល់ប្រជាពលរដ្ឋ។ ក្រៅពីនេះ មន្ត្រីនគរបាលយុត្តិធម៌ក៏ត្រូវត្រួតពិនិត្យស្វែងរកបទល្មើសតាមរយៈពាក្យបណ្តឹងបានផងដែរ។ ពាក្យបណ្តឹង មិនតម្រូវឲ្យធ្វើឡើងក្រោមទម្រង់ណាមួយជាដាច់ខាតនោះទេ គ្រាន់តែធ្វើឲ្យយ៉ាងណាឲ្យមន្ត្រីនគរបាលយុត្តិធម៌បានដឹងអំពីហេតុការណ៍នោះជាការសម្រេចអាចធ្វើតាមរយៈទម្រង់លាយលក្ខណ៍ អក្សរ ឬទម្រង់ផ្ទាល់មាត់ គឺគ្រប់គ្រាន់។ បន្ទាប់ពីមន្ត្រីនគរបាលយុត្តិធម៌បានដឹងអំពីហេតុការណ៍តាមរយៈមធ្យោបាយដោយខ្លួនផ្ទាល់ក្តី ឬតាមរយៈពាក្យបណ្តឹងរបស់ប្រជាពលរដ្ឋក្តី មន្ត្រីនគរបាលយុត្តិធម៌ត្រូវមានតួនាទីក្នុងការស៊ើបអង្កេតស្វែងរកភស្តុតាងជាបន្ត។

### ១.៣.២ ការស៊ើបអង្កេតស្វែងរកភស្តុតាង

បន្ទាប់ពីមន្ត្រីនគរបាលយុត្តិធម៌បានដឹងអំពីហេតុការណ៍នោះរួចមក ជាបឋមត្រូវវាយតម្លៃអំពីប្រភេទនៃបទល្មើសជាមុនសិន ថាតើជាបទល្មើសជាក់ស្តែង ឬមិនមែនជាបទល្មើសជាក់ស្តែង? ហើយតួនាទីរបស់មន្ត្រីនគរបាលយុត្តិធម៌គឺអាស្រ័យលើប្រភេទនៃបទល្មើសទាំងពីរនេះ។ ជាក់ស្តែងពាក់ព័ន្ធនឹងការស៊ើបអង្កេតស្វែងរកភស្តុតាងនេះ ការកំណត់សញ្ញាណទូទៅនៃភស្តុតាងត្រូវបានរៀបរាប់ដូចខាងក្រោម៖

## ផ្នែក២ សញ្ញាណទូទៅនៃភស្តុតាង

នៅក្នុងរឿងក្តីនីមួយៗ ដូចជារឿងព្រហ្មទណ្ឌកម្រិតនៃភស្តុងតាងទាបឬខ្ពស់អាស្រ័យទៅតាមដំណាក់កាលនៃនីតិវិធីនីមួយៗ។ សម្រាប់ការឃាត់ខ្លួនបុគ្គលណាម្នាក់ ដើម្បីសាកសួរដោយសង្ស័យថាអាចនឹងប្រព្រឹត្តបទល្មើសណាមួយនោះ កម្រិតនៃភស្តុតាង គឺជាការសង្ស័យដែលមានហេតុផល (Reasonable Suspicion) សម្រាប់យកមកវិនិច្ឆ័យ។ ហេតុដូចនេះហើយ ទើបការវិភាគឬវិនិច្ឆ័យនូវបទល្មើសណាមួយគឺតម្រូវឱ្យមានភស្តុតាងគ្រប់គ្រាប់សម្រាប់ពិចារណាព្រឹត្តិហេតុដែលអាចបង្ហាញពីវត្តមានធាតុផ្សំនៃបទល្មើស ព្រមទាំងអាចកំណត់អត្តសញ្ញាណនៃអ្នកប្រព្រឹត្តបទល្មើសផងដែរ។ ដើម្បីឱ្យយល់កាន់តែច្បាស់អំពីភស្តុតាង នៅចំណុចបន្ទាប់នឹងមានការបកស្រាយអំពីភស្តុតាងនេះ។

## កថាខណ្ឌ១ អត្ថន័យនៃភស្តុតាង

ភស្តុតាង គឺជាតឹកតាងជាលាយលក្ខណ៍អក្សរ ឬមិនមែនជាលាយលក្ខណ៍អក្សរ ដែលជាមូលដ្ឋាននៃការសម្រេចសេចក្តីរបស់តុលាការ។

ភស្តុតាង ផ្អែកទៅតាមន័យទូលាយ គឺជាការចង្អុលបង្ហាញឱ្យឃើញនូវអត្ថិភាពនៃអំពើ ឬលិខិតគតិយុត្តណាមួយ ។ តាមន័យចង្អៀត គឺជាវិធីដែលប្រើប្រាស់ ដើម្បីបង្ហាញឱ្យឃើញនូវភស្តុតាងនេះ ។[17]

ភស្តុតាង មានន័យដូចខាងក្រោម[18]៖

- របស់ជាតឹកតាងជាគ្រឿងសម្គាល់ជាសំអាង។
- ការចង្អុលបង្ហាញឲ្យឃើញនូវអត្ថិភាពនៃអំពើ ឬលិខិតគតិយុត្តណាមួយ។ **ឧទាហរណ៍៖** កាំបិតគឺជាភស្តុតាងមួយបញ្ជាក់ពីអត្ថិភាពនៃអំពើរបស់ របស់ជនល្មើសដែលបានចាក់សម្លាប់ជនរងគ្រោះ។

ភស្តុតាង គឺជាវិធីទាំងពួងដែលបង្កើតឡើងសម្រាប់នឹងបញ្ជាក់អំពីអត្ថិភាពនៃកិច្ចការ ផ្សេងៗ ដែលជាទីនាំមកនូវសិទ្ធិ [19] ។ គោលបំណងចុងក្រោយបំផុតនៃភស្តុតាង គឺស្វែងរកការពិត ។

ភស្តុតាង គឺជាព្រឹត្តិហេតុ ឬអង្គហេតុទាំងឡាយដែលអង្គហេតុទាំងនោះត្រូវបានកំណត់ដោយច្បាប់ទៅលើទម្រង់នីតិវិធីនានារបស់វា ដើម្បីធ្វើការបង្ហាញ ឬបដិសេធទៅលើព្រឹត្តិការណ៍នៃបទល្មើសណាមួយបានដោយអង្គហេតុទាំងនោះបង្ហាញនូវការដាក់បន្ទុក ឬដោះបន្ទុកដោះសារចំពោះការទទួល ខុសត្រូវរបស់បុគ្គល ព្រមទាំងកំណត់បាននូវ កម្រិតខ្ពស់ ឬទាប និងធ្ងន់ឬស្រាល ទៅលើការទទួល ខុសត្រូវរបស់បុគ្គលទាំងនោះទៀតផង[20] ។ ភស្តុតាង គឺអាចផ្តល់នូវព័ត៌មានពីហេតុការណ៍ ដែកត្រូវស៊ើបអង្កេតដែលអាចមានដូចជា វត្ថុ ស្លាកស្នាម សំណល់ សរីរៈ និងការសង្កេតរបស់អ្នកស៊ើបអង្កេត, សក្ខីកម្ម របស់សាក្សី, ជនរងគ្រោះ, ជនសង្ស័យ, ឯកសារ និងការវិភាគរបស់អ្នកជំនាញ។

ការស៊ើបអង្កេតនេះ ជួនកាលត្រូវបានគេប្រៀបប្រដូចទៅនឹងការដំឡើងរូបភាពនៃល្បែងល្បងប្រាជ្ញាភស្តុតាងនីមួយៗប្រៀបដូចគ្នាទៅនឹងបំណែកមួយៗនៃរូបភាពនោះ។ ការធ្វើការប្រៀបធៀបបែបនេះ គឺមានប្រយោជន៍ណាស់ក្នុងការមើលឃើញថាតួនាទីរបស់ភស្តុតាងបានដើរតួគ្រប់ទិដ្ឋភាព នៃការស៊ើបអង្កេតទាំងអស់។

## ១.១ កម្មវត្ថុនៃការស្វែងរកភស្តុតាង

គោលបំណងនៃភស្តុតាង គឺចង់បង្ហាញអំពីការប្រមូលព័ត៌មានឲ្យបានពេញលេញ និងគ្រប់ជ្រុងជ្រោយព្រមទាំងឲ្យបានច្បាស់លាស់ និងត្រឹមត្រូវតាមនីតិវិធីនៃច្បាប់ដែលបានបង្កើតនូវទម្លាក់ក្នុងការកំណត់អំពីអត្ថិភាពនៃបទល្មើស,អត្តសញ្ញាណរបស់ជនប្រព្រឹត្តបទល្មើស ហើយឈានទៅដល់ការសម្រេចសេចក្តីរបស់តុលា

[17] សទ្ទានុក្រមបារាំងខ្មែរនៃពាក្យច្បាប់ ឆ្នាំ២០០៥ ទំព័រ២២៦ រៀបរៀងដោយសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

[18] នីតិព្រហ្មទណ្ឌទូទៅ រៀបរៀងដោយលោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ និង លោកស្រីសាស្ត្រចារ្យ ចាំង ស៊ីណាត ឆ្នាំ២០១២ ទំព័រ៥៦៩

[19] សេចក្តីផ្តើមនៃនីតិកម្ពុជា រៀបរៀងដោយ ការិយាល័យស្រាវជ្រាវនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ចឆ្នាំ ២០០៥ ទំព័រ១៥៥

[20] ក្រមនីតិវិធីព្រហ្មទណ្ឌលេខ នស/រកម/០៧០៨/០២៤ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ១ កថាខណ្ឌ ១

ការដោយត្រឹមត្រូវតាមផ្លូវច្បាប់។ ក្នុងរឿងក្តីព្រហ្មទណ្ឌ ភស្តុតាងត្រូវបានគេចាត់ទុកថាមានប្រយោជន៍ និងជឿទុកចិត្តបានគឺលុះត្រាតែមានការប្រមូលភស្តុតាងទាំងនោះ ត្រូវបានធ្វើទៅតាមលក្ខខណ្ឌគ្រឹះនៃច្បាប់ដោយមានការកំណត់ឲ្យច្បាស់នូវអត្ថិភាពនៃបទល្មើសព្រហ្មទណ្ឌណាមួយ ហើយនឹងត្រូវអនុវត្តចំពោះរឿងព្រហ្មទណ្ឌកាលណាពុំមានវិធានដោយឡែកចែងដោយច្បាប់ពិសេសទេនោះ។ យោងតាមស្មារតីនៃក្រមនីតិវិធីព្រហ្មទណ្ឌក្នុងមាត្រា ១ ដែលបង្ហាញពីគោលបំណងនៃការគោរពវិធាន មានគោលបំណងកំណត់អំពីវិធានទាំងឡាយដែលត្រូវគោរព និងប្រព្រឹត្តិតាមដោយហ្មត់ចត់ដើម្បីកំណត់ឱ្យច្បាស់នូវអត្ថិភាពនៃបទល្មើសព្រហ្មទណ្ឌណាមួយ។

## កថាខណ្ឌ២ ចំណាត់ថ្នាក់ភស្តុតាង

ចំណាត់ថ្នាក់នៃភស្តុតាងត្រូវបានបែងចែកជាបីប្រភេទដូចជា ប្រភេទវត្ថុ (សំណល់, សរីរៈ) ប្រភេទសក្ខីកម្ម និងប្រភេទឯកសារ។

### ២.១ ប្រភេទវត្ថុ សំណល់ សរីរៈ

ភស្តុតាងជាវត្ថុ សំដៅដល់របស់ដែលមានរូបដោយលក្ខណៈទាំងឡាយនៃវត្ថុទាំងនោះមានខ្លឹមសារភ្ជាប់ទៅនឹងសំណុំរឿងក្តី។ ពោលគឺមានន័យថា វត្ថុនោះជាប្រភពនៃការផ្តល់ព័ត៌មានអំពីអង្គហេតុ សក្ខីកម្មឬអង្គហេតុគ្រឹះ ហើយលើសពីនេះទៅទៀត វត្ថុនោះជាវត្ថុដែលអាចផ្តល់ព័ត៌មានអំពីអង្គហេតុផង និងវាខ្លួនឯងបម្រើដល់អត្ថិភាពនៃអង្គសេចក្តីផង ពោលគឺអាចប្រើក្នុងការបម្រើដល់អត្ថិភាព ឬនត្ថិភាពនៃបទល្មើសបាន។

ភស្តុតាងជាវត្ថុ ក៏សំដៅដល់វត្ថុទាំងឡាយណាដែលបម្រើដល់ចំណែកៗនៃភស្តុតាង មានន័យថាជាកម្មវត្ថុទាំងឡាយណាដែលបានបម្រើដល់ភស្តុតាងនានា ដោយភស្តុតាងជាវត្ថុនោះវាបានកំណត់នូវអង្គហេតុនៃបទល្មើស និងកំណត់បាននូវការប្រព្រឹត្តរបស់បុគ្គល។ អាចនិយាយបានថាសំដៅដល់វត្ថុទាំងឡាយណាដែលវត្ថុនោះមានកម្មវត្ថុរបស់វាបម្រើដល់ការដាក់បន្ទុកផង និងដោះបន្ទុកផង។

លើសពីនេះទៅទៀត ភស្តុតាងជាវត្ថុ ត្រូវបានគេហៅថាជា "សាក្សីគ" ពីព្រោះសាក្សីធម្មតាជាមនុស្សដែលអាចនិយាយបាន និងចេះរៀបរាប់បានតាមគ្រប់សកម្មភាពដែលគេទទួលដឹងតាមវិញ្ញាណនានា។ ជាទូទៅភស្តុតាងជាវត្ថុនេះ ជាទឡ្ហីកម្មមួយ ដែលបញ្ជាក់នូវអង្គហេតុពិត ហើយអាចមានសារៈសំខាន់បំផុតក្នុងរឿងក្តីទាំងឡាយ។

## ២.២ ប្រភេទសក្ខីកម្ម

### ២.២.១ ការបំភ្លឺរបស់សាក្សី

ការបំភ្លឺរបស់សាក្សី សំដៅភស្តុតាងគ្រឹះដ៏រឹងមាំមួយ ដែលគ្របដណ្តប់ទៅលើសំណុំរឿងទាំងមូល។ ជាទូទៅការបំភ្លឺរបស់សាក្សី គឺជាសេចក្តីថ្លែងការណ៍អំពីអង្គហេតុទាំងឡាយ ដែលវាមានអត្ថប្រយោជន៍សម្រាប់កិច្ចការព្រហ្មទណ្ឌ ស្តីពីអង្គហេតុទាំងឡាយដែលពួកគេបានដឹង។ សាក្សី គឺជាបុគ្គលដែលត្រូវបានសាកសួរដោយស្ថាប័នស៊ើបអង្កេត និងតុលាការអំពីហេតុដែល សាក្សីនោះបានទទួលដឹង។ ជាក់ស្តែងមន្រ្តីនគរបាលយុត្តិធម៌អាចកោះហៅ និងស្តាប់ចម្លើយបុគ្គលដែលត្រូវបានសង្ស័យថាបានចូលរួមក្នុងបទល្មើស ឬដែលអាចផ្តល់ពត៌មានស្តីពីរឿងហេតុ[21]។ មិនត្រឹមតែប៉ុណ្ណោះ មន្រ្តីនគរបាលយុត្តិធម៌ក៏អាចកោះហៅ និងស្តាប់ចម្លើយបុគ្គលគ្រប់រូបដែលអាចផ្តល់ពត៌មានស្តីអំពីរឿងហេតុបានដែរ[22] ពាក់ព័ន្ធនឹងសាក្សី មន្រ្តីនគរបាលយុត្តិធម៌ក៏អាចកោហៅ និង ស្តាប់ចម្លើយសាក្សីផងដែរ[23]។

### ២.២.២ ការបំភ្លឺរបស់ជនរងគ្រោះ

ការបំភ្លឺរបស់ជនរងគ្រោះ គឺជាប្រភេទភស្តុតាងដែលពិសេសជាងគេ ពោលគឺជាការផ្តល់ពត៌មានដែលធ្វើឡើងដោយ ជនរងគ្រោះផ្ទាល់ដោយតាមរយៈការសាកសួរយកចម្លើយនៅគ្រប់ដំណាក់កាលនៃនីតិវិធីចំពោះចំណាត់ការរឿងក្តីព្រហ្មទណ្ឌ ដោយបានកត់ត្រាយ៉ាងត្រឹមត្រូវតាមវិធានដែលច្បាប់បានកំណត់។ ក្នុងករណីដែលជនរងគ្រោះស្លាប់ អ្នកស៊ើបអង្កេតបទល្មើស ត្រូវពឹងផ្អែកទៅលើអ្នកជំនាញផ្សេងៗក្នុងការធ្វើកោសល្យវិច្ច័យបែបឧក្រិដ្ឋនិច្ច័យ និងពេទ្យតុលាការ (កោសលវិច័យបែបវេជ្ជសាស្រ្ត) ដែលត្រូវផ្ទៀងផ្ទាត់ និងវាយតម្លៃ។

## ២.៣ ប្រភេទឯកសារ

### ២.៣.១ កំណត់ហេតុអង្កេត

កំណត់ហេតុអង្កេត គឺជាឯកសារដែលកត់ត្រានូវលក្ខណៈនានាលើវត្ថុផ្សេងៗដែលជាកម្មវត្ថុនៃការស៊ើបអង្កេតដូចជា៖ អគារ ឬទីតាំងដែលត្រូវធ្វើការស៊ើបអង្កេត។ ការកត់ត្រានៅក្នុងកំណត់ហេតុនេះ បង្កើតបានទទ្បីករមួយដែលសំខាន់ក្នុងសំណុំរឿង ពីព្រោះកំណត់ហេតុទាំងនេះត្រូវបានអ្នកស៊ើបអង្កេតធ្វើឡើងដោយធ្វើការកត់ត្រាភ្លាមៗទៅលើទីតាំងកើតហេតុ បន្ទាប់ពីជនល្មើសបានប្រព្រឹត្តរួចថ្មីៗបំផុត។ កំណត់ហេតុនេះ ចងសម្ព័ន្ធភាព

[21] ក្រមនីតិវិធីព្រហ្មទណ្ឌលេខ នស/រកម/០៧០៨/០២៤ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ១១៤ កថាខណ្ឌ ១១

[22] ក្រមនីតិវិធីព្រហ្មទណ្ឌលេខ នស/រកម/០៧០៨/០២៤ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ៩៤ កថាខណ្ឌ ១

[23] ក្រមនីតិវិធីព្រហ្មទណ្ឌលេខ នស/រកម/០៧០៨/០២៤ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ១៧៩ កថាខណ្ឌ ១

ជាមួយនឹងកំណត់ហេតុយកចម្លើយនានាពីដំបូងគ្រប់ប្រភេទដូចជា៖ សាក្សី, ជនរងគ្រោះ, កំណត់ហេតុឃាត់ខ្លួន , កំណត់ហេតុឆែកឆេរ, កំណត់ហេតុចាប់យកវត្ថុ តាង និងកំណត់ហេតុសាកសួរជនល្មើសជាដើម។

### ២.៣.២ ឯកសារសំណេរនានា

ឯកសារសំណេរ គឺសំដៅភស្តុតាងដែលជាប្រភេទឯកសារទាំងឡាយណាដែលបានបញ្ជាក់នូវខ្លឹមសារច្បាស់លាស់ ដោយបានរក្សាទុកដូចប្រភេទនៃវត្ថុដែរ។ ឯកសារសំណេរទាំងនោះរួមមានដូចជា លិខិតបញ្ជាក់ផ្សេងៗរបស់ស្ថាប័ននានា ដែលមានលក្ខណៈបញ្ជាក់ទៅលើជនជាប់ចោទឬក៏លិខិតផ្សេងៗ ទៀតដែលពាក់ព័ន្ធទៅនឹងអត្តចរឹតរបស់ជនល្មើសដូចជាអត្តសញ្ញាណកម្មនានាជាដើម។ តាមខ្លឹមសារ ចំពោះឯកសារសំណេរដែលមានតម្លៃជាភស្តុតាងនៅក្នុងសំណុំរឿងព្រហ្មទណ្ឌវាមានភាពរឹងមាំខ្លាំងណាស់ ប្រសិនបើខ្លឹមសារនៃឯកសារសំណេរនោះមានអត្ថន័យដូចជាភស្តុតាងវត្ថុ។

## ២.៤ សេចក្តីពន្យល់ផ្ទាល់របស់ជនជាប់ចោទ

សេចក្តីពន្យល់ផ្ទាល់របស់ជនជាប់ចោទ ក៏ជាប្រភេទនៃភស្តុតាងមួយផងដែរ។ ភស្តុតាងប្រភេទនេះមានសារៈសំខាន់ណាស់ក្នុងការធ្វើសេចក្តីសម្រេច។ យោងតាមក្រមនីតិវិធីព្រហ្មទណ្ឌ ជនជាប់ចោទក៏បានកំណត់អំពីសិទ្ធិខ្លះដូចជា សិទ្ធិមិនឆ្លើយ, សិទ្ធិរកមេធាវីជាដើម។ល។ ការបំភ្លឺរបស់ជនជាប់ចោទ សំដៅការបំភ្លឺដែលធ្វើឡើងដោយជនជាប់ចោទឆ្លើយបំភ្លឺ អំពីពត៌មានទៅតាមអត្ថិភាពនៃប្រភេទរឿងក្តីដោយរៀបរាប់នូវអង្គហេតុនានាព្រមទាំងពិពណ៌នា អំពីអង្គហេតុឬអំពីព្រឹត្តិការណ៍នានាដែលជនល្មើសបានដឹង និងបានធ្វើដោយរៀបរាប់នូវរឿងរ៉ាវដែលបានកើតឡើងនោះមានសភាពយ៉ាងដូចម្តេច? តើជនជាប់ចោទរូបនេះបានធ្វើអ្វីខ្លះ? ហើយហេតុការណ៍អ្វីខ្លះបានកើតឡើង?។ល។

# ជំពូកទី ២
# នីតិវិធីនៃការស៊ើបអង្កេត
# ក្នុងរឿងព្រហ្មទណ្ឌ

# ជំពូកទី២

# នីតិវិធីនៃការស៊ើបអង្កេតក្នុងរឿងព្រហ្មទណ្ឌ

## ផ្នែក១៖ ការស៊ើបអង្កេតដោយមន្ត្រីនគរបាលយុត្តិធម៌

នៅក្នុងការស៊ើបអង្កេតស្វែងរកភស្តុតាងរបស់មន្ត្រីនគរបាលយុត្តិធម៌ ត្រូវបានចែកចេញជាពីរ គឺ**ទី១.** ការស៊ើបអង្កេតក្នុងករណីបទល្មើសជាក់ស្តែង និង**ទី២.** ការស៊ើបអង្កេតបឋម (ករណីបទល្មើសមិនជាក់ស្តែង) ។ នៅក្នុងច្បាប់បានកំណត់ផងដែរថាអំណាចទាំងឡាយដែលផ្តល់ឱ្យមន្ត្រីនគរបាលយុត្តិធម៌ខុសគ្នាទៅតាមតួនាទីដែលមន្ត្រីនោះបម្រើការនៅក្នុងក្របខណ្ឌនៃការស៊ើបអង្កេតបទល្មើសជាក់ស្តែង ឬក្នុងក្របខណ្ឌនៃការស៊ើបអង្កេតបឋម[24]។ តាមអត្ថន័យនេះផងដែរ អាចទាញបានថាក្នុងការស៊ើបអង្កេតទាំងពីរនេះ គឺមិនដូចគ្នាទេសូម្បីតែលក្ខខណ្ឌនៃការបើកការស៊ើបអង្កេត ក៏មិនដូចគ្នាទាំងអំណាចដែលប្រើប្រាស់ដោយមន្ត្រីនគរបាលយុត្តិធម៌ក្នុងក្របខណ្ឌនៃការស៊ើបអង្កេតនេះក៏ខុសគ្នាដែរ។ ដូចនេះ ដើម្បីបកស្រាយឱ្យកាន់តែច្បាស់ពាក់ព័ន្ធទៅនឹងការស៊ើបអង្កេតក្នុងករណីបទល្មើសជាក់ស្តែង និងករណីស៊ើបអង្កេតបឋម ក្រុមយើងខ្ញុំនឹងលើកយកចំណុចនីមួយៗមកវែកញែកពិភាក្សាដូចខាងក្រោម៖

### កថាខណ្ឌ១៖ ការស៊ើបអង្កេតបទល្មើសជាក់ស្តែងដោយមន្ត្រីនគរបាលយុត្តិធម៌

ជាគោលការណ៍ទូទៅ ក្នុងការស៊ើបអង្កេតបទល្មើសជាក់ស្តែងនេះ គឺអាចធ្វើទៅបានតែក្នុងករណីដែលជាបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែងតែប៉ុណ្ណោះ ចំពោះបទលហុវិញ គឺមិនត្រូវបានយកមកអនុវត្តឡើយ។ ដោយឡែកច្បាប់ក៏បានកំណត់ផងដែរថា បុគ្គលដែលមានសមត្ថកិច្ចក្នុងការដឹកនាំការស៊ើបអង្កេតនេះរួមមាន គឺមានព្រះរាជអាជ្ញានិងមន្ត្រីនគរបាលយុត្តិធម៌។ ចំណែកឯភ្នាក់ងារនគរបាលយុត្តិធម៌ មានអំណាចផ្ទាល់ដោយត្រឹមតែពិនិត្យកត់ត្រានូវបទឧក្រិដ្ឋ បទមជ្ឈឹមជាក់ស្តែង ក្នុងកំណត់ហេតុតែប៉ុណ្ណោះ។ ចំពោះកិច្ចស៊ើបអង្កេតភ្នាក់ងារនគរបាលយុត្តិធម៌ជួយមន្ត្រីនគរបាលយុត្តិធម៌ ឬបំពេញកិច្ចនេះក្រោមការត្រួតពិនិត្យរបស់នគរបាលយុត្តិធម៌។ ជាទូទៅចំពោះក្នុងករណីបទឧក្រិដ្ឋ ឬបទមជ្ឈឹមជាក់ស្តែង បុគ្គលណាក៏មានសិទ្ធិចាប់ខ្លួនជនសង្ស័យ និងនាំខ្លួនប្រគល់ឲ្យមន្ត្រីនគរបាលយុត្តិធម៌ដែលនៅជិតបំផុតបាន[25] ។

#### ១.១ លក្ខខណ្ឌករណីបទល្មើសជាក់ស្តែង

ចំពោះនីតិវិធីនៃការស៊ើបអង្កេតរបស់នគរបាលយុត្តិធម៌ ក្នុងករណីបទល្មើសជាក់ស្តែងមានច្រើនចំណុចសំខាន់ៗ ដែលយើងនឹងធ្វើការបកស្រាយ ប៉ុន្តែមុននឹងឈានទៅធ្វើការបកស្រាយឱ្យបានលម្អិតអំពីនីតិវិធីរបស់

[24] ក្រមនីតិវិធីព្រហ្មទណ្ឌលេខ នស/រកម/០៧០៨/០២៤ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ៨៤

[25] ក្រមនីតិវិធីព្រហ្មទណ្ឌលេខ នស/រកម/០៧០៨/០២៤ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ៨៧

នគរបាលយុត្តិធម៌ចំពោះការស៊ើបអង្កេតក្នុងករណីបទល្មើសជាក់ស្តែង គប្បីគួរយល់ឱ្យច្បាស់ជាមុនសិនថា តើអ្វីទៅជាបទល្មើសជាក់ស្តែង?

### ១.១.១ ការកំណត់ពីបទល្មើសជាក់ស្តែង

ជាគោលការណ៍ទូទៅ បន្ទាប់ពីមន្ត្រីនគរបាលយុត្តិធម៌ បានដឹងអំពីហេតុការណ៍ដែលបានកើតឡើង ហើយជាបឋមត្រូវកំណត់ និងវាយតម្លៃប្រភេទនៃបទល្មើសជាមុនសិន ថាតើជាបទល្មើសជាក់ស្តែង ឬ មិនមែនជាបទល្មើសជាក់ស្តែង? ដោយការស៊ើបអង្កេតជាសមត្ថកិច្ចរបស់មន្ត្រីនគរបាល ក៏ដូចជាភ្នាក់ងារនគរបាលយុត្តិធម៌ក្នុងការវាយតម្លៃអំពីអាទិភាពនៃលក្ខណៈជាក់ស្តែង មុននឹងអនុវត្តអំណាចរបស់ខ្លួនក្នុងការបើកការស៊ើបអង្កេតបទល្មើសជាក់ស្តែងនេះ បើពុំដូច្នេះទេ មន្ត្រីនគរបាលយុត្តិធម៌និងភ្នាក់ងារនគរបាលយុត្តិធម៌នោះនឹងត្រូវទទួលទោសព្រហ្មទណ្ឌ ទោសពិន័យ និងទោសរដ្ឋប្បវេណីព្រមទាំងត្រូវបានមោឃភាពនៃកិច្ចដែលបានបំពេញផងដែរ។ ក្នុងការពិនិត្យវាយតម្លៃនេះ ត្រូវអនុវត្តតាមប្បញ្ញត្តិនៃមាត្រា៨៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

ផ្ទុយទៅវិញ បើពុំបានរកឃើញស្ថានភាពជាក់ស្តែងដែលបានកំណត់ជាមុនទេ ភ្នាក់ងារដែលបើកការស៊ើបអង្កេតនោះនឹងគ្មានសមត្ថកិច្ច ហើយគ្រប់កិច្ចដែលបានបំពេញនឹងត្រូវចាត់ទុកជាមោឃភាពដោយស្វ័យប្រវត្តិ។ ក្នុងករណីនេះ មន្ត្រីនគរបាលយុត្តិធម៌អាចបើកជាមុននូវការស៊ើបអង្កេតបឋមជាមុនដើម្បីឈានដល់ការរកឃើញតម្រុយដែលអាចឲ្យសន្និដ្ឋានបានពីលក្ខណៈជាក់ស្តែង។ ពេលដែលការស៊ើបអង្កេតបឋមត្រូវបានបញ្ចប់ អ្នកស៊ើបអង្កេតអាចបើកការស៊ើបអង្កេតបទល្មើសជាក់ស្តែង ហើយការប្រមូលតម្រុយខាងក្រៅដែលអនុញ្ញាតឲ្យមានការកំណត់ពីស្ថានភាពជាក់ស្តែងដែលផ្អែកលើភាពជាក់ស្តែងដែលមានបញ្ញត្តិចែងក្នុងមាត្រា៨៦ និងមាត្រា៨៨[26] នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

ក្រមនីតិវិធីព្រហ្មទណ្ឌបានផ្តល់នូវមូលដ្ឋានចំនួន ០២ (ពីរ) សម្រាប់ធ្វើការពិនិត្យនិងកំណត់ស្ថានភាពដែលក្នុងនោះមន្ត្រីនគរបាលយុត្តិធម៌អាចប្រើប្រាស់នៅក្នុងស្ថានភាពនៃការស៊ើបអង្កេតជាក់ស្តែងបាន៖

- **ទីមួយ** យោងតាមមាត្រា ៨៦ បានផ្តល់ជានិយមន័យអំពីបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង ដោយមាត្រានេះបានចែងថា បទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង គឺស្ថិតនៅក្នុងសកម្មភាពដែលច្បាប់បានកំណត់រួមមាន៖
  - បទល្មើសដែលកំពុងប្រព្រឹត្ត
  - បទល្មើសដែលទើបប្រព្រឹត្តរួចភ្លាម
  - ត្រូវចាត់ទុកថាជាបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែងដែរ កាលណានៅក្រោយពេលមានបទល្មើសរួចបន្តិចមក
  - ជនដែលគេសង្ស័យ ត្រូវបានសាធារណៈជនស្រែកដេញប្រដាប់ចាប់ប្រដឹង
  - បុគ្គលដែលត្រូវគេរកឃើញថាមានវត្ថុ ឬស្លាកស្នាម ឬតម្រុយច្បាស់លាស់ហើយស៊ីសង្វាក់ផ្សេងទៀតដែលនាំឱ្យមានការសន្និដ្ឋានថា បុគ្គលនោះបានប្រព្រឹត្ត ឬបានចូលរួមប្រព្រឹត្តបទល្មើស។

[26] ក្រមនីតិវិធីព្រហ្មទណ្ឌលេខ នស/រកម/០៧០៨/០២៤ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០៧

ហេតុដូច្នេះហើយស្ថានភាពដែលមានដូចនៅក្នុងមាត្រា ៨៦ នេះគឺជាស្ថានភាពករណីបទល្មើសជាក់ស្ដែង។

នៅក្នុងករណីដែលបទល្មើសមួយ ប្រព្រឹត្តនៅក្នុងស្ថានភាពណាមួយនៃស្ថានភាពដែលបានចែងនៅក្នុងមាត្រា ៨៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ គឺក្នុងករណីនោះអាចទាញឱ្យមានការសន្និដ្ឋានបានថាជាបទល្មើសជាក់ស្ដែង ហើយមន្ត្រីនគរបាលយុត្តិធម៌អាចបើកការស៊ើបអង្កេតជាក់ស្ដែងបាន ។

- **ទីពីរ** យោងតាមមាត្រា ៨៨ (ការចាត់ទុកដូចជាបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្ដែង) នៃក្រមនីតិវិធីព្រហ្មទណ្ឌ ក៏ជាលក្ខខណ្ឌនៃការស៊ើបអង្កេតជាក់ស្ដែងដែរ ។ ដោយមាត្រានេះបានបញ្ញត្តិយ៉ាងច្បាស់ថាត្រូវបានចាត់ទុកដូចជាបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្ដែងផងដែរ បើទោះបីជាស្ថិតនៅក្រៅពីករណីដែលមានចែងក្នុងមាត្រា ៨៦ ខាងលើនេះក៏ដោយ គ្រប់បទឧក្រិដ្ឋ ឬបទមជ្ឈិមទាំងឡាយណាដែលត្រូវបានប្រព្រឹត្តនៅក្នុងទីកន្លែងដែលអ្នកកាន់កាប់នៅទីនោះ សុំឱ្យព្រះរាជអាជ្ញាឬមន្ត្រីនគរបាលយុត្តិធម៌ចូលមកពិនិត្យ ឬភ្នាក់ងារនគរបាលយុត្តិធម៌ក្នុងករណីដែលគ្មានអ្នកកាន់កាប់ទីកន្លែងនោះ ។ ម្យ៉ាងវិញទៀតក្នុងករណីចុងក្រោយនេះ ភ្នាក់ងារនគរបាលយុត្តិធម៌ត្រូវរាយការណ៍ជាបន្ទាន់ដល់មន្ត្រីនគរបាលយុត្តិធម៌។ <u>**ជាឧទាហរណ៍**</u> លោក **កក្កដា** ជាកសិករម្នាក់រស់នៅខេត្តកំពង់ចាម គាត់មានដីចំការជាច្រើនកន្លែងនៅក្នុងខេត្តកំពង់ចាម នៅដើមខែមករា មានឈ្មួញម្នាក់ឈ្មោះ **សីហា** រស់នៅរាជធានីភ្នំពេញចង់ទិញដីចំការរបស់គាត់ ។ លោក **កក្កដា** បានណាត់ លោក **សីហា** ដើម្បីទៅមើលដីចំការនោះទាំងអស់គ្នាលុះដល់ថ្ងៃកំណត់ពួកគាត់ទាំងពីរក៏បានទៅដីចំការនោះ។ ពេលទៅដល់ដីចំការ ក៏ស្រាប់តែប្រទះឃើញសាកសពបុរសម្នាក់បានស្លាប់នៅលើដីចំការរបស់លោក **កក្កដា** ដោយរូបគាត់មិនបានដឹងពីមូលហេតុអ្វីនោះឡើយ។ ក្នុងពេលភ្លាមៗនោះលោក **កក្កដា** ក៏បានទៅរាយការណ៍ដល់ភ្នាក់ងារមន្ត្រីនគរបាលយុត្តិធម៌អំពីបញ្ហានេះ បន្ទាប់ក្រោយមកភ្នាក់ងារមន្ត្រីនគរបាលយុត្តិធម៌ក៏បានរាយការណ៍យ៉ាងលឿនទៅមន្ត្រីនគរបាលយុត្តិធម៌ដែលជាប្រធានឋានានុក្រមរបស់ខ្លួន។ បន្ទាប់ពីបានទទួលនូវការរាយការណ៍អំពីអង្គហេតុនេះរួចហើយ មន្ត្រីនគរបាលយុត្តិធម៌ ក៏បានចុះមកពិនិត្យ និងធ្វើការឆែកឆេរនៅចំណុចដីចំការរបស់លោក **កក្កដា** តែម្ដង ។ នៅក្នុងករណីនេះ ជាការពិតពីដំបូង គឺយើងឃើញថាជាបទល្មើសមិនជាក់ស្ដែងក៏ពិតមែន ប៉ុន្តែដោយសារតែសកម្មភាពនោះបានគោរពនូវលក្ខខណ្ឌនៃមាត្រា ៨៨ ត្រង់ចំណុចថាលោក **កក្កដា** ដែលជាម្ចាស់កាន់កាប់ដីចំការកើតហេតុខាងលើបានសុំស្នើឱ្យភ្នាក់ងារមន្ត្រីនគរបាលយុត្តិធម៌ចូលមកពិនិត្យ ហើយភ្នាក់ងារគាត់បានបំពេញដូចលក្ខខណ្ឌក្នុងវាក្យខណ្ឌចុងក្រោយនៃមាត្រា ៨៨ ។ ដូច្នេះករណីនេះ យើងអាចសន្និដ្ឋានបានថាវាជាបទល្មើសជាក់ស្ដែងស្របតាមមាត្រា ៨៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ និយាយជារួមយើងអាចទាញបានថា លក្ខខណ្ឌនៃការបើកការស៊ើបអង្កេតជាក់ស្ដែងមាន ២ គឺ៖ ទីមួយ គឺបទល្មើសជាក់ស្ដែងដែលមានចែងនៅក្នុងមាត្រា ៨៦ និងទីពីរគឺការចាត់ទុកដូចជាបទល្មើសជាក់ស្ដែងដែលមានចែងនៅក្នុងមាត្រា ៨៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

ដោយឡែកចំណុចបន្ទាប់ យើងខ្ញុំនឹងធ្វើការបកស្រាយតាមផ្នែកនីមួយៗ ដែលត្រូវបានចាត់ទុកជាស្ថានភាពជាក់ស្ដែងផងដែលមានដូចខាងក្រោម៖

### ១.១.២ បទល្មើសកំពុងប្រព្រឹត្ត

បទល្មើសដែលកំពុងប្រព្រឹត្ត សំដៅដល់ករណីនៃបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង ដែលចារីកំពុងតែប្រព្រឹត្តដោយពុំមានការកាត់ផ្តាច់សកម្មភាពនោះ ពោលគឺមានន័យថាស្ថានភាពជាក់ស្តែងដែល ចារីត្រូវបានគេឃើញទាន់ក្នុងអំពើសកម្ម ឬអកម្មនោះ។ ដោយឡែកក៏មានបទល្មើសផ្សេងទៀតផងដែរ ដែលមិនបង្ហាញឲ្យឃើញផ្ទាល់តែការទទួលបានតម្រុយត្រូវតែធ្វើឡើងតាមគន្លងច្បាប់។ **ឧទាហរណ៍៖** កន្លែងពិសោធន៍ផលិតគ្រឿងញៀនគេត្រូវបើកការស៊ើបអង្កេតបឋមជាមុនសិន ដើម្បីអាចរកឃើញតម្រុយជាវត្ថុដែលអនុញ្ញាតឲ្យបើកការស៊ើបអង្កេតបទល្មើសជាក់ស្តែង។ ក្នុងករណី ការជួញដូរគ្រឿងញៀន បន្ទាប់ពីទទួលបានភស្តុតាងជាក់ស្តែងដោយការតាមដានមន្ត្រីនគរបាលយុត្តិធម៌អាចបើកការឆែកឆេរ មន្ទីរពិសោធន៍ជាក់លាក់ ក្នុងក្របខណ្ឌការស៊ើបអង្កេតជាក់ស្តែង។ នេះសបញ្ជាក់ថា បើពុំមានតម្រុយពីខាងក្រៅ ចំពោះការសង្ស័យ និងការបរិហារ មិនត្រូវបានរាប់បញ្ចូលក្នុងលក្ខខណ្ឌដែលត្រូវបានទាមទារថាជាបទល្មើសជាក់ស្តែងឡើយ[27]។ ប៉ុន្តែក្នុងករណី ដែលមានការប្តឹងបរិហារពីសំណាក់ជនរងគ្រោះ អាចចាត់ទុកជាភស្តុតាងជាក់ស្តែងបាន។

### ១.១.៣ បទល្មើសដែលទើបប្រព្រឹត្តរួចភ្លាម

បទល្មើសដែលទើបប្រព្រឹត្តរួចភ្លាម សំដៅដល់ករណីនៃបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែងទាំងឡាយណាដែលចារីបានប្រព្រឹត្តហើយភ្លាមត្រូវបានបកស្រាយទៅលើការយល់ឃើញរបស់សង្គមតាមរយៈការវាយតម្លៃដោយចៅក្រម។ ឧទាហរណ៍៖ មានគេឃើញជនសង្ស័យនៅកន្លែងកើតហេតុក្រោយពីការប្រព្រឹត្តរួចបន្តិចមក។ ដើម្បីឱ្យកាន់តែងាយស្រួលយល់ជាងនេះទៅទៀត **<u>ជាឧទាហរណ៍៖</u>** បទល្មើសដែលបានប្រព្រឹត្តរួចភ្លាមៗនេះគឺដូចជាមានការបាញ់សម្លាប់ជនណាម្នាក់ ដែលចារីបានប្រព្រឹត្តសកម្មភាពនៅហ្នឹងកន្លែងតែម្តង ដូចនេះពេលដែលចារីបាញ់ជនរងគ្រោះរួចហើយ គឺបទល្មើសបានកើតមានឡើងម្យ៉ាងទៀតជននោះមានវត្តមាននៅនឹងកន្លែងកើតហេតុ នេះអាចចាត់ទុកថា ជាស្ថានភាពដែលទើបតែប្រព្រឹត្តរួចភ្លាម ។

### ១.១.៤ ការបន្សល់ទុកនូវតម្រុយលើជនសង្ស័យ

ជនសង្ស័យត្រូវបានគេប្រទះឃើញ ក្រោយការប្រព្រឹត្តបន្តិចថាមានកាន់កាប់វត្ថុ,អាវុធឬតម្រុយផ្សេងៗដែលនាំឲ្យគេសន្និដ្ឋានថាជននោះបានប្រព្រឹត្តបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែងណាមួយ។ **ឧទាហរណ៍៖** ការប្រទះស្នាមឈាមនៅទីកន្លែងណាមួយ ចំពោះស្ថានភាពជាក់ស្តែងបែបនេះអាចត្រូវបានស្តែងចេញនៅក្នុងករណីដែលកំពុងតែមានការត្រួតពិនិត្យចរាចរណ៍ នគរបាលបានប្រទះឃើញមានស្នាមឈាម ក្លិនអាភៀន ក្លិនរំសេវដែលជាប់ក្នុងរថយន្ត និងចេញពីរថយន្តជាដើម។

[27] ក្រមនីតិវិធីព្រហ្មទណ្ឌលេខ នស/រកម/០៧០៨/០២៤ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ៨៦

លើសពីនេះទៅទៀត ប្រសិនបើធ្វើការក្រឡេកទៅមើលមាត្រា ១៨ នៃច្បាប់ព្រហ្មទណ្ឌសម័យអន្តរកាល បានបញ្ញត្តិថា បើជនសង្ស័យត្រូវបានសាក្សី ឬជនរងគ្រោះចង្អុលបង្ហាញនៅនឹងកន្លែងប្រព្រឹត្តឧក្រិដ្ឋកម្ម ឬបទល្មើសថាជាឧក្រិដ្ឋជន មានន័យថា ជនម្នាក់នោះទើបតែប្រព្រឹត្តបទល្មើសរួចបន្តិចមកហើយជននោះ ស្ថិតនៅក្នុងហ្វូងមហាជនដែលកំពុងចោមរោម ចំណែកឯជនរងគ្រោះ ឬសាក្សីដែលបានឃើញចង្អុលប្រាប់ថាម្នាក់នឹង គឺជាអ្នកប្រព្រឹត្តបទល្មើស បទឧក្រិដ្ឋឬបទមជ្ឈិមជាក់ស្តែង។ ស្ថានភាពមួយទៀតដែលមាត្រា ១៨ (ច្បាបអ៊ុនតាក់) បានបញ្ជាក់ថា បើជនសង្ស័យនោះរកវិធីរត់គេចពីទីកន្លែងប្រព្រឹត្តបទល្មើស។ ដូចច្នេះក្រោយពេលដែលប្រព្រឹត្តរួចបន្តិចមក គឺជននោះបានរកវិធីគេចខ្លួន ហើយនៅពេលដែលគាត់រកវិធីគេចខ្លួននោះ ក្នុងស្ថានភាពច្បាប់បានចែងថាជាប្រភេទនៃស្ថានភាពដែលស្ថិតនៅក្នុងមាត្រា ៨៦ មានន័យថា ជាបទល្មើសជាក់ស្តែង ។

### ១.១.៥ ជនសង្ស័យត្រូវបានសាធារណៈជនស្រែកដេញប្រដាប់ចាប់ប្រភីង

សំដៅដល់ការស្រែកដេញប្រកិត ពីសំណាក់សាធារណៈជនតាមចាប់ពីជនសង្ស័យណាមួយដោយមានការបញ្ជាក់បង្ហាញភ្លាមៗ ថាបុគ្គលម្នាក់នោះ បានប្រព្រឹត្តអំពើដែលប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ។ ការស្រែកប្រកូកប្រកាសជាសាធារណៈ ត្រូវធ្វើឡើងក្នុងរយៈពេលណាមួយដែលនៅជិតការប្រព្រឹត្តបំផុត។ នៅក្នុងមាត្រា ៨៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ក៏បានបញ្ជាក់ផងដែរថាត្រូវចាត់ទុកជាបទល្មើសសជាក់ស្តែងផងដែរគឺពេលដែលជនសង្ស័យត្រូវបានសាធារណៈជនស្រែកដេញប្រដាប់ចាប់ប្រភីង ហើយន័យនេះនៅក្នុងវចនានុក្រមខ្មែររបស់ **សម្តេចព្រះសង្ឃរាជ ជួន ណាត** បានបញ្ជាក់យ៉ាងច្បាស់ថាពាក្យ "**ដេញប្រដាប់ចាប់ប្រភីង**" មានន័យថា គឺសំដៅទៅដល់ការដេញយ៉ាងប្រកិត ហើយចាប់បានជនល្មើសនោះបានតែម្តង ដូច្នេះស្ថានភាពនេះ វាគឺបានបង្ហាញយ៉ាងជាក់ស្តែង និងបញ្ជាក់យ៉ាងច្បាស់ថាក្នុងករណីនេះ គឺ បុគ្គលដែលត្រូវបានគេរកឃើញថាមានវត្ថុឬមានស្លាកស្នាម ឬមានតម្រុយយ៉ាងច្បាស់លាស់ហើយស៊ីសង្វាក់ផ្សេងទៀតដែលនាំឱ្យគេ សន្និដ្ឋានបានថាបុគ្គលនោះបានប្រព្រឹត្ត ឬបានចូលរួមប្រព្រឹត្តបទល្មើស។ **ជាឧទាហរណ៍៖** នាថ្ងៃទី ០១ ខែមករា ឆ្នាំ២០២១ វេលាម៉ោងប្រមាណ ២១ និង ៣០ នាទី នៅគល់ស្ពាន ឧកញ៉ា លីយ៉ុងផាត់ ត្រើយខាងកើត សង្កាត់ព្រែកតាសេកខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ មានករណីឃាតកម្មមួយបានកើតឡើង ភ្លាមនោះក៏មានប្រជាពលរដ្ឋដែលស្ថិតនៅក្នុងហេតុការណ៍នោះបានរាយការណ៍មកមន្ត្រីនគរបាលយុត្តិធម៌ជួយអន្តរាគមន៍ភ្លាមៗ ដោយភ្លាមនោះក៏ឃើញមានមន្ត្រីជំនាញខាងកោសល្យវិច័យធ្វើការត្រួតពិនិត្យនៅកន្លែងកើតហេតុ និងសាកសពជនរងគ្រោះឃើញមានស្នាមផ្ទុះដោយសារផ្លែកាំបិតជាច្រើនកន្លែង និងមានឈាមប្រឡាក់ដាបពាសពេញផ្លូវថ្នល់ បន្ទាប់ពីក្រោយពេលពិនិត្យរួចហើយមន្ត្រីនគរបាលយុត្តិធម៌ កងរាជអាវុធហត្ថ បានចាប់ផ្តើមបើកការស៊ើបអង្កេតក្នុងករណីជាក់ស្តែងតែម្តង។ ខណៈពេលនោះ ស្រាប់តែមានជនគួរឱ្យសង្ស័យម្នាក់មានកាំបិតនៅក្នុងដៃ ហើយអាវប្រឡាក់សុទ្ធតែឈាមផងដែរ បានរត់ចេញពីកន្លែងកើតហេតុ ចូលទៅក្នុងព្រៃជិតកន្លែងកើតហេតុ ក្នុងពេលភ្លាមនោះ ក៏មានប្រជាពលរដ្ឋបានជួយដេញប្រដាប់ចាប់ប្រជីងជនល្មើសនោះបញ្ជូនឱ្យកម្លាំងជំនាញមន្ត្រីនគរបាលយុត្តិធម៌ដើម្បីបន្តនីតិវិធីបន្តក្នុងករណីឃាតកម្មនេះ ។ សរុបមក ដោយសារតែជនដែលប្រព្រឹត្តបទល្មើសនេះនៅ

ទីកន្លែងដែលកំពុងកើតហេតុនោះស្រាប់ ហើយមានភាពស៊ីចង្វាក់គ្នាក្នុងស្ថានភាពដែលអាចសន្និដ្ឋានបានថាជននោះបានប្រព្រឹត្តបទល្មើសដែលចូលទៅក្នុងករណីបទល្មើសជាក់ស្តែង ។

**កំណត់ចំណាំ** មាត្រា៨៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ គឺចែងចំពោះតែបទឧក្រិដ្ឋឬបទមជ្ឈិមជាក់ស្តែងតែប៉ុណ្ណោះ ដូច្នេះមិនអាយកមាត្រានេះ មកប្រើប្រាស់ចំពោះបទលហុជាក់ស្តែងឡើយ[28] ។

### ១.១.៦ ការចាត់ទុកជាបទល្មើសជាក់ស្តែង

ក្នុងករណីមួយទៀត ការចាត់ទុកដូចជាបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែងដែរ គឺកាលណាមានបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែងប្រព្រឹត្តនៅក្នុងទីកន្លែងដែលមានអ្នកកាន់កាប់នៅ ដែលទីកន្លែងនោះសុំឲ្យព្រះរាជអាជ្ញាឬមន្ត្រីនគរបាលយុត្តិធម៌ចូលមកពិនិត្យ ឬភ្នាក់ងារនគរបាលយុត្តិធម៌ចូលមកពិនិត្យ[29] ។ **ឧទាហរណ៍**៖ ការលួចដោយមានការទម្លាយសោរ ដែលកម្មសិទ្ធិករ ឬអ្នកកាន់កាប់ផ្ទះបានឃើញនៅពេលត្រឡប់មកដល់ផ្ទះ ដោយសភាពខាងក្នុងមានភាពរញ៉េរញ៉ៃហាក់បីដូចជាមានការស្វែងរកវត្ថុមានតម្លៃ ដូចជាមានការគាស់ទូរ រើសំលៀកបំពាក់ដែលការប្រព្រឹត្តនិងការបន្សល់ទុកនៅភស្តុតាងដែលគ្មានអ្នកណាដឹង ដែលការលួចនេះអាចត្រូវបានប្រព្រឹត្តច្រើនថ្ងៃមុននឹងការពិនិត្យឃើញ ប៉ុន្តែការស្នើសុំរបស់ម្ចាស់ផ្ទះ ឬអ្នកកាន់កាប់ផ្ទះ មានអានុភាពប្រគល់អំណាចក្នុងការស៊ើបអង្កេតបទល្មើសជាក់ស្តែងឲ្យទៅមន្ត្រីនគរបាលយុត្តិធម៌ដែលជាអ្នកទទួលបណ្តឹងដោយផ្ទាល់ ឬតាមរយៈព្រះរាជអាជ្ញាក្នុងករណីដែលព្រះរាជអាជ្ញាជាអ្នកដែលបានស្នើសុំ។

## ១.២ វិធានពាក់ព័ន្ធនឹងទីកន្លែងកើតហេតុ

### ១.២.១ ការចុះទៅទីកន្លែងកើតហេតុ

ជាគោលការណ៍ នៅក្នុងការស៊ើបអង្កេតបទល្មើសជាក់ស្តែងនេះ មន្ត្រីនគរបាលយុត្តិធម៌មាន កាតព្វកិច្ចត្រូវរាយការណ៍ជូនទៅព្រះរាជអាជ្ញាក្នុងករណីបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង ដើម្បីចុះទៅកន្លែងកើតហេតុ និងធ្វើការពិនិត្យបទល្មើស។

មន្ត្រីនគរបាលយុត្តិធម៌ ត្រូវចុះទៅកាន់ទីកន្លែងកើតហេតុផ្ទាល់តែម្តងសម្រាប់កិច្ចការមួយចំនួនដែលមន្ត្រីនគរបាលយុត្តិធម៌ត្រូវបំពេញរួមមាន៖

- ឡោមព័ទ្ធទីកន្លែងកើតហេតុ ព្រមទាំងកំណត់ទំហំនៃកន្លែងកើតហេតុ
- អង្កេតពិពណ៌នាធ្វើកំណត់ហេតុ និងពិនិត្យកន្លែងកើតហេតុ
- ផ្តិតយករូបភាពគ្រប់ចំណុច

[28] យោងតាមប្រសាសន៍របស់មេធាវី គី ប៊ុនទ្រាន សមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងពេលផ្តល់បទសម្ភាសន៍
[29] ក្រមនីតិវិធីព្រហ្មទណ្ឌលេខ នស/រកម/០៧០៨/០២៤ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ៨៨

- ស្វែងរកសាក្សី រក្សាទុកសាក្សី ព្រមធ្វើការសាកសួរសាក្សី (បើមាន)
- ការពារភស្តុតាងដើម្បីប្រមូលឲ្យបានអស់
- ឃាត់ខ្លួនជនសង្ស័យប្រសិនបើមាននៅនឹងកន្លែងកើតហេតុ និងរក្សាសុវត្ថិភាពជនល្មើស
- សួរចម្លើយជនសង្ស័យ
- ធ្វើកំណត់ហេតុអំពីការស៊ើបអង្កេត។

### ១.២.២ ការធ្វើកំណត់ហេតុរបស់មន្ត្រីនគរបាលយុត្តិធម៌

ការធ្វើកំណត់ហេតុរបស់មន្ត្រីនគរបាលយុត្តិធម៌ត្រូវបានបែងចែកដូចតទៅ៖

**កំណត់ហេតុពិនិត្យកន្លែងកើតហេតុ៖** ត្រូវកត់ត្រានូវពត៌មានផ្សេងៗដូចជា ពិនិត្យកន្លែងកើតហេតុមានការប្រែប្រួលនូវស្ថានភាពដើម ឬយ៉ាងណា។ ក្នុងករណីមានការប្រែប្រួលត្រូវកត់ត្រាចំណុចដែលប្រែប្រួលនោះមានអ្វីខ្លះ។ ត្រូវកត់ត្រានូវពេលវេលាពិនិត្យវត្តមានអ្នកដែលបានចូលរួមពិនិត្យ ព្រមទាំងពិនិត្យដោយយកចិត្តទុកដាក់នូវរាល់សកម្មភាពទាំងឡាយ ដែលកើតឡើងនៅកន្លែងកើតហេតុឲ្យបានច្បាស់លាស់និងតាមលំដាប់លំដោយ។

**កំណត់ហេតុពិនិត្យសាកសព៖** ពិនិត្យស្លាកស្នាមសាកសព ស្ថានភាពនៃការស្លាប់និងអត្តសញ្ញាណសាកសព ឆែកឆេរសំលៀកបំពាក់សាកសព ព្រមទាំងធ្វើកំណត់ហេតុដកហូតបើមានលទ្ធភាពត្រូវធ្វើការប៉ាន់ស្មានថាសាកសពស្លាប់នៅពេលណា និង មូលហេតុអ្វី?

**កំណត់ហេតុពិនិត្យរបួសស្នាមជនរងគ្រោះ ឬជនសង្ស័យ៖** ពិនិត្យកត់ត្រាស្លាកស្នាមរបួសដែលមានរបស់ ជនរងគ្រោះ ឬជនសង្ស័យ (បើមាន)។

**គូសគំនូសប្លង់នៅនឹងកន្លែងកើតហេតុ៖** ត្រូវពិនិត្យ និងគូសគំនូសប្លង់នៅនឹងកន្លែងកើតហេតុផ្ទាល់។

**ផ្តិតយករូបភាព៖** ត្រូវថតយកគ្រប់ទិដ្ឋភាព គ្រប់កន្លែងនៃកន្លែងកើតហេតុយ៉ាងល្អិតល្អន់បំផុតពិសេសគឺសាកសព របួស ស្នាមសាកសពទាំងមូល មុនរំកិល និងក្រោយពេលរំកិល។

ដើម្បីឲ្យបណ្តាលភារកិច្ចដូចមានខាងលើ ប្រព្រឹត្តទៅទទួលបានល្អត្រូវមានវិធានការឲ្យបានម៉ឺងម៉ាត់នឹងហាមឃាត់ចំពោះការចេញចូលកន្លែងកើតហេតុចំពោះអ្នកដែលគ្មានសិទ្ធិអនុញ្ញាត ទោះបីជាកម្លាំងនគរបាលកងរាជអាវុធហត្ថ អ្នកសារពត៌មាន អង្គការក្រៅរដ្ឋាភិបាល។ល។

## កថាខណ្ឌ២ ការស៊ើបអង្កេតបឋម ដោយមន្ត្រីនគរបាលយុត្តិធម៌

ជាគោលការណ៍បទល្មើសទាំងអស់ អាចជាកម្មវត្ថុនៃនីតិវិធីទាក់ទងនឹងរបៀបស៊ើបអង្កេតបឋមលើកលែងតែករណីដែលបទល្មើសទាំងនោះ តម្រូវឲ្យមានការបើកការស៊ើបអង្កេតពីតុលាការដឹកនាំដោយចៅក្រម

ស៊ើបសួរ។ ពោលគឺការស៊ើបអង្កេតបឋម គឺជាការស៊ើបអង្កេតធម្មតាដែលនគរបាលយុត្តិធម៌ពិនិត្យកត់ត្រាបទល្មើស និងស្វែងរកអ្នកប្រព្រឹត្តនៅពេលដែលពុំមានការបើកការស៊ើបសួរ ឬនៅពេលដែលអ្នកស៊ើបអង្កេតមិនអាចធ្វើការស៊ើបអង្កេតបទល្មើសជាក់ស្តែង។

## ២.១ បុព្វហេតុនៃការស៊ើបអង្កេត

ការស៊ើបអង្កេតបឋម គឺជានីតិវិធីមួយដែលមានទម្រង់សាមញ្ញប៉ុន្តែផ្តល់ឲ្យអ្នកស៊ើបអង្កេតនូវអំណាចមួយដែលមានកម្រិត។ បើគ្មានការស៊ើបអង្កេតបឋមទេ ការស៊ើបអង្កេតដូចជាមានកម្រិត ព្រោះថាមន្ត្រីនគរបាលយុត្តិធម៌ដែលដឹងអំពីហេតុការណ៍ដែលមិនមែនជាបទឧក្រិដ្ឋ ឬបទមជ្ឈឹមជាក់ស្តែង ត្រូវតែជូនដំណឹងទៅព្រះរាជអាជ្ញាភ្លាម ដោយព្រះរាជអាជ្ញាទាមទារឲ្យមានការស៊ើនអង្កេតមួយ ដែលនាំឲ្យមានការចេញដីកាចាត់ឲ្យស៊ើបសួរជំនួស ឬចេញដីកាតម្កល់សំណុំរឿងទុកមិនចាត់ការអាស្រ័យតាមភាពធ្ងន់ធ្ងរនៃបទល្មើស។ ក្នុងករណីបទល្មើសមិនជាក់ស្តែង កាលណាបានដឹងពីអំពើដែលអាចជាបទល្មើសឧក្រិដ្ឋ ឬបទមជ្ឈិម ឬបទលហុ មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការស៊ើបអង្កេតបឋមដោយឯង ឬតាមការស្នើសុំរបស់ព្រះរាជអាជ្ញា[30] ។

## ២.២ វិធានអនុវត្តចំពោះការស៊ើបអង្កេតបឋម

ការស៊ើបអង្កេតបឋមនេះ ត្រូវគោរពតាមវិធានដែលមានចែងក្នុងបទប្បញ្ញត្តិនៃមាត្រាដូចខាងក្រោម[31] ៖

- មាត្រា ៩០ (កំណត់ហេតុលើការស្រាវជ្រាវ និងការពិនិត្យ)
- មាត្រា ៩៥ (ការត្រួតពិនិត្យខាងផ្នែកបច្ចេកទេស ឬវិទ្យាសាស្ត្រ)
- មាត្រា ១០៥ (ការហាមឃាត់មិនឲ្យស្តាប់ដោយឯកឯងជាអាទិ៍)
- មាត្រា ១០៧ (ការបញ្ជូនកំណត់ហេតុទៅព្រះរាជអាជ្ញា)
- មាត្រា ១០៨ (និទ្ទេសដែលត្រូវចុះក្នុងកំណត់ហេតុ)។

ដែលប្បញ្ញត្តិនៃមាត្រាដូចដែលមានចែងខាងលើនៃក្រមនីតិវិធីព្រហ្មទណ្ឌ នេះត្រូវយកមកអនុវត្តនៅក្នុងការស៊ើបអង្កេតបឋមនេះ។

## កថាខណ្ឌ៣ ដីកាចាត់ឲ្យស៊ើបសួរជំនួស

សំរាប់ដីកាចាត់ឱ្យស៊ើបសួរជំនួស ក្នុងចំណោមនគរបាលនិងក្រុមអាវុធហត្ថ មានតែមន្ត្រីនគរបាលយុត្តិធម៌ទេដែលអាចទទួលការកិច្ចឲ្យស៊ើបសួរជំនួសរបស់ចៅក្រមស៊ើបសួរបាន ដូច្នេះតើដីកាចាត់ឲ្យស៊ើបសួរជំនួសជាដីកាអ្វី? តើចៅក្រមស៊ើបសួរ ចេញដីកានេះដើម្បីអ្វី? ។

---

[30] ក្រមនីតិវិធីព្រហ្មទណ្ឌលេខ នស/រកម/០៧០៨/០២៤ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ១១១

[31] ក្រមនីតិវិធីព្រហ្មទណ្ឌលេខ នស/រកម/០៧០៨/០២៤ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ១១២

### ៣.១ អត្ថន័យដីកាចាត់ឲ្យស៊ើបសួរជំនួស

ដីកាចាត់ឲ្យស៊ើបសួរជំនួស ជាប្រតិភូកម្មនៃអំណាចដែលចៅក្រមស៊ើបសួរប្រគល់ឲ្យចៅក្រមផ្សេងឬមន្ត្រីនគរបាលយុត្តិធម៌ ឬអង្គភាពនគរបាល ដើម្បីអនុវត្តកិច្ចស៊ើបសួរមួយ ឬច្រើន ដែលកំណត់បានក្នុងដីកាចាត់ឲ្យស៊ើបសួរជំនួស។ ដីកាចាត់ឲ្យស៊ើបសួរជំនួស ត្រូវបញ្ជាក់អំពីប្រភេទនៃកិច្ចដែលត្រូវធ្វើហើយកិច្ចនោះត្រូវតែមានទំនាក់ទំនងដោយផ្ទាល់ជាមួយបទល្មើសដែលចោទប្រកាន់ ហើយមិនអាច មានលក្ខណៈជាទូទៅទេគឺត្រូវណែនាំឲ្យបានច្បាស់[32] ។ ក្នុងដីកាចាត់ឲ្យស៊ើបសួរជំនួស ចៅក្រមស៊ើបសួរត្រូវ៖

- បញ្ជាក់អំពីកិច្ចដែលត្រូវធ្វើ
- កំណត់ថិរវេលាដែលត្រូវអនុវត្តដីកាចាត់ឲ្យស៊ើបសួរជំនួស
- ត្រូវចុះកាលបរិច្ឆេទ ចុះហត្ថលេខាដោយចៅក្រមស៊ើបសួរ និងមានបោះត្រាផង ។

ចំពោះដីកាចាត់ឱ្យស៊ើបសួរជំនួស ចៅក្រមស៊ើបសួរ អាចបញ្ឈប់ដីកាចាត់ឲ្យស៊ើបសួរជំនួសបានគ្រប់ពេលវេលា និងមុនពេល ដែលការអនុវត្តដីកានេះត្រូវបញ្ចប់។

### ៣.២ ដីកាចាត់ឲ្យស៊ើបសួរជំនួសចេញឲ្យមន្ត្រីនគរបាលយុត្តិធម៌

ដូចដែលបានរៀបរាប់ខាងលើ ក្នុងចំណោមនគរបាលនិងកងរាជអាវុធហត្ថ មានតែមន្ត្រីនគរបាលយុត្តិធម៌ ប៉ុណ្ណោះដែលអាចទទួលការផ្ទេរនូវសិទ្ធិបែបនេះ។ ចៅក្រមស៊ើបសួរ អាចចាត់តាំងមន្ត្រីនគរបាលយុត្តិធម៌ដែលមានក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ព្រមទាំងគ្រប់មន្ត្រីនគរបាលយុត្តិធម៌លើដែនដីប្រទេសទាំងមូល។ មន្ត្រីនគរបាលយុត្តិធម៌នេះ ត្រូវស្ថិតនៅក្រោមអំណាចផ្ទាល់ របស់ចៅក្រមស៊ើបសួរក្នុងក្របខណ្ឌនៃការអនុវត្តដីកាចាត់ឲ្យស៊ើបសួរជំនួសហើយត្រូវរាយការណ៍ជូនចៅក្រមស៊ើបសួរនេះតែប៉ុណ្ណោះ[33]។ ជាគោលការណ៍ចៅក្រមស៊ើបសួរមិនអាចផ្ទេរអំណាចទាំងអស់របស់ខ្លួនបានទេ។ អំណាច ដែលមិនអាចត្រូវបានផ្ទេរទៅឲ្យមន្ត្រីមគរបាលយុត្តិធម៌ គឺជាអំណាចចោទប្រកាន់បុគ្គលណាម្នាក់ អំណាចសួរចម្លើយជនត្រូវចោទ ឬស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី អំណាចសួរតទល់បុគ្គលខាងលើជាមួយនឹងមនុស្សផ្សេងទៀតឬអំណាចចេញដីកាឬធ្វើការឆែកឆេរក្នុងកន្លែងដែលការពារ។ អំណាចដែលចៅក្រមស៊ើបសួរអាចផ្ទេរបានទៅមន្ត្រីនគរបាលយុត្តធម៌រួមមាន៖

- ការស្តាប់ចម្លើយសាក្សី បើនៅក្នុងពេលស្តាប់ចម្លើយ មានលេចចេញនូវតម្រុយពិរុទ្ធភាពប្រឆាំងនឹងសាក្សី ការស្តាប់ចម្លើយត្រូវបញ្ចប់ ដើម្បីឲ្យមន្ត្រីនគរបាលយុត្តិធម៌ផ្តល់ ដំណឹងភ្លាមទៅចៅ ក្រមស៊ើបសួរ។
- ការឆែកឆេរ និងការចាប់យកវត្ថុ (មាត្រា ១៨១នៃក្រមនីតិវិធីព្រហ្មទណ្ឌ)

[32] ក្រមនីតិវិធីព្រហ្មទណ្ឌលេខ នស/រកម/០៧០៨/០២៤ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ១៧៤

[33] ក្រមនីតិវិធីព្រហ្មទណ្ឌលេខ នស/រកម/០៧០៨/០២៤ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ១៧៦

- ការឃាត់ខ្លួន អំណាចត្រួតពិនិត្យដែលធ្វើដោយព្រះរាជអាជ្ញាក្នុងក្របខ័ណ្ឌនៃដីកាចាត់ឲ្យស៊ើបសួរជំនួស។ នៅពេលដែលផុតវិធាននេះ បុគ្គលត្រូវបង្ហាញខ្លួននៅចំពោះមុខចៅក្រមស៊ើបសួរ (មាត្រា ១៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ) ។
- ការស្តាប់ទូរស័ព្ទ ចំពោះការស្តាប់ និងការថតចម្លងការសន្ទនាតាមទូរស័ព្ទ និងការចាប់ការឆ្លើយឆ្លងតាមមធ្យោបាយទូរគមនាគមន៍ ជាការពិតណាស់ដែលនឹងត្រូវប្រគល់ទៅឲ្យចៅក្រមស៊ើបសួរដើម្បីបញ្ចូលក្នុងសំណុំរឿងនៅពេលដែលកិច្ចត្រូវបានបំពេញចប់[34] ។

## ផ្នែក២ វិធានស្រាវជ្រាវក្នុងករណីបទល្មើសជាក់ស្តែង និងការស៊ើបអង្កេតបឋម

### កថាខណ្ឌ១ ការឆែកឆេរ

### ១.១ ករណីបទល្មើសជាក់ស្តែង

ក្នុងករណីបទល្មើសជាក់ស្តែងមុននឹងអាចធ្វើការឆែកឆេរ មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការឆែកឆេរបានតែក្នុងករណី ដែលទទួលបានការអនុញ្ញាតជាបឋមពីព្រះរាជអាជ្ញា ទោះបីការអនុញ្ញាតនោះដោយផ្ទាល់មាត់ក៏ដោយ[35]ជាគោលការណ៍ការឆែកឆេរត្រូវធ្វើនៅចំពោះមុខអ្នកកាន់កាប់ទីកន្លែង ឬបើគ្មានអ្នកណាកាន់កាប់ទីកន្លែងទេ ត្រូវធ្វើចំពោះមុខសាក្សីពីរនាក់ ដែលសាក្សីត្រូវចាត់តាំងដោយមន្ត្រីនគរបាលយុត្តិធម៌។ សម្គាល់គឺសាក្សីមិនអាចជានគរបាល ឬក៏កងរាជអាវុធហត្ថ ដែលជា កម្លាំងរួមប្រតិបត្តិការក្នុងការឆែកឆេរនោះទេ។ មន្ត្រីនគរបាលយុត្តិធម៌មិនអាចធ្វើការឆែកឆេរនៅមុនម៉ោង៦ (ប្រាំមួយ) ព្រឹក និងក្រោយម៉ោង ១៨ (ដប់ប្រាំបី) ល្ងាចឡើយលើកលែងតែៈ

- ក្នុងករណីដែលមានចែងដោយមាត្រា ៨៦ (និយមន័យបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង) នៃក្រមនីតិវិធីព្រហ្មទណ្ឌ
- ក្នុងករណីដែលមានចែងដោយមាត្រា ៨៨ (ការចាត់ទុកជា បទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង) នៃក្រមនីតិវិធីព្រហ្មទណ្ឌ
- ក្នុងករណីមានសម្រែកស្រែកឲ្យគេជួយពីក្នុងទីកន្លែង
- ក្នុងករណីឆែកឆេរនៅទីកន្លែងក្នុងពេលម៉ោង ដែលបើកចំហរដល់សាធារណៈជន គឺសំដៅទៅដល់ទីតាំងដែលអាជីវកម្ម នៅពេលយប់ដូចជា បនល្បែង ក្លឹប ខារ៉ាអូខេ បនពេស្យា រង្គសាលរាំកម្សាន្តផ្សេងៗជាដើមគឺ

[34] ក្រមនីតិវិធីព្រហ្មទណ្ឌលេខ នស/រកម/០៧០៨/០២៤ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ១៨៣

[35] ក្រមនីតិវិធីព្រហ្មទណ្ឌលេខ នស/រកម/០៧០៨/០២៤ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ៩១

អាចឆែកឆេរបានព្រោះគេបើកចំហដល់សាធារណៈជននៅពេលយប់ ខុសពីម៉ោងឆែកឆេរពីម៉ោង ៦ ព្រឹក ដល់ម៉ោង ៦ ល្ងាច ដូច្នេះអាចធ្វើការឆែកឆេរដោយមិនគោរពលក្ខខណ្ឌពេលវេលានៃការឆែកឆេរ ។

• ក្នុងករណី ឆែកឆេរនៅគ្រប់ទីកន្លែងដែលផលិតរក្សាទុកជួញដូរចែកចាយនិងប្រើប្រាស់គ្រឿងញៀនគឺជាវិធានពិសេសមួយដែលទាក់ទងនឹងបទល្មើសគ្រឿងញៀនគឺពុំចាំបាច់គោរពវិធានទាក់ទងនឹងពេលវេលាចាប់ពីម៉ោង ៦ព្រឹក ដល់ម៉ោង ៦ ល្ងាចឡើយ ។

ចំពោះការឆែកឆេរនៅក្នុងការិយាល័យមេធាវី៖ មន្ត្រីនគរបាលយុត្តិធម៌ មិនអាចធ្វើការឆែកឆេរបានទេ មានតែព្រះរាជអាជ្ញា ឬចៅក្រមស៊ើបសួរតែប៉ុណ្ណោះ ដែលអាចធ្វើការឆែកឆេរបានដោយការឆែកឆេរនេះធ្វើបានតែនៅចំពោះមុខប្រធានគណៈមេធាវី ឬប្រតិភូរបស់ប្រធានគណៈមេធាវី ឬមេធាវីសាមី។

ចំពោះការឆែកឆេរនៅក្នុងអគារសារព័ត៌មាន សហគ្រាសនៃសារព័ត៌មានសរសេរ ឬសហគ្រាសសារព័ត៌មានសោតទស្សន៍បាន តែចំពោះមុខព្រះរាជអាជ្ញា ឬចៅក្រមស៊ើបសួរម្នាក់ ដែលធានារ៉ាប់រងកុំឲ្យការឆែកឆេរនេះប៉ះពាល់ដល់ការប្រកបដោយសេរីនូវមុខរបរអ្នកសារព័ត៌មាន និងធ្វើឲ្យយឺតយ៉ាវដល់ការផ្សព្វផ្សាយព័ត៌មាននេះដោយមិនត្រឹមត្រូវ។ **ជាឧទាហរណ៍៖** មន្ត្រីនគរបាលយុត្តិធម៌ ដែលឆែកឆេរដោយបំពានដោយសារគាត់ឆែកឆេរការិយាល័យមេធាវី ឬអគារសារពត៌មាន ដោយឯកឯងក្នុងករណីនេះការឆែកឆេរត្រូវចាត់ទុកជាមោឃៈបានន័យថាអ្វីដែលទទួលបាននៅក្នុងនីតិវិធីនោះ គឺមិនអាចយកជាការបានឡើយ គឺមិនមានអានុភាពសំរាប់យកមកអនុវត្តនោះទេ[36] ។

ចំពោះកំណត់ហេតុស្តីពីការឆែកឆេរ និងការបិទស្លាកលើវត្ថុតាង៖

រាល់ការប្រតិបត្តិការឆែកឆេរ មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើកំណត់ហេតុស្តីពីការឆែកឆេរ ដែល ក្នុងនោះមាន៖

- ការអនុញ្ញាតរបស់ព្រះរាជអាជ្ញា ដោយប្រាប់ថ្ងៃ និងម៉ោង នៃការអនុញ្ញាតនោះ
- អត្តសញ្ញាណរបស់អ្នកកាន់កាប់ទីកន្លែង ឬរបស់សាក្សីនីមួយៗ
- មន្ត្រីនគរបាលយុត្តិធម៌ អាចចាប់យកវត្ថុតាង និងបិទស្លាកបោះត្រាលើវត្ថុតាងនោះ[37]
- ក្រោយពីបង្ហាញវត្ថុចាប់បានដល់អ្នកកាន់កាប់ទីកន្លែង ឬសាក្សីពីរនាក់មើលរួចហើយ មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើកំណត់ហេតុស្តីពីការចាប់យក រួមទាំងបញ្ជីសារពើភ័ណ្ឌ នៃវត្ថុដែលចាប់យក
- កំណត់ហេតុស្តីពីការចាប់យកត្រូវចុះហត្ថលេខា ឬផ្តិតម្រាមដៃដោយអ្នកកាន់កាប់ទីកន្លែង ឬដោយសាក្សីពីរនាក់។

[36] ប្រសាសន៍របស់ ឯកឧត្តម កើត រិទ្ធ រដ្ឋមន្ត្រីនៃក្រសួងយុត្តិធម៌ ក្នុងកម្មវិធីផ្សព្វផ្សាយច្បាប់ស្តីពីក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

[37] ក្រមនីតិវិធីព្រហ្មទណ្ឌលេខ នស/រកម/០៧០៨/០២៤ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ៩២

### ១.២ ករណីបទល្មើសមិនជាក់ស្តែង

មន្ត្រីនគរបាលយុត្តិធម៌ អាចស៊ើបអង្កេតបឋមដោយអាចធ្វើការចុះឆែកឆេរបានដោយ៖

- អាចសុំម្ចាស់ទីកន្លែងចូលឆែកឆេរ និងចាប់យកវត្ថុតាងមកពិនិត្យបាន ដោយពុំទាន់ចាំសុំយោបល់ពីព្រះរាជអាជ្ញាប្រសិនបើម្ចាស់កន្លែងនោះយល់ព្រមអនុញ្ញាតឲ្យ ប៉ុន្តែការអនុញ្ញាតត្រូវតែមានជាលាយលក្ខណ៍អក្សរដោយស្មោះត្រង់ គ្មានការគាបសង្កត់ណាមួយជាដាច់ខាត។
- ប្រសិនបើអ្នកកាន់កាប់ទីកន្លែងអវត្តមាន ឬបដិសេធការឆែកឆេរ មន្ត្រីនគរបាលយុត្តិធម៌ត្រូវរាយការណ៍ជូនព្រះរាជអាជ្ញារួច ព្រះរាជអាជ្ញាសុំប្រធានសាលាដំបូង ហើយលុះត្រាតែប្រធានសាលាដំបូងចេញដីកាឲ្យឆែកឆេរតាមការសុំរបស់ព្រះរាជអាជ្ញា ទើបព្រះរាជអាជ្ញាត្រូវដឹកនាំ ឆែកឆេរផ្ទាល់បាន។ ក្នុងករណីនេះគឺត្រូវគោរពតាមនីតិវិធីដែលមានចែងក្នុងមាត្រា ១១៣ នៃ ក្រមនីតិវិធីព្រហ្មទណ្ឌ។
- ក្នុងការឆែកឆេរត្រូវធ្វើនៅចំពោះមុខអ្នកកាន់កាប់ទីកន្លែង ឬប្រសិនបើគ្មានអ្នកកាន់កាប់ទីកន្លែងទេ ត្រូវធ្វើនៅចំពោះមុខសាក្សីចំនួន ០២ នាក់ ហើយសាក្សីអាចត្រូវចាត់តាំងដោយព្រះរាជអាជ្ញា ដែលត្រូវជាអ្នកក្រៅពីនគរបាល ឬកងរាជអាវុធហត្ថដែលជាកម្លាំងរួម។
- ការឆែកឆេរមិនអាចផ្តើមមុខម៉ោង ០៦(ប្រាំមួយ) ព្រឹក និងក្រោយម៉ោង ០៦ (ប្រាំមួយ) ល្ងាចឡើយ ប៉ុន្តែបើកិច្ចការបន្តគឺអាចបន្តបានតាមពេលសមរម្យ។ (ពុំមានករណីពិសេសដូចក្នុង ករណីការឆែកឆេរករណីជាក់ស្តែងនៃមាត្រា៩១ នៃក្រមនីតិវិធីព្រហ្មទណ្ឌនោះទេ) ។
- ការឆែកឆេរត្រូវតែធ្វើកំណត់ហេតុ និងអនុវត្តតាមខ្លឹមសារដែលចែងក្នុងមាត្រា៩១ ជាដាច់ខាតនៃក្រមនីតិវិធីព្រហ្មទណ្ឌ។

កាលណាការស៊ើបអង្កេតបឋមនេះ ទាក់ទងនឹងបទល្មើសឧក្រិដ្ឋឬបទមជ្ឈិម មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការឆែកឆេរ និងចាប់យកវត្ថុតាង តែត្រូវទទួលការយល់ព្រមច្បាស់លាស់ និងពិតប្រាកដពីអ្នកកាន់កាប់ទីកន្លែង[38]។ ការយល់ព្រមត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរសរសេរ ដោយផ្ទាល់ដៃរបស់អ្នកកាន់កាប់ទីកន្លែង ប្រសិនបើអ្នកកាន់កាប់ទីកន្លែងមិនចេះអក្សរ នោះត្រូវសរសេរឲ្យបានច្បាស់លាស់ក្នុងកំណត់ហេតុថាអ្នកកាន់កាប់ទីកន្លែងនោះមិនចេះអក្សរហើយយល់ព្រមឲ្យឆែកឆេរ។

### កថាខណ្ឌ២ ការឃាត់ខ្លួន

ដើម្បីឆ្លើយតបនឹងតម្រូវការចាំបាច់នៃការស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការឃាត់ខ្លួន៖ បុគ្គលដែលសង្ស័យថាបានចូលរួមក្នុងបទល្មើស, បុគ្គលដែលដឹងពីរឿងហេតុបទល្មើសតែបដិសេធមិនផ្តល់ព័ត៌

[38] ក្រមនីតិវិធីព្រហ្មទណ្ឌលេខ នស/រកម/០៧០៨/០២៤ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ១១៣

មាន,មានការព្រមព្រៀងជាលាយលក្ខណ៍អក្សរឲ្យធ្វើការឃាត់ខ្លួនដោយព្រះរាជអាជ្ញា[39]។ ចំពោះការឃាត់ខ្លួនក្នុងករណីស៊ើបអង្កេតបឋមក៏ដូចក្នុងករណីជាក់ស្តែងផងដែរ ពោលគឺនៅពេលដែលមានតម្រុយពីអំពើបទល្មើសព្រហ្មទណ្ឌច្បាស់លាស់ឬត្រូវអនុវត្តវិធានការបង្ខំណាមួយ មន្ត្រីនគរបាលយុត្តិធម៌ ត្រូវរាយការណ៍ជូនព្រះរាជអាជ្ញាជាមុនសិនមានន័យថា៖ ប្រសិនបើក្រោយពីការស៊ើបអង្កេតពិនិត្យឃើញច្បាស់ថាពិតជាមានបទល្មើសព្រហ្មទណ្ឌច្បាស់លាស់ ហើយមានមូលហេតុចាំបាច់តម្រូវឲ្យឃាត់ខ្លួនខានមិនបាន មន្ត្រីនគរបាលយុត្តិធម៌អាចស្នើសុំឃាត់ខ្លួនជនសង្ស័យទៅព្រះរាជអាជ្ញា។ ដោយការស្នើសុំឃាត់ខ្លួននេះ គឺជាការផ្តើមគំនិតរបស់មន្ត្រីនគរបាលយុត្តិធម៌ ដូច្នេះមន្ត្រីនគរបាលយុត្តិធម៌ត្រូវតែភ្ជាប់ទៅជាមួយនូវភស្តុតាងដែលតម្រូវឲ្យមានការឃាត់ខ្លួនជាចាំបាច់នោះ ក្នុងការទទួលខុសត្រូវលើសំណើររបស់ខ្លួន ហើយលុះត្រាតែមានការយល់ព្រមជាលាយលក្ខណ៍អក្សរពីព្រះរាជអាជ្ញាទើបអាចធ្វើការឃាត់ខ្លួនបាន។

ក្នុងករណីស៊ើបអង្កេតបឋម ដែលមន្ត្រីនគរបាលយុត្តិធម៌បានហៅមកសាកសួរតាមសម្រួលហើយក្រោយពីការសាកសួរឃើញថា៖ ពុំមានបទល្មើសព្រហ្មទណ្ឌ ឬពុំមានពិរុទ្ធធ្ងន់ធ្ងរដែលមិនចាំបាច់ឃាត់ខ្លួនទេនោះមន្ត្រីនគរបាលយុត្តិធម៌អាចអនុញ្ញាតឲ្យជននោះអាចត្រឡប់ទៅវិញបាន ហើយបញ្ជូនតែសំណុំរឿងមកព្រះរាជអាជ្ញាជាក្រោយក៏បាន។ ម្យ៉ាងវិញទៀត ក្នុងករណីការស៊ើបអង្កេតដែលទទួលបញ្ជាពីព្រះរាជអាជ្ញាហើយក្រោយពីការស៊ើបអង្កេតពិនិត្យឃើញថា៖ ពុំមានបទល្មើសព្រហ្មទណ្ឌ ឬពុំមានពិរុទ្ធធ្ងន់ធ្ងរដែលមិនចាំបាច់ឃាត់ខ្លួនទេ មន្ត្រីនគរបាលត្រូវសុំការសម្រេចឃាត់ខ្លួន ឬមិនឃាត់ខ្លួនពីព្រះរាជអាជ្ញា ក្នុងករណីនេះប្រសិនបើព្រះរាជអាជ្ញាទទូតឲ្យឃាត់ខ្លួន និងបញ្ជាឲ្យឃាត់ខ្លួនទៀតនោះមន្ត្រីនគរបាល គ្រាន់តែសរសេរបញ្ជាក់ក្នុងរបាយការណ៍ថា៖ ការឃាត់ខ្លួននោះតាមការបញ្ជារបស់ព្រះរាជអាជ្ញាជាការស្រេចដើម្បីផុតពីការទទួលខុសត្រូវ។

### ២.១ រយៈពេលនៃការឃាត់ខ្លួន

#### ២.១.១ នីតិជន

ទាក់ទងនឹងរយៈពេលនៃការឃាត់ខ្លួនចំពោះនីតិជនមិនអាចឲ្យលើសពី ៤៨ម៉ោង គឺគិតពីម៉ោងដែលសាមីខ្លួនមកដល់អង្គភាពយុត្តិធម៌ ឬករណីខ្លះគិតពីពេលដែលមន្ត្រីនគរបាលយុត្តិធម៌ធ្វើកំណត់ហេតុស្តីពីការសួរចម្លើយចប់។ ការអនុញ្ញាតឲ្យពន្យាពេលឃាត់ខ្លួនត្រូវធ្វើជាលាយលក្ខណ៍អក្សរ និងមានសំអាងហេតុត្រូវដាក់បញ្ចូលទៅក្នុងសំណុំរឿង។ ចំពោះបទល្មើសឧក្រិដ្ឋ មន្ត្រីនគរបាលយុត្តិធម៌អាចពន្យារពេលឃាត់ខ្លួនបានតែត្រូវធ្វើការស្នើសុំទៅព្រះរាជអាជ្ញា ដែលការពន្យាពេលនេះមិនអាចឲ្យលើសពី ២៤ម៉ោងឡើយ គឺមិនគិតពីថេរវេលាចាំបាច់ដឹកជញ្ជូន។ នៅពេលដែលមានសុំការអនុញ្ញាតនេះ ព្រះរាជអាជ្ញានឹងធ្វើការផ្ទៀងផ្ទាត់មើលថា តើការសុំ

[39] ក្រមនីតិវិធីព្រហ្មទណ្ឌលេខ នស/រកម/០៧០៨/០២៤ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ៩៦

ពន្យារពេលរបស់មន្រ្តីនគរបាលយុត្តិធម៌មានមូលហេតុសមហេតុផលដែរឬទេ? ដោយក្នុងច្បាប់អាចហៅបានថា ពិនិត្យមើលមូលកភាពមានន័យថាមើលទៅមានលក្ខណៈសមស្របដែរឬទេ? កត្តានេះ ជាចំណុចសំខាន់មួយពីព្រោះថាការពន្យារពេលគឺមិនមែនចេះតែពន្យារពេលមិនមានមូលហេតុនោះទេ ម្យ៉ាងវិញទៀត គឺមិនមែនចេះតែសុំពន្យារពេលចង់ទុកឱ្យជនណាម្នាក់នៅយូរនោះទេ សំខាន់ទាល់តែមន្រ្តីនគរបាលយុត្តិធម៌មានតម្រុយបញ្ជាក់ថាបុគ្គលនោះ មានពិរុទ្ធភាពពាក់ព័ន្ធនឹងបទល្មើសដែរ ទើបគាត់អាចសុំពន្យារពេលដើម្បីយកចម្លើយ ឬស្វែងរកភស្តុតាងថ្មីៗបន្ថែម។ លើសពីនេះទៀតចំពោះការឃាត់ខ្លួននេះ គឺមានលក្ខណៈខុសៗគ្នាចំពោះបុគ្គលដែលត្រូវឃាត់ខ្លួន ដោយច្បាប់បានបញ្ញត្តិយ៉ាងច្បាស់ថាចំពោះមនុស្សពេញវ័យ (នីតិជន) ចាប់ពីអាយុ ១៨ ឆ្នាំឡើងទៅត្រូវមានរយៈពេលនៃការឃាត់ខ្លួនចំនួន ៤៨ ម៉ោង ហើយបទឧក្រិដ្ឋ ក្នុងករណីមានតម្រុយបញ្ជាក់ថាមានពិរុទ្ធភាពចាំបាច់មន្រ្តីនគរបាលយុត្តិធម៌អាចសុំពន្យារពេលបាន ២៤ ម៉ោង ដោយការសុំពន្យាពរនេះត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ និងមានសំអាងហេតុត្រូវបញ្ជូនទៅក្នុងសំណុំរឿង ។ អ្វីដែលត្រូវកំណត់ចំណាំលើសពីនេះទៅទៀត ការពន្យារជាវិធានការពិសេសមួយ ដែលអាចផ្តល់ពេលវេលាបន្ថែមដល់មន្រ្តីនគរបាលយុត្តិធម៌ក្នុងការស្វែងរកភស្តុតាងឱ្យគ្រប់ជ្រុងជ្រោយ ប៉ុន្តែមានករណីពិសេសមួយដែលមិនអាចមានការពន្យារពេលបាន ពីព្រោះថាការពន្យាពេលមិនអាចធ្វើបានទេ ប្រសិនបើបុគ្គលឃាត់ខ្លួននោះជាអនីតិជន។

### ២.១.២ អនីតិជន

ច្បាប់បានកំណត់យ៉ាងជាក់លាក់ចំពោះការឃាត់ខ្លួនរបស់អនីតិជន ដោយការឃាត់ខ្លួនអនីតិជនត្រូវបានធ្វើការញែកចេញអនីតិជនជា ៣ (បី) ប្រភេទគឺ កំណត់ទៅតាមអាយុរបស់អនីតិជនដែលត្រូវធ្វើការឃាត់ខ្លួន ដោយប្រភេទទី១ អនីតិជនមានអាយុក្រោម ១៤ឆ្នាំ ប្រភេទទី២ អនីតិជនចាប់ពីអាយុ ១៤ឆ្នាំ ដល់ក្រោម ១៦ឆ្នាំ និងប្រភេទទី៣ អាយុចាប់ពី ១៦ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ ត្រូវបានកំណត់រយៈពេលនៃការឃាត់ខ្លួនទៅតាមប្រភេទបទល្មើសដែលមានបញ្ជាក់ដូចខាងក្រោម៖

**ចំពោះបទឧក្រិដ្ឋ៖**

- អនីតិជនអាយុ ពី ១៤ឆ្នាំ ដល់ ក្រោម ១៦ឆ្នាំ មិនអាចឃាត់ខ្លួនលើសពី ៣៦ម៉ោងឡើយ។
- អនីតិជនអាយុ ពី ១៦ឆ្នាំ ដល់ ក្រោម ១៨ឆ្នាំ មិនអាចឃាត់ខ្លួនលើសពី ៤៨ម៉ោងឡើយ។

**ចំពោះបទមជ្ឈិម៖**

- អនីតិជនអាយុ ពី ១៤ឆ្នាំ ដល់ ក្រោម ១៨ឆ្នាំ មិនអាចឃាត់ខ្លួនលើសពី ២៤ម៉ោងឡើយ។
- អនីតិជនអាយុ ពី ១៦ឆ្នាំ ដល់ ក្រោម ១៨ឆ្នាំ មិនអាចឃាត់ខ្លួនលើសពី ៣៦ម៉ោងឡើយ។

ចំពោះអនីតិជនអាយុក្រោម ១៤ឆ្នាំ មិនអាចធ្វើការឃាត់ខ្លួនទេ។ កាលណាបុគ្គលដែលត្រូវបានឃាត់ខ្លួនជាអនីតិជន មន្ត្រីនគរបាលយុត្តិធម៌ត្រូវជូនព័ត៌មានតាមគ្រប់មធ្យោបាយដល់ឪពុក-ម្ដាយ អ្នកតំណាងស្របច្បាប់ឬដល់អ្នកទទួលភារកិច្ចលើអនីតិជននេះ[40] ។

## ២.២ បែបបទនៃការឃាត់ខ្លួន

រាល់ការឃាត់ខ្លួនរបស់មន្ត្រីនគរបាលយុត្តិធម៌ចំពោះជនណាម្នាក់ គឺត្រូវតែធ្វើកំណត់ហេតុពីព្រោះមិនមែនចេះតែឃាត់ខ្លួនគេដោយមិន។ មន្ត្រីនគរបាលយុត្តិធម៌ត្រូវជូនដំណឹងជាបន្ទាន់ អំពីសេចក្ដីសម្រេចរបស់ខ្លួនដល់បុគ្គលដែលត្រូវបានឃាត់ខ្លួន ដើម្បីឱ្យគាត់បានដឹងអំពីមូលហេតុដែលនាំឱ្យមានការឃាត់ខ្លួនរបស់គាត់និងត្រូវប្រាប់ឱ្យសាម៉ីខ្លួនបានដឹងថាគាត់មានសិទ្ធិពឹងពាក់មេធាវីដើម្បីការពារខ្លួនរបស់គាត់ដែលនេះជាចំណុចដែលល្អមួយដើម្បីជៀសវាងនូវការរំលោភបំពានសិទ្ធិ និងផលប្រយោជន៍ពីសំណាក់មន្ត្រីនគរបាលយុត្តិធម៌ដែលបំពានទៅលើច្បាប់ និងជៀសវាងការបំពានទៅលើជនដែលមិនសូវមានចំពោះដឹងផ្នែកច្បាប់។ ក្នុងករណីចាំបាច់ការយកចម្លើយផ្សេងៗ បើជនដែលត្រូវបានឃាត់ខ្លួននោះជាជនបរទេសដែលគាត់មិនអាចស្ដាប់យល់ភាសាខ្មែរបាននោះ គឺគាត់មានសិទ្ធិសុំឱ្យមានអ្នកបកប្រែភាសាដើម្បីឱ្យនិយាយស្ដាប់គ្នាបាន ហើយអ្នកបកប្រែភាសានោះមិនមែនជាមន្ត្រីនគរបាលយុត្តិធម៌ ឬអ្នកជាប់ពាក់ព័ន្ធនឹងប្រតិបត្តិការឡើយ។ កាលណាមានការឃាត់ខ្លួនបុគ្គលណាមួយ មន្ត្រីនគរបាលយុត្តិធម៌ត្រូវប្រាប់ជនដែលត្រូវឃាត់នោះអំពីសេចក្ដីសម្រេចឃាត់ខ្លួន៖

- ប្រាប់មូលហេតុពីការឃាត់ខ្លួន
- ប្រាប់សិទ្ធិរកមេធាវី
- សិទ្ធិរកអ្នកបកប្រែបើចាំបាច់

មន្ត្រីនគរបាលយុត្តិធម៌ធ្វើកំណត់ហេតុស្ដីពីការឃាត់ខ្លួនជាបន្ទាន់ ដោយមានចុះសេចក្ដីដូចតទៅ[41] ៖

- ឈ្មោះ និងឋានៈរបស់មន្ត្រីនគរបាលយុត្តិធម៌ដែលបានបង្គាប់ឲ្យឃាត់ខ្លួន
- អត្តសញ្ញាណនៃបុគ្គលដែលត្រូវឃាត់ខ្លួន
- មូលហេតុនៃការឃាត់ខ្លួន
- ថ្ងៃ ខែ ឆ្នាំ និងម៉ោងដែលផ្ដើមឃាត់ខ្លួន
- ការឲ្យដំណឹងអំពីសិទ្ធិដែលបានប្បញ្ញត្តិនៃមាត្រា ៩៨[42] (ជំនួយរបស់មេធាវីនៅក្នុងពេលឃាត់ខ្លួន)

[40] ក្រមនីតិវិធីព្រហ្មទណ្ឌលេខ នស/រកម/០៧០៨/០២៤ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ១០០

[41] ក្រមនីតិវិធីព្រហ្មទណ្ឌលេខ នស/រកម/០៧០៨/០២៤ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ៩៧

[42] បញ្ញត្តិមាត្រា ៩៨ (ជំនួយរបស់មេធាវីក្នុងពេលឃាត់ខ្លួន) នៃក្រមនីតិវិធីព្រហ្មទណ្ឌចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០៧

- ជាយថាហេតុឈ្មោះអ្នកបកប្រែ។

កំណត់ហេតុនេះត្រូវតែមានចុះហត្ថលេខា ឬផ្តិតម្រាមដៃរបស់ជន ដែលត្រូវឃាត់ខ្លួនបន្ទាប់ពីបានធ្វើកំណត់ហេតុរួចឬសាមីខ្លួនមិនចេះអក្សរ មន្ត្រីនគរបាលយុត្តិធម៌ ត្រូវបានអានកំណត់ហេតុឱ្យស្តាប់ហើយ ប្រសិនបើជននេះប្រកែកមិនព្រមចុះហត្ថលេខា ឬផ្តិតម្រាមដៃនោះទេ មន្ត្រីនគរបាលយុត្តិធម៌ត្រូវចុះនិទ្ទេស[43] ។

## ២.២.១ សិទ្ធិជួយប្រាស្រ័យមេធាវីក្នុងពេលឃាត់ខ្លួន

ចំពោះសិទ្ធិជួយប្រាស្រ័យមេធាវីនៅក្នុងពេលឃាត់ខ្លួន ប្រសិនបើជនដែលត្រូវបានឃាត់ខ្លួនចង់រកជំនួយពីសំណាក់មេធាវី គឺមិនត្រូវរកភ្លាមក្នុងអំឡុងពេលឃាត់ខ្លួនមិនទាន់ផុតរយៈ ២៤ ម៉ោង បន្ទាប់ពីត្រូវបានឃាត់ខ្លួននោះឡើយ។ នៅក្នុងមាត្រា ៩៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ អនុញ្ញាតឱ្យជននោះអាចរកមេធាវីបាន កាលណារយៈពេល ២៤ ម៉ោងបានកន្លងហួសទៅក្រោយពីការឃាត់ខ្លួន ជននោះអាចទាក់ទងជាមួយមេធាវី ឬបុគ្គលផ្សេងទៀតដែលមិនមានទំនាក់ទំនងជាមួយអំពើល្មើស ដើម្បីពិភាក្សាជាមួយគ្នាបានរយៈពេលចំនួន ៣០នាទីតែប៉ុណ្ណោះ។ ក្នុងការសន្ទនារវាងជនដែលត្រូវឃាត់ខ្លួនជាមួយមេធាវី ឬបុគ្គលណាម្នាក់នោះ គឺត្រូវធ្វើនៅក្នុងក្របខ័ណ្ឌរក្សាការសម្ងាត់នៃការសន្ទនាមានន័យថា មិនឱ្យមន្ត្រីនគរបាលយុត្តិធម៌ ឬតតិយជនទៅលួចស្តាប់ការសន្ទនាថា តើពួកគេនិយាយគ្នាពីអ្វីនោះបានឡើយ។ បន្ទាប់ពីមានការសន្ទនាបានបញ្ចប់រួចហើយ ជនដែលជួបសន្ទនានោះអាចធ្វើការកត់សម្គាល់ជាលាយលក្ខណ៍អក្សរ ដែលត្រូវភ្ជាប់ជាមួយសំណុំរឿង។ ចំពោះមេធាវី ឬជនណាម្នាក់ដែលមិនមានទាក់ទិននៅក្នុងរឿងជាមួយជនត្រូវឃាត់ខ្លួននោះ បានជ្រើសរើសឱ្យមកធ្វើជាជំនួយរបស់ខ្លួនគឺត្រូវតែបានទទួលដំណឹងពីការស្នើសុំជ្រើសរើសនេះតាមគ្រប់មធ្យោបាយនិងជាបន្ទាន់ហើយអាចចូលទៅកាន់កន្លែងឃាត់ខ្លួន និងទាក់ទងជាមួយបុគ្គលដែលត្រូវឃាត់ខ្លួនបាន ។

## ២.២.២ សិទ្ធិជំនួយគ្រូពេទ្យនៅក្នុងពេលឃាត់ខ្លួន

ចំពោះជំនួយគ្រូពេទ្យនៅក្នុងពេលឃាត់ខ្លួន នាពេលឃាត់ខ្លួន ព្រះរាជអាជ្ញា ឬមន្ត្រីនគរបាលយុត្តិធម៌អាចសុំឲ្យគ្រូពេទ្យមកពិនិត្យជនដែលត្រូវឃាត់ខ្លួន។ បើសុខភាពជនត្រូវឃាត់ខ្លួនមិនសមស្របនឹងការឃាត់ខ្លួននោះទេ មន្ត្រីនគរបាលយុត្តិធម៌ ត្រូវរាយការណ៍បន្ទាន់ទៅព្រះរាជអាជ្ញា។ ចំពោះគ្រូពេទ្យ ដែលចេញវិញ្ញាបនប័ត្របញ្ជាក់សុខភាពជនត្រូវឃាត់ខ្លួន ត្រូវភ្ជាប់ជាមួយសំណុំរឿង។ ចំណែកឯមន្ត្រីនគរបាលយុត្តិធម៌ ត្រូវចុះនិទ្ទេសការពិនិត្យសុខភាពធ្វើដោយគ្រូពេទ្យ ចុះក្នុងកំណត់ហេតុជាមួយឈ្មោះគ្រូពេទ្យនិងថ្ងៃ ខែ ឆ្នាំ ម៉ោងពិនិត្យសុខភាព[44] ។

---

[43] អត្ថន័យចុះនិទ្ទេស "បានអានឱ្យស្តាប់រួចរាល់ហើយតែបុគ្គលនេះមិនព្រមចុះហត្ថលេខា ឬមិនផ្តិតម្រាមដៃ"

[44] ក្រមនីតិវិធីព្រហ្មទណ្ឌលេខ នស/រកម/០៧០៨/០២៤ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ៩៩

**២.២.៣ ការជូនដំណឹងអំពីការឃាត់ខ្លួន (អនីតិជន)**

ជាគោលការណ៍ កាលណាជនត្រូវឃាត់ខ្លួនជាអនីតិជន មន្ត្រីនគរបាលយុត្តិធម៌ត្រូវជូនដំណឹងដល់ឪពុកម្តាយ អ្នកតំណាងស្របច្បាប់ ឬអ្នកទទួលភារកិច្ចលើអនីតិជននោះ ។

**២.២.៤ បញ្ជីឃាត់ខ្លួន**

នៅតាមអង្គភាពមន្ត្រីនគរបាលយុត្តិធម៌នីមួយៗ ត្រូវតែមានបញ្ជីសម្រាប់ចុះការឃាត់ខ្លួនជាចាំបាច់ ហើយគាត់ត្រូវតែចុះឲ្យបានត្រឹមត្រូវ និងទុកជូនអាជ្ញាធរតុលាការពិនិត្យគ្រប់ពេល។ បញ្ជីត្រូវមានសេចក្តីដូចខាងក្រោម[45] ៖

- ឈ្មោះ និងឋានៈមន្ត្រីនគរបាលយុត្តិធម៌ដែលបានបង្គាប់ឲ្យធ្វើការឃាត់ខ្លួន
- ចុះអត្តសញ្ញាណរបស់បុគ្គលដែលឃាត់ខ្លួន
- ថ្ងៃខែឆ្នាំ និងម៉ោងដែលចាប់ផ្តើមឃាត់ខ្លួន និងបញ្ចប់ការឃាត់ខ្លួន
- ឈ្មោះ និងឋានៈរបស់ចៅក្រមដែលបានអនុញ្ញាតឲ្យបន្តការឃាត់ខ្លួនជាយថាហេតុ
- ឈ្មោះរបស់គ្រូពេទ្យដែលបានពិនិត្យបុគ្គលឃាត់ខ្លួនជាយថាហេតុ
- ប្រភេទនៃសេចក្តីសម្រេចរបស់អាជ្ញាធរតុលាការនៅពេលផុតកំណត់ការឃាត់ខ្លួន។

**២.២.៥ កំណត់ហេតុសរុបនៃការឃាត់ខ្លួន**

ជាគោលការណ៍ គ្រប់ការឃាត់ខ្លួនត្រូវតែមានកំណត់ហេតុសរុបនៃការឃាត់ខ្លួនដែលត្រូវភ្ជាប់ជាមួយសំណុំរឿងទាក់ទងនឹងការឃាត់ខ្លួននេះ តម្រូវមានកំណត់ហេតុ ០២ គឺ កំណត់ហេតុស្តីពីការឃាត់ខ្លួនដែលត្រូវធ្វើដំបូងក្នុងពេលចាប់ផ្តើមឃាត់ខ្លួននិងកំណត់ហេតុសរុបនៃការឃាត់ខ្លួនដែលជាកំណត់ហេតុចុងក្រោយបង្អស់នៃការឃាត់ខ្លួន។ កំណត់ហេតុសរុបនៃការឃាត់ខ្លួននេះ គឺជាការកត់ត្រាហេតុការណ៍ទាំងអស់នៅក្នុងអំឡុងពេលឃាត់ខ្លួនជនសង្ស័យ ចាប់តាំងពីពេលឃាត់ខ្លួនដំបូងរហូតដល់ពេលសម្រេចចុងក្រោយនៃការបញ្ជូនឬការដោះលែងឲ្យមានសេរីភាពវិញ។ កំណត់ហេតុនេះ ជាការបញ្ជាក់បញ្ជាពីការអនុវត្តនីតិវិធីហើយវាអាចមានការតវ៉ាឬសុំមោឃភាពនៅចំពោះមុខតុលាការ ដោយកំណត់ហេតុសរុបនេះ ត្រូវមានចុះនិទ្ទេសដូចខាងក្រោម[46] ៖

- ឈ្មោះ និងឋានៈមន្ត្រីនគរបាលយុត្តិធម៌ដែលបង្គាប់ឲ្យឃាត់ខ្លួន
- អត្តសញ្ញាណរបស់បុគ្គលដែលត្រូវឃាត់ខ្លួន
- មូលហេតុនៃការឃាត់ខ្លួន
- ថ្ងៃខែឆ្នាំ និងម៉ោងដែលផ្តើមការឃាត់ខ្លួន

[45] ក្រមនីតិវិធីព្រហ្មទណ្ឌលេខ នស/រកម/០៧០៨/០២៤ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ១០១

[46] ក្រមនីតិវិធីព្រហ្មទណ្ឌលេខ នស/រកម/០៧០៨/០២៤ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ១០២

- បែបបទនៃការជូនដំណឹងដល់ព្រះរាជអាជ្ញា
- បែបបទនៃការជូនដំណឹងដោយអនុវត្តតាមមាត្រា១០០
- ឈ្មោះពេទ្យដែលបានពិនិត្យបុគ្គលឃាត់ខ្លួន
- អត្តសញ្ញាណរបស់ជនដែលបានសន្ទនាជាមួយបុគ្គលឃាត់ខ្លួនស្របតាមមាត្រា៩៨
- ឈ្មោះ និងឋានៈរបស់ចៅក្រមដែលជាយថាហេតុ បានអនុញ្ញាតឲ្យបន្តការឃាត់ ខ្លួន
- ថេរវេលាការស្តាប់ចម្លើយនីមួយៗ និងការសម្រាកដែលនៅចន្លោះការស្តាប់ចម្លើយ នីមួយៗ
- ថ្ងៃខែឆ្នាំ និងម៉ោងនៃការឃាត់ខ្លួន
- ប្រភេទនៃសេចក្តីសម្រេចរបស់អាជ្ញាធរតុលាការនៅពេលបញ្ចប់ការឃាត់ខ្លួន
- លក្ខខណ្ឌនៃការប្រព្រឹត្តទៅនៃការឃាត់ខ្លួនព្រមទាំងឧប្បត្តហេតុជាយថាហេតុ។

### កថាខណ្ឌ៣ ការបញ្ជូនខ្លួនជនសង្ស័យ

នៅក្នុងរយៈពេលនៃការឃាត់ខ្លួនជនសង្ស័យ មន្ត្រីនគរបាលយុត្តិធម៌ ត្រូវពិនិត្យនូវពិរុទ្ធភាពជនដែលបានឃាត់ខ្លួននោះ ហើយក៏ត្រូវពិចារណានូវមូលហេតុទាំងឡាយដែលគួរឃាត់ខ្លួនឬមិនគួរឃាត់ខ្លួន។ មន្ត្រីនគរបាលយុត្តិធម៌ត្រូវរាយការណ៍ទៅព្រះរាជអាជ្ញា ពីមូលហេតុច្បាស់លាស់ដើម្បីសម្រេចថាតើត្រូវបញ្ជូនទៅព្រះរាជអាជ្ញា ឬត្រូវដោះលែងឲ្យមានសេរីភាពឡើងវិញ។

### ៣.១ រយៈពេលនៃការបញ្ជូនខ្លួន

ជាគោលកាណ៍នៅពេលផុតរយៈពេលនៃការឃាត់ខ្លួន បុគ្គលដែលត្រូវឃាត់ខ្លួននោះត្រូវ៖ **បញ្ជូនទៅព្រះរាជអាជ្ញា ឬដោះលែងឲ្យមានសេរីភាពវិញ** [47]។ ចំពោះរយៈពេលនៃការបញ្ជូនខ្លួនវិញ៖ ជនដែលត្រូវឃាត់ខ្លួនហើយត្រូវបញ្ជូនទៅព្រះរាជអាជ្ញា គឺត្រូវនាំខ្លួនភ្លាមទៅចំពោះមុខព្រះរាជអាជ្ញា ប្រសិនបើពុំអាចធ្វើបាននូវថ្ងៃតែមួយដោយមូលហេតុដឹកជញ្ជូនឬចម្ងាយផ្លូវនៃការដឹកជញ្ជូននោះរយៈពេលបន្ថែមអាចផ្តល់ឲ្យដោយព្រះរាជអាជ្ញាបាន។ ក្នុងគ្រប់ករណីទាំងអស់ការបង្ហាញខ្លួនបុគ្គលដែលត្រូវបានឃាត់ខ្លួននោះ គឺត្រូវធ្វើឡើងក្នុងរយៈពេលដ៏ឆាប់បំផុតតាមការដែលអាចធ្វើទៅបាន។ ចំណែកឯមូលហេតុនៃការយឺតយ៉ាវ ត្រូវចុះក្នុងកំណត់ហេតុដែលត្រូវប្រគល់ជូនព្រះរាជអាជ្ញា ដោយមន្ត្រីនគរបាលយុត្តិធម៌។

[47] ក្រមនីតិវិធីព្រហ្មទណ្ឌលេខ នស/រកម/០៧០៨/០២៤ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ១០៣

**កថាខណ្ឌ៤ ទណ្ឌកម្មចំពោះកិច្ចមិនគោរពវិធាន**

ចំពោះកិច្ចទាំងឡាយណាដែលធ្វើឡើងដោយមន្ត្រីនគរបាលយុត្តិធម៌ ឬភ្នាក់ងារនគរបាលយុត្តិធម៌ឬមន្ត្រីរាជការនិងភ្នាក់ងារសាធារណៈដោយមិនគោរពវិធាន ដែលមានចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌត្រូវចាត់ទុកជាមោឃៈ៖

- វិធានសមត្ថកិច្ចដែនដីមានលក្ខណៈដាច់ខាតៈ បើមិនគោរពតាមវិធានដែលមានចែងនោះទេកិច្ចទាំងឡាយដែលបំពេញដោយមន្ត្រីនគរបាលយុត្តិធម៌ត្រូវទុកជាមោឃៈ[48]
- បំពានសេចក្តីសម្រេចហាមឃាត់របស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ (មាត្រា ៦៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)
- បំពានលើវិធានដែលបានចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ដែលមានលក្ខណដាច់ខាត់ត្រូវតែគោរពតាម បើមិនដូច្នេះទេនាំឲ្យមានមោឃភាពនៃនីតិវិធី[49] ដែលវិធានទាំងនោះ រួមមាន៖
    - មាត្រា ៩០ (កំណត់ហេតុលើការស្រាវជ្រាវ)
    - មាត្រា ៩១ (ការឆែកឆេរ)
    - មាត្រា ៩២ (ការបិទស្លាកបោះត្រាលើវត្ថុតាង)
    - មាត្រា ៩៣ (កំណត់ហេតុលើការស្តាប់ចម្លើយ)
    - មាត្រា ៩៤ (បទបញ្ជាឲ្យចូលខ្លួនក្នុងករណីការស៊ើបអង្កេតបទល្មើសជាក់ស្តែង)
    - មាត្រា ៩៥ (ការត្រួតពិនិត្យខាងផ្នែកបច្ចេកទេស ឬវិទ្យាសាស្ត្រ)
    - មាត្រា ៩៦ (ការឃាត់ខ្លួន)
    - មាត្រា ៩៧ (កំណត់ហេតុស្តីពីការឃាត់ខ្លួន)
    - មាត្រា ៩៨ (ជំនួយរបស់មេធាវីនៅក្នុងពេលឃាត់ខ្លួន)
    - មាត្រា ៩៩ (ជំនួយរបស់គ្រូពេទ្យនៅក្នុងពេលឃាត់ខ្លួន)
    - មាត្រា ១០០ (អនីតិជនដែលត្រូវបានឃាត់ខ្លួន)
    - មាត្រា ១០៥ (ការហាមឃាត់មិនឲ្យស្តាប់ដោយឯង ជាអាទិ៍)
    - មាត្រា ១០៦ (ថិរវេលានៃការស៊ើបអង្កេតករណីជាក់ស្តែង) និង
    - មាត្រា ១០៨ (និទ្ទេសដែលត្រូវចុះនៅក្នុងកំណត់ហេតុ) ។

[48] ក្រមនីតិវិធីព្រហ្មទណ្ឌលេខ នស/រកម/០៧០៨/០២៤ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ៦៩

[49] ក្រមនីតិវិធីព្រហ្មទណ្ឌលេខ នស/រកម/០៧០៨/០២៤ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ១០៩

- ចំពោះវិធាន និងទម្រង់ការដែលមានលក្ខណៈដាច់ខាតត្រូវតែគោរពតាម បើមិនដូច្នេះ ទេនាំឲ្យមានមោឃៈភាពនៃនីតិវិធី ដែលរួមមានដូចជា៖
  - មាត្រា ៩៦ (ការឃាត់ខ្លួន)
  - មាត្រា ៩៧ (កំណត់ហេតុស្តីពីការឃាត់ខ្លួន)
  - មាត្រា ១០០ (អនីតិជនដែលត្រូវបានឃាត់ខ្លួន)
  - មាត្រា ១០៥ (ការហាមឃាត់មិនឲ្យស្តាប់ដោយឯកឯង ជាអាទិ៍)
  - មាត្រា ១០៧ (ការបញ្ជូនកំណត់ហេតុទៅព្រះរាជអាជ្ញា)
  - មាត្រា ១១៣ (ការឆែកឆេរ)
  - មាត្រា ១១៤ (ការបញ្ជាឲ្យចូលខ្លួន ការស៊ើបអង្កេតបឋម) ។
- ករណីភ្នាក់ងារនគរបាលយុត្តិធម៌ពុំអាចបំពេញកិច្ច ត្រូវរក្សាទុកជូនតែមន្រ្តីនគរបាលយុត្តិធម៌។ កិច្ចទាំងឡាយណាដែលត្រូវបានបំពេញលើការហាមឃាត់នេះ ត្រូវចាត់ទុកជាមោឃៈ ដូចដែលមានចែងបញ្ញត្តិក្នុងមាត្រា ៧៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

នៅក្នុងការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌមួយ គឺជាសកម្មភាពដ៏សកម្មឬក៏ជាបេសកកម្មរបស់មន្ត្រីនគរ បាលយុត្តិធម៌។ ដោយនៅក្នុងដំណាក់ការស៊ើបអង្កេតបទល្មើសនីមួយៗ មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការស៊ើបអង្កេតដោយខ្លួនឯងផ្ទាល់ ដោយគ្រាន់តែមានតម្រុយមួយចំនួនឬទទួលពាក្យបណ្តឹងពីជនរងគ្រោះផ្ទាល់ ព្រមទាំងតតិយជន ឬក៏អាចជាជនអនាមិកដែលបានរាយការណ៍មកជូនមន្ត្រីនគរបាលយុត្តិធម៌ផ្ទាល់។ បេសកកម្មទាំងនេះមានពីរប្រភេទគឺ ការស៊ើបអង្កេតបទល្មើសជាក់ស្តែង និងការស៊ើបអង្កេតបឋមហើយការស៊ើបអង្កេតនីមួយៗមន្ត្រីនគរបាលយុត្តិធម៌ត្រូវតែពិនិត្យឱ្យបានច្បាស់នូវនីតិវិធីដែលមានចែងនៅក្នុងច្បាប់ ពីព្រោះប្រសិនបើការស៊ើបអង្កេតណាមួយមិនស្របទៅនឹងនីតិវិធីដែលមានចែងក្នុងច្បាប់ទេពេលនោះការស៊ើបអង្កេតនិងត្រូវទុកជាមោឃៈ ។

ដោយឡែកការអនុវត្តនៅក្នុងឧក្រិដ្ឋឋាន ក៏ជាបេសកកម្មពិសេសរបស់មន្ត្រីនគរបាលផងដែរ ដោយក្នុងការប្រមែប្រមូលភស្តុតាង ស្លាកស្នាម ឬតម្រុយដែលអ្វីៗទាំងអស់ គឺជាសញ្ញាដែលឈានទៅដល់ការឃាត់ខ្លួនជនសង្ស័យបាន ។ បេសកកម្មនៅកន្លែងកើតហេតុនេះ ត្រូវធ្វើឡើងដោយយកចិត្តទុកដាក់ ហើយមិនត្រូវឱ្យមានការយឺតយ៉ាវឡើយ ព្រោះគុណភាពនៃភស្តុតាងអាចមានការបាត់បង់ដោយសារតែគ្មានការគ្រប់គ្រងដែលអាចបណ្តាលមកពីភាពរឹករវដោយសារមានពលរដ្ឋដើរឆ្លងកាត់ ដែលជាហេតុធ្វើឱ្យមានការបាត់បង់វត្ថុផ្សេងៗ ។

នៅក្នុងការស៊ើបអង្កេតរឿងក្តីព្រហ្មទណ្ឌបេសកកម្មរបស់មន្ត្រីនគរបាលយុត្តិធម៌ គឺមានគោលដៅវែកមុខរកជនដែលបានប្រព្រឹត្តបទ និងស្វែងរកយុត្តិធម៌ជូនជនរងគ្រោះ ព្រមទាំងសង្គមជាតិផងដែរ។ និយាយជារួមការស៊ើបអង្កេតនៅក្នុងដំណាក់កាលនេះ មន្ត្រីនគរបាលយុត្តិធម៌មិនត្រូវរំលងនូវការអនុវត្តនីតិសាកសួរជនសង្ស័យនិងសាក្សីឡើយ ព្រោះវាក៏ជាសញ្ញាមួយដែលអាចឱ្យមន្ត្រីនគរបាល ធ្វើការកំណត់អត្តសញ្ញាណជនសង្ស័យដែលប្រព្រឹត្តបទល្មើស។ ក្រោយពីស្វែងរកភស្តុតាងដែលបានបន្សល់ទុកនៅកន្លែងកើតហេតុក៏ដូចជាការសាកសួរជនសង្ស័យនិងសាក្សីហើយនោះ ប្រសិនបើមានភាពស៊ីសង្វាក់គ្នា ពេលនោះមន្ត្រីនគរបាលអាចចាត់វិធានការតាមស្វែងរកខ្លួនជនដែលបានប្រព្រឹត្តបទល្មើស ដោយមានសេចក្តីសម្រេចពីព្រះរាជអាជ្ញា ឬដោយមានដីកាចាប់ខ្លួនផងដែរ ។

# អនុសាសន៍

# អនុសាសន៍

យោងតាមការស្រាវជ្រាវរបស់ក្រុមយើងខ្ញុំ ដើម្បីចូលរួមចំណែកធ្វើអោយសារណារបស់យើងខ្ញុំមួយនេះ អាចយកទៅអនុវត្តបាននៅក្នុងប្រទេសជាតិ ដូច្នេះយើងខ្ញុំសូមផ្តល់ជាអនុសាសន៍មួយចំនួនដូចខាងក្រោមៈ

- សូមសំណូមពរដល់ប្រជាពលរដ្ឋគ្រប់រូបសូមមេត្តាជួយសហការណ៍គ្នា ជាមួយមន្ត្រីនរគបាលយុត្តិធម៌ នៅពេលដែលមានបទល្មើសកើតឡើង។ ក្នុងការសហការជាមួយមន្ត្រីនគរបាលយុត្តិធម៌នោះមានដូច ជាត្រូវតែរាយការណ៍ផ្តល់ជូនទៅកាន់ប៉ុស្តិ៍នគរបាលរដ្ឋបាល ដែលមានទីតាំងជិតបំផុតនៅទីកន្លែង ដែលកើតហេតុនោះ។
- ម្យ៉ាងវិញទៀតប្រជាពលរដ្ឋគ្រប់រូបអាចដាក់ជាបណ្តឹងដោយចំហរ ឬធ្វើពាក្យបណ្តឹងអានាមិកក៏បាន ដោយមិនគិតថាប្រជាពលរដ្ឋនោះជាជនរងគ្រោះផ្ទាល់ ឬតតីយជនក្តី គឺមានសិទ្ធិធ្វើពាក្យបណ្តឹងខាង លើបាន។
- សូមសំណូមពរដល់មន្ត្រីនគរបាលទាំងអស់ឲ្យលុបចោលនូវរាល់អំពើពុករលួយ ជាពិសេសគឺអ្នកធ្វើ កំណត់ហេតុ និងអ្នកធ្វើកោសលវិច្ច័យ ដើម្បីជម្រុញអោយប្រទេសជាតិមានតម្លាភាពនិងមាននីតិរដ្ឋ ។
- សូមឲ្យមន្ត្រីនគរបាលយុត្តិធម៌ទាំងឡាយ មេត្តាគោរពតួនាទីនិងច្បាប់ឲ្យបានហ្មត់ចត់នូវក្រមសីលធម៌ ព្រមទាំងគោលការណ៍ទាំងឡាយណា ដែលមានចែងនៅក្នុងច្បាប់ឲ្យបានម៉ឺងម៉ាត់ ព្រោះបើមិនគោរពទេ នោះអាចនឹងបណ្តាលឲ្យមានការរំលោភនូវសិទ្ធិមនុស្សព្រម ទាំងសិទ្ធិសេរីភាពនឹងសេចក្តីថ្លៃថ្នូររបស់ ប្រជាពល រដ្ឋគ្រប់រូបថែមទាំងធ្វើឲ្យប្រទេសជាតិ បាត់បង់នូវនីតិរដ្ឋទាំងស្រុងទៀតផង ។

# ឯកសារយោង

# ឯកសារយោង

- ក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០៧
- បទប្បញ្ញត្តិស្តីពី ប្រព័ន្ធតុលាការច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌសម្រាប់អនុវត្តនៅប្រទេសកម្ពុជាសម័យអន្តរកាល ចុះថ្ងៃទី ១០ ខែកញ្ញា ឆ្នាំ១៩៩២
- សេចក្តីផ្តើមនៃនីតិកម្ពុជា រៀបរៀងដោយការិយាល័យស្រាវជ្រាវ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ចឆ្នាំ២០០៥
- សន្ទានុក្រមបារាំង-ខ្មែរ នៃពាក្យច្បាប់ឆ្នាំ២០០៥ រៀបរៀងដោយសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច
- នីតិព្រហ្មទណ្ឌទូទៅ រៀបរៀងដោយលោកសាស្រ្តាចារ្យ **រុន ពណ្ណារិទ្ធ** និង លោកស្រីសាស្រ្តចារ្យ **ចាំង ស៊ីណាត** ឆ្នាំ២០១២
- វចនានុក្រម សម្តេចព្រះសង្ឃរាជ ជួន ណាត
- វីឌីអូស្តីពី "វគ្គបណ្តុះបណ្តាលមន្ត្រីនគរបាលយុត្តិធម៌" ក្រោមការធ្វើបទបង្ហាញរបស់ ឯកឧត្តម កើត រិទ្ធ រដ្ឋមន្ត្រីនៃក្រសួងយុត្តិធម៌ ចុះផ្សព្វផ្សាយថ្ងៃទី ២០ ដល់ទី ២៤ ខែមិថុនា ឆ្នាំ២០១៦

# ឧបសម្ព័ន្ធ

# តារាងឧបសម្ព័ន្ធទី ១

| **លេខរៀង** | **ឈ្មោះឯកសារពាក់ព័ន្ធ** |
|---|---|
| ១ | ប្រកាសអន្តរក្រសួងលេខ ០៥៤ កយ.ដនស.ប្រក/២១ ស្តីពីការផ្តល់នីតិសម្បទាជានគរបាលយុត្តិធម៌ ចុះថ្ងៃទី ១៨ ខែកុម្ភៈ ឆ្នាំ២០២១ |
| ២ | ប្រកាសលេខៈ កយ.ប្រក/០៧ ស្តីពី បែបបទ និងទម្រង់ការនៃការធ្វើសម្បថរបស់ភ្នាក់ងារនគរបាលយុត្តិធម៌ ចុះថ្ងៃទី ២៩ ខែសីហា ឆ្នាំ២០០៧ |
| ៣ | គំរូសញ្ញាបត្រ និងវិញ្ញាបនបត្រ |

# តារាងឧបសម្ព័ន្ធទី ២

| **លេខរៀង** | **ឈ្មោះឯកសារពាក់ព័ន្ធ** |
|---|---|
| ១ | ពាក្យបណ្តឹង |
| ២ | ដីកាកោះរបស់មន្ត្រីនគរបាលយុត្តិធម៌ |
| ៣ | កំណត់ហេតុឆែកឆេរ |
| ៤ | កំណត់ហេតុស្តាប់បំភ្លឺគូភាគី |
| ៥ | កំណត់ហេតុស្តាប់បំភ្លឺចម្លើយសាក្សី |
| ៦ | កំណត់ហេតុស្តីពីការឃាត់ខ្លួន |
| ៧ | របាយការណ៍បញ្ជូនទៅព្រះរាជអាជ្ញា |
| ៨ | របាយការណ៍សំយោគ |
| ៩ | សំណើសុំធ្វើការពន្យារពេលឃាត់ខ្លួន |
| ១០ | កំណត់ហេតុស្តីពីការចាប់វត្ថុតាង |
| ១១ | ដីកាចាត់ឱ្យស៊ើបសួរជំនួស |

# តារាងឧបសម្ព័ន្ធទី ៣

| **លេខរៀង** | **ឈ្មោះឯកសារពាក់ព័ន្ធ** |
|---|---|
| ១ | ពាក្យ "**នគរបាលយុត្តិធម៌**" ដែលកំណត់ក្នុងក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ |

ឧបសម្ព័ន្ធទី១៖ ល.រ ទី១

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងយុត្តិធម៌ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

លេខ :០៥៤៨ភយ.ដនស.ប្រក/២១

**ប្រកាសអន្តរក្រសួង**

**ស្តីពី**

**ការផ្តល់នីតិសម្បទាជានគរបាលយុត្តិធម៌**

**រដ្ឋមន្ត្រី ក្រសួងយុត្តិធម៌** **ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នសរកម//០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នសរកម//១១១៩/០១៩ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសំណង់
- បានឃើញអនុក្រឹត្យលេខ២៤០ អនក្រ.បក ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ១៨០ អនក្រ.បក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៤ ស្តីពីការបង្កើតអគ្គនាយកដ្ឋានលំនៅឋានចំណុះក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញប្រកាសលេខ១៤១ ដនស/ប្រ.ក/នី.ក ចុះថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០២០ ស្តីពីការតែងតាំងមន្ត្រីអធិការកិច្ចសំណង់



មហាវិថីសម្តេចសុធារស.ខ័ណ្ឌដូនពេញ.រាជធានីភ្នំពេញ ទូរស័ព្ទ : 023 216 322, 023 217 841, 023 212 693

- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## សម្រេច

**ប្រការ១**.

ត្រូវបានផ្តល់នីតិសម្បទាជានគរបាលយុត្តិធម៌ ដល់មន្ត្រីអធិការកិច្ចសំណង់នៃអគ្គនាយកដ្ឋានសំណង់ អគ្គនាយកដ្ឋានរៀបចំដែនដីនិងនគរូបនីយកម្ម អគ្គនាយកដ្ឋានលំនៅឋាន និងមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ចំនួន ៣៦១ រូប ដូចមានរាយនាមខាងក្រោម៖

| ល.រ | គោត្តនាម-នាម | ភេទ | តួនាទី |
|---|---|---|---|
| I. **មន្ត្រីអធិការកិច្ចសំណង់ថ្នាក់ជាតិ** | | | |
| **ក.អគ្គនាយកដ្ឋានសំណង់** | | | |
| **១.ថ្នាក់ដឹកនាំអគ្គនាយកដ្ឋានសំណង់** | | | |
| ១ | ឆាន់ សុប្បផល | ប្រុស | អគ្គនាយក |
| ២ | ជា ផលរី | ប្រុស | អគ្គនាយករង |
| ៣ | ប៉ាក ចាន់ផល | ប្រុស | អគ្គនាយករង |
| ៤ | យ៉ាន់ វ៉ាន់ជីលុច | ប្រុស | អគ្គនាយករង |
| ៥ | ឆេង វ៉ាន់ថា | ប្រុស | អគ្គនាយករង |
| **២.នាយកដ្ឋានស្រាវជ្រាវបច្ចេកទេសសំណង់** | | | |
| ៦ | ជីវ ស៊ីវផេង | ប្រុស | ប្រធាននាយកដ្ឋាន |
| ៧ | ញ៉ ហេង | ប្រុស | អនុប្រធាននាយកដ្ឋាន |
| ៨ | ប៊ុល វ៉ានី | ប្រុស | អនុប្រធាននាយកដ្ឋាន |
| ៩ | លាង ហេងជ | ប្រុស | ប្រធានការិយាល័យបទដ្ឋាននិងបទប្បញ្ញត្តិស្ថាបត្យកម្ម |
| ១០ | ហេង ហាក់ | ប្រុស | អនុប្រធានការិយាល័យបទដ្ឋាននិងបទប្បញ្ញត្តិវិស្វកម្ម |
| ១១ | ឈង សុភ័ណ | ប្រុស | អនុប្រធានការិយាល័យបទដ្ឋាននិងបទប្បញ្ញត្តិវិស្វកម្ម |
| ១២ | ចាន់ ធម្ម | ប្រុស | អនុប្រធានការិយាល័យបទដ្ឋាននិងបទប្បញ្ញត្តិវិស្វកម្ម |

| ល.រ | គោត្តនាម-នាម | ភេទ | តួនាទី |
|---|---|---|---|
| ១៣ | តាំង ប៊ុណ្ណារិទ្ធ | ប្រុស | អនុប្រធានការិយាល័យបទដ្ឋាននិងបទប្បញ្ញត្តិវិស្វកម្ម |
| ១៤ | តន ធរី | ប្រុស | អនុប្រធានការិយាល័យបទដ្ឋាននិងបទប្បញ្ញត្តិស្ថាបត្យកម្ម |
| ១៥ | ផាត់ បូរី | ប្រុស | អនុប្រធានការិយាល័យបទដ្ឋាននិងបទប្បញ្ញត្តិស្ថាបត្យកម្ម |
| ១៦ | រ៉ែន កែវឡៃ | ប្រុស | អនុប្រធានការិយាល័យបទដ្ឋាននិងបទប្បញ្ញត្តិស្ថាបត្យកម្ម |
| ១៧ | ហុង ស្រ៊ុន | ប្រុស | អនុប្រធានការិយាល័យកិច្ចការទូទៅ ព័ត៌មានវិទ្យា និងឯកសារ |
| ១៨ | សូរ សាមី | ប្រុស | អនុប្រធានការិយាល័យកិច្ចការទូទៅ ព័ត៌មានវិទ្យា និងឯកសារ |
| ១៩ | ទែន សារឿន | ប្រុស | អនុប្រធានការិយាល័យកិច្ចការទូទៅ ព័ត៌មានវិទ្យា និងឯកសារ |
| ២០ | ម៉ាច ហ៊ួ | ប្រុស | មន្ត្រី |
| **៣.នាយកដ្ឋានសិក្សាគម្រោងប្លង់** | | | |
| ២១ | ឈៀក វីរៈ | ប្រុស | ប្រធាននាយកដ្ឋាន |
| ២២ | ជិន ឌៀប | ប្រុស | អនុប្រធាននាយកដ្ឋាន |
| ២៣ | ឱ វឌ្ឍនៈ | ប្រុស | អនុប្រធាននាយកដ្ឋាន |
| ២៤ | លឹម ប៉ូ | ប្រុស | អនុប្រធាននាយកដ្ឋាន |
| ២៥ | ឈុត សៅ | ប្រុស | អនុប្រធាននាយកដ្ឋាន |
| ២៦ | ជួរ ជិនសុជា | ប្រុស | អនុប្រធាននាយកដ្ឋាន |
| ២៧ | យឹម មុនី | ប្រុស | ប្រធានការិយាល័យស្ថាបត្យកម្ម |
| ២៨ | សេក សំខេមរា | ប្រុស | ប្រធានការិយាល័យវិស្វកម្មនិងកិច្ចការតម្លៃ |
| ២៩ | សូត្រ ពង្សវិចិត្រ | ប្រុស | ប្រធានការិយាល័យបែបបទអាជីវកម្ម |
| ៣០ | ដួង ស៊ីវុធ | ប្រុស | អនុប្រធានការិយាល័យវិស្វកម្មនិងកិច្ចការតម្លៃ |
| ៣១ | យី វុត្ថា | ប្រុស | អនុប្រធានការិយាល័យវិស្វកម្មនិងកិច្ចការតម្លៃ |
| ៣២ | ម៉ូវ ច័ន្ទម៉ារ៉ា | ប្រុស | អនុប្រធានការិយាល័យវិស្វកម្មនិងកិច្ចការតម្លៃ |
| ៣៣ | គីម សុគន្ធា | ប្រុស | អនុប្រធានការិយាល័យស្ថាបត្យកម្ម |
| ៣៤ | សុក ធី | ប្រុស | អនុប្រធានការិយាល័យស្ថាបត្យកម្ម |
| ៣៥ | សេក ច័ន្ទមុនី | ប្រុស | អនុប្រធានការិយាល័យស្ថាបត្យកម្ម |

| ល.រ | គោត្តនាម-នាម | ភេទ | តួនាទី |
|---|---|---|---|
| ៣៦ | ប៉េង អាន | ប្រុស | អនុប្រធានការិយាល័យបែបបទអាជីវកម្ម |
| **៤.នាយកដ្ឋានសំណង់** | | | |
| ៣៧ | ទិត ខេមរា | ប្រុស | ប្រធាននាយកដ្ឋាន |
| ៣៨ | អ៊ុំ សារុំ | ប្រុស | អនុប្រធាននាយកដ្ឋាន |
| ៣៩ | តាន់ហ៊ាង ហានីដា | ប្រុស | អនុប្រធាននាយកដ្ឋាន |
| ៤០ | មាឃ ពន្លក | ប្រុស | អនុប្រធាននាយកដ្ឋាន |
| ៤១ | ញ៉ែម វ៉ាឌី | ប្រុស | ប្រធានការិយាល័យជួសជុលនិងថែទាំ |
| ៤២ | រស់ សុភក្តិ | ប្រុស | ប្រធានការិយាល័យបច្ចេកទេសនិងត្រួតពិនិត្យ |
| ៤៣ | ឡេង សេដ្ឋា | ប្រុស | ប្រធានការិយាល័យបទប្បញ្ញត្តិការងារការដ្ឋាន |
| ៤៤ | ហេ ផាន់នី | ប្រុស | អនុប្រធានការិយាល័យបច្ចេកទេសនិងត្រួតពិនិត្យ |
| ៤៥ | ប៊ុន សីហាមានី | ប្រុស | អនុប្រធានការិយាល័យបច្ចេកទេសនិងត្រួតពិនិត្យ |
| ៤៦ | ហួង សុផាត | ប្រុស | អនុប្រធានការិយាល័យបច្ចេកទេសនិងត្រួតពិនិត្យ |
| ៤៧ | អ៊ុំ សុពុត្រា | ប្រុស | អនុប្រធានការិយាល័យបទប្បញ្ញត្តិការងារការដ្ឋាន |
| ៤៨ | ប៊ិង ឋារិទ្ធ | ប្រុស | អនុប្រធានការិយាល័យបទប្បញ្ញត្តិការងារការដ្ឋាន |
| ៤៩ | ឃួន ចាន់ | ប្រុស | អនុប្រធានការិយាល័យបទប្បញ្ញត្តិការងារការដ្ឋាន |
| ៥០ | គិត នាគសែន | ប្រុស | អនុប្រធានការិយាល័យបទប្បញ្ញត្តិការងារការដ្ឋាន |
| ៥១ | ស៊ុក តារាវុធ | ប្រុស | អនុប្រធានការិយាល័យជួសជុលនិងថែទាំ |
| ៥២ | ឌុច មុន្នីរក្ស | ប្រុស | អនុប្រធានការិយាល័យជួសជុលនិងថែទាំ |
| ៥៣ | ម៉ុម មុនី | ប្រុស | មន្ត្រី |
| ៥៤ | ខឹម ពិសី | ប្រុស | មន្ត្រី |
| ៥៥ | ឃុន សុធី | ប្រុស | មន្ត្រី |
| ៥៦ | ឡឿង បូឡេរ៉ូ | ប្រុស | មន្ត្រី |
| ៥៧ | រស់ សារ៉ាត់មុនី | ប្រុស | មន្ត្រី |
| ៥៨ | ធយ វណ្ណៈ | ប្រុស | មន្ត្រី |

| ល.រ | គោត្តនាម-នាម | ភេទ | តួនាទី |
|---|---|---|---|
| **ខ.អគ្គនាយកដ្ឋានរៀបចំដែនដីនិងនគរូបនីយកម្ម** | | | |
| **១.ថ្នាក់ដឹកនាំអគ្គនាយកដ្ឋានរៀបចំដែនដីនិងនគរូបនីយកម្ម** | | | |
| ៥៩ | ឆាយ ឫទ្ធិសែន | ប្រុស | អគ្គនាយក |
| ៦០ | សារ៉េត បូរ៉ាមី | ប្រុស | អគ្គនាយករង |
| ៦១ | ឈឹម សុគន្ធ | ប្រុស | អគ្គនាយករង |
| ៦២ | យី យ៉ាណារតន៍ | ប្រុស | អគ្គនាយករង |
| ៦៣ | លឹម អ៊ីវ | ប្រុស | អគ្គនាយករង |
| ៦៤ | ម៉េង ប៊ុណ្ណារិទ្ធ | ប្រុស | អគ្គនាយករង |
| **២.នាយកដ្ឋានស្រាវជ្រាវនិងបទប្បញ្ញត្តិ** | | | |
| ៦៥ | មៀង សុថា | ប្រុស | ប្រធាននាយកដ្ឋាន |
| ៦៦ | ចាប់ ច័ន្ទថេរា | ប្រុស | អនុប្រធាននាយកដ្ឋាន |
| ៦៧ | ចាន់ កុកអួង | ប្រុស | អនុប្រធាននាយកដ្ឋាន |
| ៦៨ | ឈឹម ណារី | ស្រី | អនុប្រធាននាយកដ្ឋាន |
| ៦៩ | អ៊ឹង ណារ៉េត | ប្រុស | អនុប្រធាននាយកដ្ឋាន |
| ៧០ | ហ៊ិន សត្យា | ប្រុស | អនុប្រធានការិយាល័យបទប្បញ្ញត្តិនគរូបនីយកម្ម |
| ៧១ | សាន សុភី | ប្រុស | អនុប្រធានការិយាល័យបទប្បញ្ញត្តិនគរូបនីយកម្ម |
| ៧២ | គង់ សុគន្ធា | ប្រុស | អនុប្រធានការិយាល័យទំនាក់ទំនងនិងកិច្ចការទូទៅ |
| ៧៣ | កែវ ដារីន | ប្រុស | អនុប្រធានការិយាល័យបទប្បញ្ញត្តិរៀបចំដែនដី |
| ៧៤ | សាយ ម៉ារុត | ប្រុស | មន្ត្រី |
| ៧៥ | ជុំ សំអាត | ប្រុស | មន្ត្រី |
| ៧៦ | ង៉ែត តារា | ប្រុស | មន្ត្រី |
| ៧៧ | សុង ឱុល | ប្រុស | មន្ត្រី |
| ៧៨ | កែ វុធនី | ប្រុស | មន្ត្រី |
| ៧៩ | គឹម កញ្ញា | ប្រុស | មន្ត្រី |

| ល.រ | គោត្តនាម-នាម | ភេទ | តួនាទី |
|---|---|---|---|
| ៨០ | ជាង សុងហៃ | ប្រុស | មន្ត្រី |
| ៨១ | តែ តាំងហ៊ាង | ប្រុស | មន្ត្រី |
| ៨២ | នៀម ប្រាក់ភូ | ប្រុស | មន្ត្រី |
| ៨៣ | មួន បញ្ញា | ប្រុស | មន្ត្រី |
| ៨៤ | ឈឹម ឈានី | ប្រុស | មន្ត្រី |
| **៣.នាយកដ្ឋាននគរូបនីយកម្ម** | | | |
| ៨៥ | សេក សុធីរិទ្ធ | ប្រុស | ប្រធាននាយកដ្ឋាន |
| ៨៦ | ប៉ុល ថាវិន្ត | ប្រុស | អនុប្រធាននាយកដ្ឋាន |
| ៨៧ | អ៊ុំ បូរិទ្ធ | ប្រុស | អនុប្រធាននាយកដ្ឋាន |
| ៨៨ | ម៉ៅ គ្រឹង | ប្រុស | អនុប្រធាននាយកដ្ឋាន |
| ៨៩ | ធាន់ សុជាតិ | ប្រុស | អនុប្រធាននាយកដ្ឋាន |
| ៩០ | អ៊ឹង វង្ហា | ប្រុស | អនុប្រធាននាយកដ្ឋាន |
| ៩១ | ញឹម ណារិនដេត | ស្រី | ប្រធានការិយាល័យនគរូបនីយកម្ម |
| ៩២ | អន ស៊ីថន | ប្រុស | អនុប្រធានការិយាល័យនគរូបនីយកម្ម |
| ៩៣ | អួន ពុទ្ធិគុណ | ប្រុស | អនុប្រធានការិយាល័យនគរូបនីយកម្ម |
| ៩៤ | សាន ស៊ីវត្ថា | ប្រុស | អនុប្រធានការិយាល័យបច្ចេកទេស |
| ៩៥ | ឆាយ គន្ធា | ប្រុស | មន្ត្រី |
| ៩៦ | សំ ភក្តី | ប្រុស | មន្ត្រី |
| ៩៧ | សៅ ប្រេម៉ា | ប្រុស | មន្ត្រី |
| ៩៨ | កៅ ទ្រូក | ប្រុស | មន្ត្រី |
| ៩៩ | ឈន សេង្ហា | ប្រុស | មន្ត្រី |
| ១០០ | អ៊ិត ច័ន្ទា | ប្រុស | មន្ត្រី |
| ១០១ | អ៊ុំ វណ្ណារិទ្ធ | ប្រុស | មន្ត្រី |
| ១០២ | លី សុវណ្ណ | ប្រុស | មន្ត្រី |

| មាត្រា ៧៩<br>**កំហុសដែលត្រូវបានប្រព្រឹត្តនៅក្នុងពេលបំពេញមុខងារ** | រាល់កំហុសទាំងឡាយដែលប្រព្រឹត្តដោយភ្នាក់ងារនគរបាលយុត្តិធម៌នៅក្នុងពេលបំពេញមុខងាររបស់ខ្លួនត្រូវតែឱ្យដំណឹងដោយព្រះរាជអាជ្ញា ឬដោយចៅក្រមស៊ើបសួរ ជូនចំពោះអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ។ យោងតាមករណីនីមួយៗអគ្គព្រះរាជអាជ្ញាប្រកាសប្រាប់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឬរដ្ឋមន្ត្រីក្រសួងការពារជាតិ ដើម្បីចាប់ផ្តើមនិតិវិធីខាងវិន័យ ។ អគ្គព្រះរាជអាជ្ញាត្រូវបានផ្តល់ដំណឹងអំពីចំណាត់ការបន្តនៃនិតិវិធីវិន័យ ។ |
| មាត្រា ៨០<br>**ទណ្ឌកម្មខាងវិន័យ** | ទណ្ឌកម្មខាងវិន័យរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឬរដ្ឋមន្ត្រីក្រសួងការពារជាតិ មិនមែនជាឧបសគ្គដល់ការធ្វើបណ្តឹងអាជ្ញាទេ ប្រសិនបើមានបទល្មើសណាមួយត្រូវបានប្រព្រឹត្ត ។<br>កាលណាភ្នាក់ងារនគរបាលយុត្តិធម៌ ប្រព្រឹត្តបទល្មើសនៅក្នុងការបំពេញមុខងាររបស់ខ្លួន តុលាការកំពូលអាចផ្ទេរអំណាចឱ្យទៅយុត្តាធិការផ្សេងចាត់ការវិញបាន ដើម្បីជាប្រយោជន៍ល្អដល់រដ្ឋបាលតុលាការ។<br>ពាក្យសុំដកសិទ្ធិនេះ ត្រូវបានធ្វើឡើងដោយព្រះរាជអាជ្ញា ។ |
| មាត្រា ៨១<br>**ការកំណត់សមត្ថកិច្ច** | ក្នុងវិស័យនគរបាលយុត្តិធម៌ នគរបាលជាតិ និងកងរាជអាវុធហត្ថ ត្រូវមានសមត្ថកិច្ចដូចមានចែងក្នុងមាត្រា ៥៦ (បេសកកម្មរបស់នគរបាលយុត្តិធម៌) នៃក្រមនេះ ។<br>លើសពីនេះទៅទៀត ចំពោះបទល្មើសយោធា មានតែកងរាជអាវុធហត្ថទេ ដែលមានគុណសម្បត្តិជានគរបាលយុត្តិធម៌ ។<br>កិច្ចប្រតិបត្តិការ និងកិច្ចសហប្រតិបត្តិការរវាងនាយនគរបាលជាតិ និងនាយទាហាននៃកងរាជអាវុធហត្ថក្នុងពេលបំពេញមុខងារជានគរបាលយុត្តិធម៌ ត្រូវកំណត់ដោយអនុក្រឹត្យ ។<br>អង្គភាពនគរបាលយុត្តិធម៌ ដែលមានសមត្ថកិច្ចថ្នាក់ជាតិអាចត្រូវបានបង្កើតឡើងដោយព្រះរាជក្រឹត្យ ។ |
| មាត្រា ៨២<br>**ការផ្តល់នីតិសម្បទាចំពោះមន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀត** | មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀតដែលច្បាប់ដោយឡែកប្រគល់ដោយឡែកប្រគល់អំណាចឱ្យពិនិត្យបទល្មើស ត្រូវដាក់ឱ្យស្ថិតក្រោមអំណាចរបស់ព្រះរាជអាជ្ញាក្នុងពេលបំពេញមុខងារនេះ ។<br>បែបបទ និងនីតិវិធីនៃការផ្តល់នីតិសម្បទាត្រូវកំណត់ដោយប្រកាសរួមរវាងក្រសួងយុត្តិធម៌ និងក្រសួងពាក់ព័ន្ធ។<br>មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀតត្រូវស្បថថា បំពេញមុខងាររបស់ខ្លួនដោយស្មោះត្រង់។ សម្បថត្រូវធ្វើនៅចំពោះមុខសាលាដំបូង ។ រូបមន្តនៃពាក្យសម្បថ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងយុត្តិធម៌ ។ |





| | |
|---|---|
| | ចំពោះការពិនិត្យបទល្មើស មន្ត្រីរាជការ និងភ្នាក់ងារទាំងនេះធ្វើរបាយការណ៍ ។ របាយការណ៍នេះមានតម្លៃត្រឹមតែព័ត៌មានធម្មតាប៉ុណ្ណោះ ។<br>រាល់កំហុសឡាយដែលប្រព្រឹត្តដោយមន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀតនៅក្នុងពេលបំពេញមុខងាររបស់ខ្លួន ត្រូវតែឱ្យដំណឹងដោយព្រះរាជអាជ្ញា ឬដោយចៅក្រមស៊ើបសួរជូន ចំពោះអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ។ អគ្គព្រះរាជអាជ្ញា ប្រកាសប្រាប់រដ្ឋមន្ត្រីដែលមន្ត្រី ឬភ្នាក់ងារនោះនៅក្រោមឱវាទដើម្បីចាប់ផ្តើមនីតិវិធីខាងវិន័យ ។ អគ្គព្រះរាជអាជ្ញាត្រូវបានផ្តល់ចំណាត់ការបន្តនៃនីតិវិធីវិន័យ ។ ទណ្ឌកម្មខាងវិន័យមិនមែនជាឧបសគ្គដល់ការធ្វើបណ្តឹងអាជ្ញាទេ ប្រសិនបើមានបទល្មើសត្រូវបានប្រព្រឹត្ត ។ |
| **គន្ថីទី ៣ ៖ ការស៊ើបអង្កេត**<br>**មាតិកាទី ១ ៖ បទប្បញ្ញត្តិទូទៅ** | |
| មាត្រា ៨៣<br>**ការសម្ងាត់នៃការស៊ើបអង្កេត** | ការស៊ើបអង្កេត ត្រូវតែជាការសម្ងាត់ ។ បុគ្គលទាំងឡាយដែលចូលរួមក្នុងការស៊ើបអង្កេត ជាពិសេសចៅក្រមខាងអយ្យការ មេធាវី ក្រឡាបញ្ជី នគរបាល កងរាជអាវុធហត្ថ មន្ត្រីរាជការ អ្នកជំនាញ អ្នកបកប្រែ គ្រូពេទ្យ និងបុគ្គលដែលមានសមត្ថកិច្ចដូចមានចែងក្នុងមាត្រា ៩៥ (ការត្រួតពិនិត្យខាង ផ្នែកបច្ចេកទេស ឬវិទ្យាសាស្ត្រ) នៃក្រមនេះ ត្រូវរក្សាការសម្ងាត់នៃវិជ្ជាជីវៈ ។<br>ប៉ុន្តែ ការគោរពនូវការសម្ងាត់វិជ្ជាជីវៈ មិនមែនជាឧបសគ្គដល់ការប្រើទសិទ្ធិនៃការការពារខ្លួនឡើយ ។<br>ម្យ៉ាងទៀត ព្រះរាជអាជ្ញាត្រូវបានអនុញ្ញាតឱ្យធ្វើសេចក្តីថ្លែងការណ៍ជាសាធារណៈ កាលណាខ្លួនយល់ឃើញថាព័ត៌មានដែលផ្សព្វផ្សាយពីរឿងណាមួយនោះជាព័ត៌មានមិនពិត ។<br>ការបំពានលើការសម្ងាត់នៃការស៊ើបអង្កេត គឺជាបទល្មើសដែលត្រូវផ្តន្ទាទោសតាមច្បាប់ព្រហ្មទណ្ឌជាធរមាន។ |
| មាត្រា ៨៤<br>**ភាពខុសគ្នានៃអំណាចរបស់មន្ត្រីនគរបាលយុត្តិធម៌ទៅតាមការស៊ើបអង្កេត** | អំណាចទាំងឡាយដែលផ្តល់ឱ្យមន្ត្រីនគរបាលយុត្តិធម៌ ខុសគ្នាទៅតាមពេលដែលមន្ត្រីនោះបំរើការក្នុងក្របខ័ណ្ឌនៃការស៊ើបអង្កេតជាក់ស្តែង ឬក្នុងក្របខ័ណ្ឌនៃការស៊ើបអង្កេតបឋម ។ |

**គន្ថីទី ៣ ៖ ការស៊ើបអង្កេត**

**មាតិកាទី ២ ៖ ការស៊ើបអង្កេតជាក់ស្តែង**

| | |
|---|---|
| មាត្រា ៨៥<br>**អំណាចរបស់មន្ត្រីនគរបាលយុត្តិធម៌នៅក្នុងករណីស៊ើបអង្កេតបទល្មើសជាក់ស្តែង** | ក្នុងករណីមានបទឧក្រិដ្ឋ ឬបទបជ្ឈិមជាក់ស្តែងមន្ត្រីនគរបាលយុត្តិធម៌ត្រូវតែគោរពតាមបទប្បញ្ញត្តិនៃមាតិកានេះ ។ |
| មាត្រា ៨៧<br>**ការចាប់ខ្លួនក្នុងករណីបទឧក្រិដ្ឋឬបទមជ្ឈិមជាក់ស្តែង** | ក្នុងករណីបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង គ្រប់បុគ្គលទាំងអស់អាចចាប់ខ្លួនជនល្មើស ហើយនាំជននោះទៅ ប្រគល់ជូនមន្ត្រីនគរបាលយុត្តិធម៌ដែលនៅជិតបំផុត។ |
| មាត្រា ៨៨<br>**ការចាត់ទុកដូចជាបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង** | ត្រូវបានចាត់ទុកដូចជាបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែងផងដែរ បើទោះបីជាស្ថិតនៅក្រៅពីករណី ដែលមានចែងក្នុងមាត្រា ៨៦ (និយមន័យបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង) ខាងលើនេះក៏ដោយ គ្រប់បទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែងទាំងឡាយណាដែលត្រូវបានប្រព្រឹត្តនៅក្នុងទីកន្លែងដែល អ្នកកាន់ កាប់នៅទីនោះ សុំឱ្យព្រះរាជអាជ្ញា ឬមន្ត្រីនគរបាលយុត្តិធម៌ចូលមកពិនិត្យ ឬភ្នាក់ងារ នគរបាលយុត្តិធម៌ក្នុងករណីដែលគ្មានមន្ត្រីនគរបាលយុត្តិធម៌នៅទីនោះ ។ ក្នុងករណីចុងក្រោយនេះភ្នាក់ងារនគរបាលយុត្តិធម៌ត្រូវរាយការណ៍ជាបន្ទាន់ជូនដល់មន្ត្រីនគរបាលយុត្តិធម៌ ។ |
| មាត្រា ៨៩<br>**វិធានដំបូងក្នុងករណីបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង** | ក្នុងករណីបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង មន្ត្រីនគរបាលយុត្តិធម៌ត្រូវរាយការណ៍ ភ្លាមជូនព្រះរាជអាជ្ញា ។<br>មន្ត្រីនគរបាលយុត្តិធម៌ចុះទៅកាន់ទីកន្លែងកើតហេតុដើម្បីធ្វើការពិនិត្យបទល្មើស។ មន្ត្រីនគរបាលយុត្តិធម៌ធានារ៉ាប់រងរក្សាទុកនូវតម្រុយនៃភស្តុតាងទាំងឡាយណាដែលអាចបាត់បង់។ មន្ត្រីនគរបាលយុត្តិធម៌ អាចហាមឃាត់បុគ្គលគ្រប់រូបកុំឱ្យទៅណាឆ្ងាយពីកន្លែងបទល្មើសរហូតដល់ពេលបញ្ចប់កិច្ចប្រតិបត្តិការរបស់ខ្លួន។<br>ប្រសិនបើយល់ឃើញថាមានប្រយោជន៍ ព្រះរាជអាជ្ញាចុះទៅកាន់កន្លែងកើតហេតុនិងដឹកនាំការស៊ើបអង្កេត ។ |





| | |
|---|---|
| | ប្រសិនបើមានការបន្ទាន់ ព្រះរាអាជ្ញាអាចអនុញ្ញាតឱ្យមន្ត្រីនគរបាលយុត្តិធម៌ណាម្នាក់ធ្វើប្រតិបត្តិការលើវិសាលភាពទាំងមូលនៃដែលដីជាតិ ដោយគោរពតាមលក្ខខណ្ឌទាំងឡាយដែល មានចែងក្នុងមាត្រា ៦៨ (ការពន្លាតសមត្ថកិច្ចដែនដី) នៃក្រមនេះ ។ |
| មាត្រា ៩០<br>**កំណត់ហេតុលើការស្រាវជ្រាវ និងការពិនិត្យ** | មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើកំណត់ហេតុស្តីពីការស្រាវជ្រាវ និងការពិនិត្យរបស់ខ្លួន ។ |
| មាត្រា ៩១<br>**ការឆែកឆេរ** | មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការឆែកឆេរបាន។ ក្នុងករណីនេះ មន្ត្រីនគរបាលយុត្តិធម៌ត្រូវទទួលជាបឋមនូវការអនុញ្ញាតពីព្រះរាជអាជ្ញាទោះបីជាការអនុញ្ញាតដោយផ្ទាល់មាត់ក៏ដោយ ។<br>មន្ត្រីនគរបាលយុត្តិធម៌ ត្រូវធ្វើការឆែកឆេរនៅចំពោះមុខអ្នកកាន់កាប់ទីកន្លែង ឬបើគ្មានអ្នកកាន់កាប់ទេ ត្រូវធ្វើនៅចំពោះមុខសាក្សីពីរនាក់។ សាក្សីត្រូវចាត់តាំងដោយមន្ត្រីនគរបាលយុត្តិធម៌ ។ សាក្សីមិនអាចជានគរបាល ឬក៏ជាកងរាជអាវុធហត្ថ ដែលជាកងកម្លាំងរួមប្រតិបត្តិការក្នុងការឆែកឆេរនោះបានឡើយ ។<br>មន្ត្រីនគរបាលយុត្តិធម៌ មិនអាចផ្តើមធ្វើការឆែកឆេរមុនម៉ោង ៦ (ប្រាំមួយ) ព្រឹក និងក្រោយម៉ោង ១៨ (ដប់ប្រាំបី) ឡើយ លើកលែងតែ :<br>– ក្នុងករណីដែលមានចែងដោយមាត្រា ៨៦ (និយមន័យបទឧក្រិដ្ឋ ឬបទបទមជ្ឈិមជាក់ស្តែង) នៃក្រមនេះ<br>– ក្នុងករណីដែងចែងដោយមាត្រា ៨៨ (ការចាត់ទុកដូចជាបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង) នៃក្រមនេះ<br>– ក្នុងករណីមានសំរែកស្រែកឱ្យគេជួយពីក្នុងទីកន្លែង<br>– ក្នុងករណីឆែកឆេរនៅទីកន្លែងក្នុងពេលម៉ោងដែលបើកចំហដល់សារធារណជន<br>– ក្នុងករណីឆែកឆេរនៅគ្រប់ទីកន្លែងដែលផលិត រក្សាទុក ជួញដូរ ចែកចាយ ប្រើប្រាស់គ្រឿងញៀន ។<br>មន្ត្រីនគរបាលយុត្តិធម៌ធ្វើកំណត់ហេតុស្តីពីការឆែកឆេរដែលនៅក្នុងនោះមានចុះ :<br>– ការអនុញ្ញាតរបស់ព្រះរាជអាជ្ញាដោយប្រាប់ថ្ងៃ និងម៉ោងនៃការអនុញ្ញាតនេះ<br>– អត្តសញ្ញាណរបស់អ្នកកាន់កាប់ទីកន្លែង ឬរបស់សាក្សីនីមួយៗ ។ |

| | |
|---|---|
| | មន្ត្រីនគរបាលយុត្តិធម៌ មិនអាចធ្វើការឆែកឆេរនៅក្នុងការិយាល័យមេធាវីបានទេ ។ មានតែព្រះរាជអាជ្ញា ឬចៅក្រមស៊ើបសួរតែប៉ុណ្ណោះ ដែលអាចធ្វើការឆែកឆេរនេះបាននៅចំពោះមុខប្រធានគណៈមេធាវី ឬប្រតិភូរបស់ប្រធានគណៈមេធាវី ឬមេធាវីសាមី។<br>មន្ត្រីនគរបាលយុត្តិធម៌ អាចធ្វើការឆែកឆេរនៅក្នុងអគារសារព័ត៌មាន សហគ្រាសនៃសារព័ត៌មានសរសេរ ឬសហគ្រាសសារព័ត៌មានសោតទស្សន៍ បានតែចំពោះមុខព្រះរាជអាជ្ញា ឬចៅក្រមស៊ើបសួរម្នាក់ ដែលធានារ៉ាប់រងកុំឱ្យការឆែកឆេរនេះ ប៉ះពាល់ដល់ការប្រកបដោយសេរីនូវមុខរបរអ្នកសារព័ត៌មាន និងធ្វើឱ្យយឺតយ៉ាវដល់ការផ្សព្វផ្សាយព័ត៌មាននេះដោយមិនត្រឹមត្រូវ ។ |
| មាត្រា ៩២<br>**ការបិទស្លាកបោះត្រាលើវត្ថុតាង** | មន្ត្រីនគរបាលយុត្តិធម៌ អាចចាប់យកវត្ថុតាង ។ មន្ត្រីនគរបាលយុត្តិធម៌ត្រូវបិទស្លាកបោះត្រានៅលើវត្ថុតាងនោះ ។ ក្រោយពីបានបង្ហាញវត្ថុដែលចាប់បានដល់អ្នកកាន់កាប់ទីកន្លែង ឬដល់សាក្សីពីរនាក់មើលរួច មន្ត្រីគរបាលយុត្តិធម៌ធ្វើកំណត់ហេតុស្ដីពីការចាប់យក ដែលរួមមានបញ្ជីសារពើភ័ណ្ឌនៃវត្ថុដែលចាប់ ។ កំណត់ហេតុស្ដីពីការចាប់យកត្រូវចុះហត្ថលេខា ឬផ្ដិតម្រាមដៃដោយអ្នកកាន់កាប់ទីកន្លែង ឬដោយសាក្សីពីនាក់ ។ |
| មាត្រា ៩៣<br>**កំណត់ហេតុលើការស្ដាប់ចម្លើយ** | មន្ត្រីនគរបាលយុត្តិធម៌ អាចហៅនិងនាំមកកាន់អង្គភាពរបស់ខ្លួននូវបុគ្គលគ្រប់រូបដែលសង្ស័យថាបានចូលរួមក្នុងបទល្មើស ។ មន្ត្រីនគរបាលយុត្តិធម៌ធ្វើការស្ដាប់ចម្លើយជនទាំងនោះ ។<br>ការស្ដាប់ចម្លើយនីមួយៗ ត្រូវមានធ្វើកំណត់ហេតុ ។<br>កំណត់ហេតុត្រូវដកស្រង់តាមដោយត្រឹមត្រូវនូវសេចក្ដីរាយការណ៍របស់បុគ្គលដែលផ្ដល់ចម្លើយ។ ក្នុងករណីចាំបាច់ មន្ត្រីនគរបាលយុត្តិធម៌ អាចរកអ្នកបកប្រែដែលស្បថថានិយាយការពិតស្របតាម ជំនឿ ឬសាសនាខ្លួន។ អ្នកបកប្រែមិនអាចជ្រើសរើសយកពីក្នុងចំណោមនគរបាល កងរាជអាវុធហត្ថ ឬបុគ្គលដែលទាក់ទិនក្នុងរឿងជាមួយគ្នាបានទេ ។<br>ទំព័រនីមួយៗនៃកំណត់ហេតុ ត្រូវចុះហត្ថលេខា ឬផ្ដិតម្រាមដៃដោយបុគ្គលដែលបានឆ្លើយ ។<br>មុននឹងចុះហត្ថលេខា ឬផ្ដិតម្រាមដៃ បុគ្គលនោះត្រូវអានកំណត់ហេតុឡើងវិញ ។ ក្នុងករណីចាំបាច់មន្ត្រីនគរបាលយុត្តិធម៌ត្រូវអាចដោយសំឡេងខ្លាំងៗ នូវខ្លឹមសារកំណត់ហេតុ ។<br>មន្ត្រីនគរបាលយុត្តិធម៌អាចហៅរកអ្នកបកប្រែបាន។ កាលណាបុគ្គលនោះមិនព្រមចុះហត្ថលេខា ឬមិនព្រមផ្ដិតម្រាមដៃទេ មន្ត្រីនគរបាលយុត្តិធម៌ត្រូវចុះនិទ្ទេសនៅក្នុងកំណត់ហេតុ ។ |





| | |
|---|---|
| មាត្រា ៩៤<br>**បទបញ្ជាឱ្យចូលខ្លួនក្នុងករណីការស៊ើបអង្កេតបទល្មើសជាក់ស្ដែង** | មន្ត្រីនគរបាលយុត្តិធម៌អាចកោះហៅ និងស្ដាប់ចម្លើយបុគ្គលគ្រប់រូបដែលផ្ដល់ព័ត៌មានស្ដីពីរឿងហេតុបាន។<br>បុគ្គលដែលកោះហៅនោះ ត្រូវចូលបង្ហាញខ្លួន ។ ក្នុងករណីរឹងទទឹង មន្ត្រីនគរបាលយុត្តិធម៌ ត្រូវជូនដំណឹងដល់ព្រះរាជអាជ្ញាដែលអាចចេញបញ្ជាឱ្យចូលខ្លួនបាន។ បញ្ជាឱ្យចូលខ្លួននេះ ត្រូវមានអត្តសញ្ញាណរបស់បុគ្គលដែលពាក់ព័ន្ធ មានចុះកាលបរិច្ឆេទ និងចុះហត្ថលេខាដោយព្រះរាជអាជ្ញា និងមានត្រាផង។ បញ្ជាឱ្យចូលខ្លួន អនុញ្ញាតឱ្យមន្ត្រីនគរបាលយុត្តិធម៌ប្រើប្រាស់កម្លាំងសាធារណៈដើម្បី បង្ខំបុគ្គលនោះឱ្យចូលបង្ហាញខ្លួន។ កថាខណ្ឌទី ២ ដល់ទី ៥ នៃមាត្រា ៩៣ (កំណត់ហេតុលើការ ស្ដាប់ចម្លើយ) នៃក្រមនេះ ត្រូវយកមកអនុវត្ត ។ |
| មាត្រា ៩៥<br>**ការត្រួតពិនិត្យខាងផ្នែកបច្ចេកទេស ឬវិទ្យាសាស្ត្រ** | ប្រសិនបើត្រូវការធ្វើការពិនិត្យបច្ចេកទេស ឬវិទ្យាសាស្ត្រដែលមិនអាចបង្អង់បាន មន្ត្រីនគរបាលយុត្តិធម៌អាចពឹងដល់បុគ្គលគ្រប់រូបដែលមានមុខជំនាញ។ ប្រសិនបើបុគ្គលនោះមិនទាន់បានចុះ ឈ្មោះនៅក្នុងបញ្ជីអ្នកជំនាញដែលចែងនៅមាត្រា ១៦៣ (បញ្ជីថ្នាក់ជាតិនៃអ្នកជំនាញ) នៃក្រមនេះទេ បុគ្គលនោះត្រូវស្បថតាមសាសនា ឬជំនឿរបស់ខ្លួនថា នឹងជួយដោយភក្ដីភាពដល់តុលារ ។ |
| មាត្រា ៩៦<br>**ការឃាត់ខ្លួន** | ដើម្បីឆ្លើយតបទៅនឹងតម្រូវការចាំបាច់នៃការស៊ើបអង្កេតមន្ត្រីនគរបាលយុត្តិធម៌ អាចឃាត់ខ្លួនបុគ្គលដែលសង្ស័យថាបានចូលរួមក្នុងបទល្មើស។ មន្ត្រីនគរបាលយុត្តិធម៌ក៏អាចឃាត់ខ្លួនបុគ្គល ដែលអាចផ្ដល់ព័ត៌មានស្ដីអំពីរឿងហេតុបានដែរ ប្រសិនបើលក្ខខណ្ឌខាងក្រោមនេះត្រូវបានបំពេញ :<br>– បុគ្គលដែលអាចផ្ដល់ព័ត៌មានប្រកែកមិនព្រមផ្ដល់ព័ត៌មាន<br>– មានការយល់ព្រមជាលាយលក្ខណ៍អក្សរឱ្យធ្វើការឃាត់ខ្លួនពីព្រះរាជអាជ្ញា ។<br>មន្ត្រីនគរបាលយុត្តិធម៌ត្រូវរាយការណ៍ភ្លាមជូនព្រះរាជអាជ្ញា ព្រមទាំងត្រូវបញ្ជូនគ្រប់ភស្តុតាងទាំងអស់ដែលតម្រូវឱ្យមានការឃាត់ខ្លួននេះ ។ ការឃាត់ខ្លួនមានថិរវេលា ៤៨ (សែសិបប្រាំបី) ម៉ោង ។ ថិរវេលាត្រូវគិតពីម៉ោងដែលសាមីខ្លួនមកដល់អង្គភាពនគរបាល ឬកងរាជអាវុធហត្ថ ។<br>ចំពោះបទឧក្រិដ្ឋ កាលណាមានតម្រុយដែលបង្ហាញឱ្យឃើញថា មានពិរុទ្ធភាពលើបុគ្គលដែលឃាត់ខ្លួន មន្ត្រីនគរបាលយុត្តិធម៌អាចពន្យារពេលឃាត់ខ្លួនបាន ប្រសិនបើវិធានការនេះជាការចាំបាច់ ដើម្បីឱ្យការស៊ើបអង្កេតប្រព្រឹត្តទៅបានល្អ ។ ការព្យារពេលនេះត្រូវសុំទៅព្រះរាជអាជ្ញា ដែលត្រូវផ្ទៀងផ្ទាត់មើលមូលកភាព ។ ការអនុញ្ញាតឱ្យពន្យារពេល |

| | |
|---|---|
| | ឃាត់ខ្លួនដែលធ្វើជាលាយលក្ខណ៍អក្សរ និងមានសំអាងហេតុត្រូវដាក់បញ្ចូនទៅក្នុងសំណុំរឿង ។ ការព្យារគឺជាវិធានការពិសេស ។ ការពន្យារនេះមិនអាចឱ្យលើសពី ២៤ (ម្ភៃបួន) ម៉ោងឡើយ ដោយមិនគិតពីថេរវេលា ចាំបាច់ក្នុងការដឹកជញ្ជូន ។<br>ការពន្យារមិនអាចត្រូវយល់ព្រមបានទេ ប្រសិនបើបុគ្គលដែលឃាត់ខ្លួននោះជាអនីតិជន ។<br>ចំពោះបទឧក្រិដ្ឋ អនីតិជនដែលមានអាយុពី ១៤ ឆ្នាំ ដល់ក្រោម ១៦ ឆ្នាំ មិនអាចត្រូវឃាត់ខ្លួនហួសរយៈពេល ៣៦ ម៉ោងឡើយ ។<br>ចំពោះបទមជ្ឈិម អនីតិជនដែលមានអាយុពី ១៤ ឆ្នាំ ដល់ក្រោម ១៦ ឆ្នាំ មិនអាចឃាត់ខ្លួនហួសរយៈពេល ២៤ ម៉ោងឡើយ ។<br>ចំពោះបទឧក្រិដ្ឋ អនីតិជនដែលមានអាយុពី ១៦ ឆ្នាំ ដល់ក្រោម ១៨ឆ្នាំមិនអាចត្រូវគេឃាត់ខ្លួនហួសរយៈពេល ៤៨ ម៉ោងឡើយ ។<br>ចំពោះបទមជ្ឈិម អនីតិជនដែលមានអាយុពី ១៦ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ មិនអាចត្រូវគេឃាត់ខ្លួនហួសរយៈពេល ៣៦ ម៉ោងឡើយ ។<br>អនីតិជនដែលមានអាយុក្រោម ១៤ ឆ្នាំ ពុំអាចត្រូវគេឃាត់ខ្លួនបានឡើយ ។ |
| មាត្រា ៩៧<br>**កំណត់ហេតុស្តីពីការឃាត់ខ្លួន** | កាលណាមានការឃាត់ខ្លួនបុគ្គលណាមួយ មន្ត្រីនគរបាលយុត្តិធម៌ត្រូវឱ្យដំណឹងជាបន្ទាន់អំពីសេចក្តីសម្រេចរបស់ខ្លួនដល់បុគ្គនោះដោយប្រាប់ឱ្យបានដឹងអំពីមូលហេតុនៃសេចក្តីសម្រេចឃាត់ខ្លួននេះ។ មន្ត្រីនគរបាលយុត្តិធម៌ប្រាប់ដល់សាមីខ្លួនឱ្យបានដឹងផងដែរ អំពីសិទ្ធិដែលបានចែងនៅមាត្រា ៩៨ (ជំនួយរបស់មេធាវីនៅក្នុងពេលឃាត់ខ្លួន) នៃក្រមនេះ។ ក្នុងករណីចាំបាច់ មន្ត្រីនគរបាលយុត្តិធម៌អាចហៅរកអ្នកបកប្រែ។ មន្ត្រីនគរបាលយុត្តិធម៌ធ្វើកំណត់ហេតុស្តីពីការឃាត់ខ្លួនជាបន្ទាន់ដោយមានចុះសេចក្តីដូចតទៅ:<br>– ឈ្មោះ និងឋានៈរបស់មន្ត្រីនគរបាលយុត្តិធម៌ដែលបានបង្គាប់ឱ្យឃាត់ខ្លួន<br>– អត្តសញ្ញាណនៃបុគ្គលដែលត្រូវឃាត់ខ្លួន<br>– មូលហេតុនៃការឃាត់ខ្លួន<br>– ថ្ងៃ ខែ ឆ្នាំ និងម៉ោងដែលផ្តើមឃាត់ខ្លួន<br>– ការឱ្យដំណឹងអំពីសិទ្ធិដែលបានបញ្ញត្តនៃមាត្រា ៩៨ (ជំនួយរបស់មេធាវីនៅក្នុងពេលឃាត់ខ្លួន)នៃក្រមនេះ<br>– ជាយថាហេតុ ឈ្មោះអ្នកបកប្រែ ។ |





| | |
|---|---|
| | កំណត់ហេតុនេះត្រូវមានចុះហត្ថលេខា ឬផ្តិតម្រាមដៃរបស់ជនឃាត់ខ្លួនក្រោយពីបានអានកំណត់ហេតុរួច ឬបើសាមីខ្លួនមិនចេះអក្សរ មន្ត្រីនគរបាលយុត្តិធម៌ត្រូវអានកំណត់ហេតុឱ្យស្តាប់។ ប្រសិនបើជននេះប្រកែកមិនព្រមចុះហត្ថលេខា ឬផ្តិតម្រាមដៃទេ មន្ត្រីនគរបាលយុត្តិធម៌ត្រូវចុះនិទ្ទេស។កំណត់ហេតុត្រូវភ្ជាប់ជាមួយសំណុំរឿង ។ |
| មាត្រា ៩៩<br>**ជំនួយរបស់គ្រូពេទ្យនៅក្នុងពេលឃាត់ខ្លួន** | ព្រះរាជអាជ្ញា ឬមន្ត្រីនគរបាលយុត្តិធម៌សុំឲ្យគ្រូពេទ្យមកពិនិត្យបុគ្គលិកដែលឃាត់ខ្លួនបានគ្រប់ពេលវេលា ។ គ្រូពេទ្យផ្ទៀងផ្ទាត់មើលថាតើស្ថានភាពសុខភាពនៃបុគ្គលឃាត់ខ្លួននោះសមស្របនឹងការឃាត់ខ្លួនដែរឬទេ ។<br>ប្រសិនបើគ្រូពេទ្យយល់ឃើញថា ស្ថានភាពរបស់សុខភាពរបស់បុគ្គលនោះពុំសមស្របជាមួយនឹង ការឃាត់ខ្លួនទេនោះ មន្ត្រីនគរបាលយុត្តិធម៌រាយការណ៍ជាបន្ទាន់ដល់ព្រះរាជអជ្ញា ។ គ្រូពេទ្យចេញវិញ្ញាបនប័ត្របញ្ជាក់សុខភាពដែលត្រូវភ្ជាប់ជាមួយសំណុំរឿង។ មន្ត្រីនគរបាលយុត្តិធម៌ ចុះនិទ្ទេសនៅលើកំណត់ហេតុអំពីឈ្មោះរបស់គ្រូពេទ្យ ព្រមទាំងថ្ងៃ ខែ ឆ្នាំ និងម៉ោងនៃការពិនិត្យសុខភាព ។<br>ព្រះរាជអជ្ញាអាចចុះទៅកាន់ទីកន្លែងផ្ទាល់ ដើម្បីផ្ទៀងផ្ទាត់នៃការឃាត់ខ្លួន ។ |
| មាត្រា ១០០<br>**អនីតិជនដែលត្រូវបានឃាត់ខ្លួន** | កាលណាបុគ្គលដែលត្រូវបានឃាត់ខ្លួនជាជាអនីតិជន មន្ត្រីនគរបាលយុត្តិធម៌ ត្រូវជូនពត៌មានតាមគ្រប់ មធ្យោបាយដល់ឪពុកម្តាយ ដល់អ្នកតំណាងស្របច្បាប់ ឬអ្នកទទួលភារកិច្ចលើអនីតិជននេះ។ |
| មាត្រា ១០១<br>**បញ្ជីនៃការឃាត់ខ្លួន** | នៅក្នុងកន្លែងនីមួយៗរបស់នគរបាល ឬកងរាជអាវុធហត្ថ ដែលសម្រាប់ទទួលជនដែលត្រូវឃាត់ខ្លួនត្រូវមានបញ្ជីស្តីពីការឃាត់ខ្លួននីមួយ ។<br>គ្រប់ការហាមឃាត់ត្រូវមានចុះនៅក្នុងបញ្ជីដោយមានសេចក្តីដូចតទៅនេះ :<br>– ឈ្មោះ និងឋានៈមន្ត្រីនគរបាលយុត្តិធម៌ដែលបានបង្គាប់ឲ្យធ្វើការឃាត់ខ្លួន<br>– អត្តសញ្ញាណរបស់បុគ្គលដែលឃាត់ខ្លួន<br>– ថ្ងៃ ខែ ឆ្នាំ និងម៉ោងដែលចាប់ផ្តើមឃាត់ខ្លួន និងបញ្ចប់ការឃាត់ខ្លួន<br>– ឈ្មោះ និងឋានៈរបស់ចៅក្រមដែលបានពិនិត្យបុគ្គលឃាត់ខ្លួនជាយថាហេតុ<br>– ឈ្មោះរបស់គ្រូពេទ្យដែលបានពិនិត្យបុគ្គលឃាត់ខ្លួនជាយថាហេតុ<br>– ប្រភេទនៃសេចក្តីសម្រេចចិត្តរបស់អជ្ញាធរតុលាការនៅពេលផុតកំណត់ការឃាត់ខ្លួន។<br>បញ្ជីនេះត្រូវកាន់កាប់ជាប្រចាំសម្រាប់ជូនអជ្ញាធរតុលាការតាមតម្រូវការ ។ |

| | |
|---|---|
| មាត្រា ១០២<br>**កំណត់ហេតុសរុបនៃការឃាត់ខ្លួន** | គ្រប់ប្រការឃាត់ខ្លួនត្រូវតែមានធ្វើកំណត់ហេតុសរុបនៃការឃាត់ខ្លួន ។<br>កំណត់ហេតុសរុបនេះត្រូវតែមានចុះនិទ្ទេសដូចតទៅ<br>– ឈ្មោះ និងឋានៈមន្ត្រីនគរបាលយុត្តិធម៌ដែលបង្គាប់ឲ្យឃាត់ខ្លួន<br>– អត្តសញ្ញាណរបស់បុគ្គលដែលត្រូវឃាត់ខ្លួន<br>– មូលហេតុនៃការឃាត់ខ្លួន<br>– ថ្ងៃ ខែ ឆ្នាំនិងម៉ោងដែលផ្តើមការឃាត់ខ្លួន<br>– បែបបទនៃការជូនដំណឹងដល់ព្រះរាជអជ្ញារ<br>– បែបបទនៃការជូនដំណឹងដោយអនុវត្តតាមមាត្រា១០០(អតិថិជនដែលត្រូវបានឃាត់ខ្លួន)នៃក្រមនេះ<br>– ឈ្មោះ គ្រូពេទ្យដែលបានពិនិត្យបុគ្គលឃាត់ខ្លួន<br>– អត្តសញ្ញាណរបស់ជនដែលបានសន្ទនាជាមួយបុគ្គលជាមួយបុគ្គលឃាត់ខ្លួនស្របតាមមាត្រា៩៨ (ជំនួយរបស់មេធាវីនៅក្នុងពេលឃាត់ខ្លួន)នៃក្រមនេះ<br>– ឈ្មោះ និងឋានៈរបស់ចៅក្រមដែលជាយថាហេតុបានអនុញ្ញាតឲ្យបន្តការឃាត់ខ្លួន<br>– ថិរវេលានៃការស្តាប់ចម្លើយនីមួយៗ និងថិរវេលានៃការសម្រាកដែលនៅចន្លោះការស្តាប់ចម្លើយ នីមួយៗ<br>– ថ្ងៃ ខែ ឆ្នាំ និងម៉ោងនៃការឃាត់ខ្លួន<br>– ប្រភេទនៃសេចក្តីសម្រេចចិត្តរបស់អជ្ញាធរតុលាការនៅពេលបញ្ចប់ការឃាត់ខ្លួន<br>– លក្ខខណ្ឌនៃការប្រព្រឹត្តិទៅនៃការឃាត់ខ្លួន ព្រមទាំងឧប្បហេតុជាយថាហេតុ ។<br>កំណត់ហេតុសរុបនៃការឃាត់ខ្លួនត្រូវភ្ជាប់ជាមួយសំណុំរឿង ។ |
| មាត្រា ១០៤<br>**រយៈពេលនៃការបញ្ជូនខ្លួន** | កាលណាបុគ្គលដែលត្រូវឃាត់ខ្លួន ត្រូវបញ្ជូនខ្លួនទៅព្រះរាជអាជ្ញានោះបុគ្គលនេះត្រូវបានគេនាំខ្លួនភ្លាមយកទៅចំពោះមុខព្រះរាជអាជ្ញា ។<br>ប្រសិនបើការបង្ហាញខ្លួនបុគ្គលដែលត្រូវបានឃាត់ខ្លួន ពុំអាចធ្វើបានក្នុងថ្ងៃតែមួយបានដោយសារមានមូលហេតុពិសេសដែលបណ្តាលមកពីការលំបាកក្នុងការដឹកជញ្ជូន ឬចំងាយផ្លូវនៃការដឹក ជញ្ជូននោះ រយៈពេលបន្ថែមអាចផ្តល់ឱ្យដោយព្រះរាជអាជ្ញាបាន ។ |





| | |
|---|---|
| | នៅក្នុងគ្រប់ករណីទាំងអស់ ការបង្ហាញខ្លួនបុគ្គលដែលត្រូវបានឃាត់ខ្លួនត្រូវធ្វើឡើងក្នុងរយៈពេលដ៏ឆាប់បំផុតតាមការដែលអាចធ្វើទៅបាន។<br>មូលហេតុនៃការយឺតយ៉ាវត្រូវចុះក្នុងកំណត់ហេតុ ដែលត្រូវប្រគល់ជូនព្រះរាជអាជ្ញាដោយមន្ត្រីនគរបាលយុត្តិធម៌ ។ |
| មាត្រា ១០៥<br>**ការហាមឃាត់មិនឱ្យស្តាប់ដោយឯកឯងជាអាទិ៍** | មន្ត្រីនគរបាលយុត្តិធម៌ ពុំមានអំនាចបង្គាប់ឱ្យស្តាប់ និងថតសម្លេងការសន្ទនាតាមទូរសព្ទ័ឡើយ។ មន្ត្រីនគរបាលយុត្តិធម៌ ពុំមានអំណាចបង្គាប់ឱ្យចាប់ និងថតការឆ្លើយឆ្លងដែលចេញតាមមធ្យោបាយទូរគមនាគមន៍ជាអាទិ៍សារតាមទូរសារ ឬសារតាមអិនធើណែត ។ |
| មាត្រា ១០៦<br>**ថិរវេលានៃការស៊ើបអង្កេតករណីជាក់ស្តែង** | ថិរវេលានៃការស៊ើបអង្កេតបទល្មើសជាក់ស្តែង មិនអាចលើសពី៧ (ប្រាំពីរ) ថ្ងៃ គិតពីថ្ងៃប្រព្រឹត្តិបទល្មើស ។ កិច្ចស៊ើបអង្កេតត្រូវប្រព្រឹត្តទៅជាប់ជានិច្ចនៅក្នុងថិរវេលានេះ។ ប្រសិនបើការស៊ើបអង្កេតមិនបានបញ្ចប់ក្នុងរយៈពេល ៧ (ប្រាំពីរ) ថ្ងៃនោះទេ មន្ត្រីនគរបាលយុត្តិធម៌ ត្រូវស្នើសុំយោបល់ទៅព្រះរាជអាជ្ញា ។ |
| មាត្រា ១០៧<br>**ការបញ្ជូនកំណត់ហេតុទៅព្រះរាជអាជ្ញា** | ក្រោយបញ្ចប់ការស៊ើបអង្កេត មន្ត្រីនគរបាលយុត្តិធម៌ត្រូវបញ្ជូនកំណត់ហេតុ និងវត្ថុតាងទាំងអស់ទៅព្រះរាជអាជ្ញា ។ កាលណាបុគ្គលណាមួយត្រូវបញ្ជូនទៅព្រះរាជអាជ្ញា នោះការបញ្ជូនកំណត់ហេតុ និងវត្ថុតាងត្រូវធ្វើជាមួយការបញ្ជូនខ្លួនបុគ្គលនោះដែរ ។ |
| មាត្រា ១០៨<br>**និទ្ទេសដែលត្រូវចុះនៅក្នុងកំណត់ហេតុ** | កំណត់ហេតុដែលធ្វើដោយមន្ត្រីនគរបាលយុត្តិធម៌ត្រូវចុះ :<br>– ឈ្មោះ និងឋានៈរបស់មន្ត្រីនគរបាលយុត្តិធម៌<br>– អង្គភាពរបស់មន្ត្រីនោះ<br>– កាលបរិច្ឆេទ<br>ទំព័រនីមួយៗ ត្រូវចុះហត្ថលេខាដោយមន្ត្រីនគរបាលយុត្តិធម៌។<br>ពាក្យឆូតលុប និងការយោងត្រូវមានបញ្ជាក់យល់ព្រមដោយមានចុះហត្ថលេខារបស់មន្ត្រីនគរបាលយុត្តិធម៌នៅរឹមទំព័រ ។<br>កំណត់ហេតុស្តីពីការស្តាប់ចម្លើយ ឬស្តីពីការឃាត់ខ្លួនត្រូវមានអត្តសញ្ញាណរបស់បុគ្គលដែលពាក់ព័ន្ធ ។ |

| | |
|---|---|
| មាត្រា ១១០<br>**អំណាចធ្វើមូលវិចារណ៍របស់** | តាមគោលការណ៍កំណត់ហេតុមានតម្លៃគ្រាន់តែជាព័ត៌មានប៉ុណ្ណោះ។ ប៉ុន្តែកំណត់ហេតុរបស់មន្ត្រីនគរបាលយុត្តិធម៌ត្រូវទុកជាបន្ទាល់ ឯកសារដើម មានន័យថាត្រូវទុកជាឯកសារដែលត្រូវជឿរហូតដល់មានភស្តុតាងផ្ទុយ ។ ភស្តុតាងផ្ទុយអាចជូនមកចៅក្រមបានដោយសេរី តាមគ្រប់មធ្យោបាយ ត្រឹមត្រូវតាមច្បាប់ ។<br>ចៅក្រមធ្វើមូលវិចារណ៍ដោយសេរី លើកំណត់ហេតុដែលធ្វើដោយមន្ត្រីនគរបាលយុត្តិធម៌ក្នុងក្របខណ្ឌនៃការស៊ើបអង្កេតបទល្មើសជាក់ស្តែង ។ |

**គន្លឹទី ៣ ៖ ការស៊ើបអង្កេត**

**មាតិកាទី ៣ ៖ ការស៊ើបអង្កេតបឋម**

| | |
|---|---|
| មាត្រា ១១១<br>**ការបើកការស៊ើបអង្កេតបឋម** | កាលណាបានដឹងអំពីដែលអាចជាបទឧក្រិដ្ឋ ឬបទមជ្ឈិម ឬបទពហុ មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការស៊ើបអង្កេតបឋមដោយឯកឯង ឬតាមការសុំរបស់ព្រះរាជអាជ្ញា ។ |
| មាត្រា១១៣<br>**ការឆែកឆេរ** | កាលណាការស៊ើបអង្កេតបឋមនោះ ទាក់ទងនឹងបទឧក្រិដ្ឋ ឬបទមជ្ឈិម មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការឆែកឆេរ និងចាប់យកវត្ថុតាង ។<br>មន្ត្រីនគរបាលយុត្តិធម៌ ជាបឋមត្រូវទទួលការយល់ព្រមច្បាស់លាស់ និងពិតប្រាកដពីអ្នកកាន់កាប់ទីកន្លែង ។<br>ការយល់ព្រមនេះត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរសរសេរដោយផ្ទាល់ដៃរបស់អ្នកកាន់កាប់ទីកន្លែង។ ប្រសិនបើអ្នកកាន់កាប់ទីកន្លែងមិនចេះអក្សរ នោះត្រូវសរសេរឱ្យបានច្បាស់លាស់ក្នុងកំណត់ ហេតុថា អ្នកកាន់កាប់ទីកន្លែងនោះមិនចេះអក្សរ ហើយយល់ព្រមឱ្យឆែកឆេរ ។<br>ក្នុងករណីដែលអ្នកកាន់កាប់ទីកន្លែងអវត្តមាន ឬបដិសេធការឆែកឆេរ ប្រធានសាលាដំបូងដែលមានសមត្ថ កិច្ចដែនដី អាចចេញដីកាអនុញ្ញាតឱ្យឆែកឆេរ តាមការសុំរបស់ព្រះរាជអាជ្ញា ។ ព្រះរាជអាជ្ញា ត្រូវដឹកនាំដោយផ្ទាល់នូវការឆែកឆេរនេះ។ ការឆែកឆេរត្រូវធ្វើនៅចំពោះមុខអ្នកកាន់កាប់ទីកន្លែង ឬបើគ្មានអ្នកកាន់កាប់ទេត្រូវធ្វើចំពោះមុខសាក្សីពីរនាក់។ សាក្សីត្រូវចាត់តាំងដោយព្រះរាជអាជ្ញា ។ សាក្សីមិនអាចជានគរបាល ឬជាកងរាជអាវុធហត្ថដែលជាកងកម្លាំងរួមប្រតិបត្តិការក្នុងការឆែកឆេរនោះឡើយ ។ ការឆែកឆេរមិនអាចផ្តើមមុនម៉ោង ៦ (ប្រាំមួយ) ព្រឹក និងក្រោយម៉ោង ១៨ (ដប់ប្រាំបី) ឡើយ ។<br>បទប្បញ្ញត្តិនៃមាត្រា ៩២ (ការបិទស្លាកបោះត្រាលើវត្ថុតាង)នៃក្រមនេះ ត្រូវយកមកអនុវត្តក្នុងការចាប់យក វត្ថុតាង ។ |





| | |
|---|---|
| | |
| មាត្រា ១១៤<br>**ការបញ្ជាឱ្យចូលខ្លួន ការស៊ើបអង្កេតបឋម** | មន្ត្រីនគរបាលយុត្តិធម៌អាចកោះហៅ និងស្តាប់ចម្លើយបុគ្គលគ្រប់រូបដែលត្រូវបានសង្ស័យថាបានចូលរួមក្នុងបទល្មើស ឬដែលអាចផ្តល់ព័ត៌មានស្តីពីរឿងហេតុ ។<br>បុគ្គលដែលកោះហៅត្រូវចូលមកបង្ហាញខ្លួន។ ក្នុងករណីរឹងទទឹងមន្ត្រីនគរបាលយុត្តិធម៌ជូនដំណឹងដល់ព្រះរាជអាជ្ញាដែលអាចចេញបញ្ជាឱ្យចូលខ្លួន។ បញ្ជាឱ្យចូលខ្លួននេះត្រូវមានចុះអត្តសញ្ញាណបុគ្គលពាក់ព័ន្ធ កាលបរិច្ឆេទ និងចុះហត្ថលេខា ដោយព្រះរាជអាជ្ញា និងមានបោះត្រា ។<br>បញ្ជាឱ្យចូលខ្លួន អនុញ្ញាតឱ្យមន្ត្រីនគរបាលយុត្តិធម៌ប្រើប្រាស់កងកម្លាំងសាធារណៈដើម្បីបង្ខំឱ្យបុគ្គលនោះឱ្យចូលបង្ហាញខ្លួន ។ |
| មាត្រា ១១៥<br>**កំណត់ហេតុស្រង់ចម្លើយការស៊ើបអង្កេតបឋម** | ការស្តាប់ចម្លើយនីមួយៗ ត្រូវមានធ្វើកំណត់ហេតុ ។<br>កំណត់ហេតុត្រូវដកស្រង់ដោយត្រឹមត្រូវតាមចម្លើយរបស់បុគ្គលពាក់ព័ន្ធ ។ ក្នុងករណីចាំបាច់ មន្ត្រីនគរបាលយុត្តិធម៌ អាចហៅរកអ្នកបកប្រែដែលបានស្បថស្របតាមសាសនា ឬជំនឿរបស់ខ្លួនថាខ្លួននឹងបកប្រែឱ្យបានត្រឹមត្រូវ ។ អ្នកបកប្រែមិនអាចត្រូវបានជ្រើសរើសក្នុងចំណោមនគរបាល កងរាជអាវុធហត្ថ ឬបុគ្គលដែលពាក់ព័ន្ធនៅក្នុងរឿងជាមួយទេ ។ |
| មាត្រា ១១៨<br>**អំណាចធ្វើមូលវិចារណ៍របស់ចៅក្រម** | តាមគោលការណ៍ កំណត់ហេតុមានតម្លៃគ្រាន់តែជាព័ត៌មានប៉ុណ្ណោះ។ ប៉ុន្តែ កំណត់ហេតុរបស់មន្ត្រីនគរបាលយុត្តិធម៌ត្រូវទុកជាបន្ទាល់ "ឯកសារដើម" មានន័យថាត្រូវទុកឮជាឯកសារដែលត្រូវជឿរហូតដល់មានភស្តុតាងផ្ទុយ ។ ភស្តុតាងផ្ទុយអាចជូនមកចៅក្រមបានដោយសេរី តាមគ្រប់មធ្យោបាយត្រឹមត្រូវតាមច្បាប់ ។<br>ចៅក្រមធ្វើមូលវិចារណ៍ដោយសេរីលើកំណត់ហេតុដែលធ្វើដោយមន្ត្រីនគរបាលយុត្តិធម៌ក្នុងក្របខ័ណ្ឌនៃស៊ើបអង្កេតបឋម ។ |

**គន្លឹទី ៤ ៖ ការស៊ើបសួរ**

**មាតិកាទី ១ ៖ ចៅក្រមស៊ើបសួរ**

| | |
|---|---|
| មាត្រា ១២១<br>**ការសម្ងាត់នៃការស៊ើបសួរ** | ការស៊ើបសួរត្រូវតែជាការសម្ងាត់ ។ |

| | |
|---|---|
| | បុគ្គលទាំងឡាយដែលចូលរួមក្នុងការស៊ើបសួរ ជាពិសេសចៅក្រម មេធាវី ក្រឡាបញ្ជី នគរបាល កងរាជ អាវុធហត្ថ មន្ត្រីរាជការ អ្នកជំនាញ អ្នកបកប្រែ គ្រូពេទ្យ និងបុគ្គលដែលមាន សមត្ថកិច្ច ដូចចែងក្នុងមាត្រា ៩៥ (ការត្រួតពិនិត្យខាងផ្នែកបច្ចេកទេស ឬវិទ្យាសាស្ត្រ) នៃក្រមនេះត្រូវរក្សា ការសម្ងាត់នៃវិជ្ជាជីវៈ ។<br>ប៉ុន្តែ ការគោរពនូវការសម្ងាត់វិជ្ជាជីវៈ មិនអាចជាឧបសគ្គដល់ការប្រើសិទ្ធិនៃការការពារខ្លួនឡើយ ។<br>ម្យ៉ាងទៀតព្រះរាជអាជ្ញាអាចធ្វើសេចក្តីថ្លែងការណ៍ជាសាធារណៈ កាលណាខ្លួនយល់ឃើញថាព័ត៌មានដែលផ្សព្វផ្សាយពីរឿងណាមួយនោះ ជាព័ត៌មានមិនពិត ។<br>មាត្រា ១៣១ ដីកាចាត់ឱ្យស៊ើបសួរជំនួស<br>ចៅក្រមស៊ើបសួរអាចសុំឱ្យចៅក្រមផ្សេង ឬមន្ត្រីនគរបាលយុត្តិធម៌ឬអង្គភាពនគរបាលយុត្តិធម៌ បំពេញកិច្ចខ្លះតាមដីកាចាត់ឱ្យស៊ើបសួរជំនួស នៅក្នុងលក្ខខណ្ឌដែលមានចែងនៅមាត្រា ១៧៣ (ដីកាចាត់ ឱ្យស៊ើបសួរជំនួស) ដល់មាត្រា ១៨៤ (កំណត់ហេតុកសាងដោយមន្ត្រីនគរបាល យុត្តិធម៌) នៃក្រមនេះ ។ |
| មាត្រា ១៤៤<br>**ជំនួយរបស់អ្នកបកប្រែ** | ក្នុងករណីចាំបាច់ ចៅក្រមស៊ើបសួរត្រូវហៅរកអ្នកបកប្រែ ។<br>អ្នកបកប្រែត្រូវស្បថស្របតាមសាសនា ឬជំនឿរបស់ខ្លួនថា ខ្លួននឹងជួយដល់តុលាការ និងបកប្រែឱ្យបានត្រឹមត្រូវតាមចម្លើយទាំងឡាយ។ ក្នុងករណីណាក៏ដោយអ្នកបកប្រែមិនអាចត្រូវ ជ្រើសរើសក្នុងចំណោមចៅក្រម ក្រឡាបញ្ជី នគរបាល កងរាជអាវុធហត្ថ ភាគី ឬសាក្សីទេ ។ |
| មាត្រា ១៥៩<br>**វិធានអនុវត្តចំពោះការឆែកឆេរ** | ចៅក្រមស៊ើបសួរអាចធ្វើការឆែកឆេរបាន ។<br>ចៅក្រមស៊ើបសួរត្រូវឆែកឆេរនៅចំពោះមុខអ្នកកាន់កាប់ទីកន្លែង ឬបើគ្មានអ្នកកាន់កាប់ទេ ត្រូវធ្វើនៅចំពោះមុខសាក្សី ២ (ពីរ) នាក់ដែលខ្លួនចាត់តាំង ។ សាក្សីមិនអាចជានគរបាល ឬជាកងរាជអាវុធហត្ថដែលជាកងកម្លាំងរួយប្រតិបត្តិការក្នុងការឆែក ឆេរនៅបានឡើយ ។<br>ចៅក្រមស៊ើបសួរមិនអាចផ្តើមឆែកឆេរមុនម៉ោង ៦ (ប្រាំមួយ) ព្រឹក និងក្រោយម៉ោង ១៨ (ដប់ប្រាំបី) បានទេលើកលែងតែ :<br>– ក្នុងករណីឆែកឆេរនៅទីកន្លែងដែលបើកចំហដល់សាធារណជន<br>– ក្នុងករណីឆែកឆេរនៅគ្រប់ទីកន្លែងដែលផលិតរក្សាទុកជួញដូរ ចែកចាយ ឬប្រើប្រាស់គ្រឿងញៀន។ |





| | |
|---|---|
| | ការឆែកឆេរនៅក្នុងការិយាល័យមេធាវី ត្រូវធ្វើនៅចំពោះមុខប្រធានគណៈមេធាវី ឬប្រតិភូរបស់ប្រធានគណៈមេធាវីនោះ ។<br>ចៅក្របស៊ើបសួរត្រូវធ្វើកំណត់ហេតុស្តីពីការឆែកឆេរដោយមានចុះហត្ថលេខារបស់ខ្លួន និងក្រឡាបញ្ជីរួមជាមួយអ្នកកាន់កាប់ទីកន្លែង ឬសាក្សី ២ (ពីរ) នាក់ ។<br>កំណត់ហេតុត្រូវចុះនិទ្ទេស អំពីអត្តសញ្ញាណរបស់អ្នកកាន់កាប់ទីកន្លែង ឬសាក្សីនីមួយៗ ។ ការបើការឆែកឆេរប្រព្រឹត្តទៅនៅក្នុងការិយាល័យមេធាវីកំណត់ហេតុត្រូវចុះនិទ្ទេសអំពីវត្តមានរបស់ប្រធានគណៈមេធាវីឬរបស់ប្រតិភូនៃប្រធានគណៈមេធាវីនេះ។ |
| មាត្រា ១៧១<br>**សោហ៊ុយសម្រាប់ធ្វើកោសលវិច័យ** | សោហ៊ុយក្នុងការធ្វើកោសលវិច័យជាបន្ទុករបស់អ្នកស្នើសុំ ។<br>កាលណាចៅក្រមស៊ើបសួរ ព្រះរាជអាជ្ញា ឬមន្ត្រីនគរបាលយុត្តិធម៌ ស្នើសុំឱ្យធ្វើកោសលវិច័យកោសលវិច័យបន្ថែម ឬធ្វើប្រតិកោសលវិច័យ សោហ៊ុយទាំងនេះជាបន្ទុករបស់រដ្ឋ ។ |
| មាត្រា ១៧៣<br>**ដីកាចាត់ឱ្យស៊ើបសួរជំនួស** | តាមរយៈដីកាចាត់ឱ្យស៊ើបសួរជំនួសចៅក្រមស៊ើបសួរអាចប្រគល់សិទ្ធិឱ្យចៅក្រមនៃតុលាការរបស់ខ្លួនឬតុលាការផ្សេងទៀត មន្ត្រីនគរបាលយុត្តិធម៌ ឬដល់អង្គភាពនគរបាលយុត្តិធម៌ដើម្បីបំពេញកិច្ចស៊ើបសួរ ។ |
| មាត្រា ១៧៦<br>**ដីកាចាត់ឱ្យស៊ើបសួរជំនួសចេញឱ្យមន្ត្រីនគរបាលយុត្តិធម៌** | កាលណាដីកាចាត់ឱ្យស៊ើបសួរជំនួសត្រូវបានប្រគល់ឱ្យដល់មន្ត្រីនគរបាលយុត្តិធម៌ នោះមន្ត្រីនគរបាលយុត្តិធម៌ប្រើប្រាស់អំណាចដែលមានចែងនៅក្នុងមាត្រា ១៧៦ (កំណត់ហេតុស្តីពីការស្រាវជ្រាវ និងការពិនិត្យ) ដល់មាត្រា ១៨៤ (កំណត់ហេតុកសាងដោយមន្ត្រីនគរបាលយុត្តិធម៌) នៃក្រមនេះ ។<br>ចំពោះការអនុវត្តដីកាចាត់ឱ្យស៊ើបសួរជំនួល មន្ត្រីនគរបាលយុត្តិធម៌ស្ថិតនៅក្រោមអំណាចចៅក្រមស៊ើបសួរហើយត្រូវរាយការណ៍ជូនចៅក្រមនេះតែប៉ុណ្ណោះ ។ |
| មាត្រា ១៧៧<br>**ការប្រតិបត្តិដីកាចាត់ឱ្យស៊ើបសួរជំនួសដោយមន្ត្រីនគរបាលយុត្តិធម៌** | មន្ត្រីនគរបាលយុត្តិធម៌បំពេញកិច្ចដែលមានចែងនៅក្នុងដីកាចាត់ឱ្យស៊ើបសួរជំនួស នៅក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួនលើកលែងតែបទប្បញ្ញត្តិនៃកថាខណ្ឌទី ២ និងទី ៣ មាត្រា ៦៨ (ការពន្លាតសមត្ថកិច្ចដែនដី) នៃក្រមនេះ ។ |

| | |
|---|---|
| មាត្រា ១៧៨<br>**កំណត់ហេតុស្តីពីការស្រាវជ្រាវ និងការពិនិត្យ** | មន្ត្រីនគរបាលយុត្តិធម៌ធ្វើកំណត់ហេតុស្តីពីការស្រាវជ្រាវ និងការពិនិត្យរបស់ខ្លួន ។ |
| មាត្រា ១៧៩<br>**វិធានទាក់ទងនឹងការស្តាប់ចម្លើយដែលធ្វើឡើងដោយមន្ត្រីនគរបាលយុត្តិធម៌** | មន្ត្រីនគរបាលយុត្តិធម៌អាចកោះហៅ និងស្តាប់ចម្លើយសាក្សី ។<br>មុននឹងឆ្លើយចំពោះសំណួរ សាក្សីម្នាក់ៗត្រូវស្បថតាមសាសនា ឬជំនឿរបស់ខ្លួនថា និយាយតែការពិត ។ ប៉ុន្តែសាក្សីដែលមានរៀបរាប់នៅមាត្រា ១៥៦ (សាក្សីដែលអនុញ្ញាតឱ្យរួចពីសម្បថ) ត្រូវបាន លើកលែងមិនបាច់ធ្វើសម្បថ ។ ដើម្បីគោរពសិទ្ធិការពារខ្លួន មន្ត្រីនគរបាលយុត្តិធម៌មិនអាចស្តាប់ចម្លើយក្នុងឋានៈជាសាក្សី នូវបុគ្គលណាមួយដែលមានតម្រុយនៃពិរុទ្ធភាពលើបុគ្គលនោះទេ ។ កាលណាការស្តាប់ចម្លើយសាក្សីណាម្នាក់ បានធ្វើឱ្យលេចតម្រុយនៃពិរុទ្ធភាពលើសាក្សីនោះ មន្ត្រីនគរបាលយុត្តិធម៌ត្រូវបញ្ឈប់ការស្តាប់ ហើយត្រូវរាយការណ៍ជូនចៅក្រមស៊ើបសួរ ។ មន្ត្រីនគរបាលយុត្តិធម៌អាចហៅរកអ្នកបកប្រែដែលបានស្បថស្របតាមសាសនា ឬជំនឿរបស់ខ្លួនថា ខ្លួននឹងជួយបកប្រែជូនតុលាការឱ្យបានត្រឹមត្រូវ ។<br>បុគ្គលដែលបានកោះហៅក្នុងឋានៈជាសាក្សី ត្រូវតែចូលបង្ហាញខ្លួន ។ ក្នុងករណីរឹងទទឹងមន្ត្រីនគរបាលយុត្តិធម៌រាយការណ៍ជូនចៅក្រមស៊ើបសួរ ដែលអាចចេញបញ្ជាឱ្យចូលខ្លួនដោយមានចុះអត្តសញ្ញាណនៃសាក្សី ។ បញ្ជានេះត្រូវមានចុះកាលបរិច្ឆេទ និងហត្ថលេខាដោយចៅក្រមស៊ើបសួរ និងមានបោះត្រាផង ។ បញ្ជាឱ្យចូលបង្ហាញខ្លួន អនុញ្ញាតឱ្យមន្ត្រីនគរបាលយុត្តិធម៌ប្រើប្រាស់កម្លាំងសាធារណៈ ដើម្បី បង្ខំឱ្យសាក្សីខ្លួនចំពោះមុខខ្លួន ។<br>កថាខណ្ឌទី ២ ដល់ទី ៥ នៃមាត្រា ៩៣ (កំណត់ហេតុលើការស្តាប់ចម្លើយ) នៃក្រមនេះ ត្រូវយកមកអនុវត្តលើកំណត់ហេតុស្តីពីការស្តាប់ចម្លើយសាក្សី ។ |
| មាត្រា ១៨០<br>**ការស្តាប់ចម្លើយដែលពុំអាចធ្វើឡើងដោយមន្ត្រីនគរបាលយុត្តិធម៌** | មន្ត្រីនគរបាលយុត្តិធម៌មិនអាចសួរចម្លើយជនត្រូវចោទ ឬស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណីបានទេ ។ |
| មាត្រា ១៨១<br>**ការឆែកឆេរ និងការចាប់យក ដែលធ្វើឡើងដោយមន្ត្រីនគរបាលយុត្តិធម៌** | មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការឆែកឆេរ និងចាប់យកវត្ថុតាងនៅក្នុងលក្ខខណ្ឌដែលចែងនៅក្នុងមាត្រា ៩១ (ការឆែកឆេរ) និងមាត្រា ៩២ (ការបិទស្លាកបោះត្រាលើវត្ថុតាង) នៃក្រមនេះ ។ ប៉ុន្តែការអនុញ្ញាតដែលមានចែងនៅក្នុងវាក្យខណ្ឌទី ២ កថាខណ្ឌទី ១ មាត្រា ៩១ (ការឆែកឆេរ) នៃក្រមនេះ ត្រូវតែផ្តល់ឱ្យដោយចៅក្រមស៊ើបសួរ ។ |





| | |
|---|---|
| មាត្រា ១៨៣<br>**ការស្តាប់ទូរស័ព្ទ ជាអាទិ៍នៅក្នុងក្របខ័ណ្ឌនៃដីកាចាត់ឱ្យស៊ើបសួរជំនួស** | កាលណាដីកាចាត់ឱ្យស៊ើបសួរជំនួសបានចែងអំពីការស្តាប់ និងការថតការសន្ទនាតាមទូរស័ព្ទ ឬការចាប់ និងការថតគ្រប់ការឆ្លើយឆ្លងតាមមធ្យោបាយទូរគមនាគមន៍ ដូចជា សារតាមទូរសារ ឬសារតាមអ៊ិនធើណែត មន្ត្រីនគរបាលយុត្តិធម៌ប្រើប្រាស់អំណាចដែលប្រគល់ឱ្យចៅក្រមស៊ើបសួរ ដោយវាក្យខណ្ឌ ទី ២ កថាខណ្ឌទី ១ និងកថាខណ្ឌទី ២ នៃមាត្រា ១៧២ (ការស្តាប់ទូរស័ព្ទ ជាអាទិ៍ ដែលបង្គាប់ដោយ ចៅក្រមស៊ើបសួរ) នៃក្រមនេះ ។ |
| មាត្រា ១៨៤<br>**កំណត់ហេតុកសាងដោយមន្ត្រីនគរបាលយុត្តិធម៌** | កំណត់ហេតុដែលធ្វើឡើងដោយមន្ត្រីនគរបាលយុត្តិធម៌ នៅក្នុងក្របខ័ណ្ឌនៃការអនុវត្តដីកាចាត់ ឱ្យស៊ើបសួរជំនួសត្រូវស្ថិតនៅក្រោមបទប្បញ្ញត្តិនៃមាត្រា ១០៨ (និទ្ទេសដែលត្រូវចុះនៅក្នុង កំណត់ហេតុ) នៃក្រមនេះ ។ |
| មាត្រា ១៨៨<br>**ការជូនដំណឹងអំពីដីកាបង្គាប់ឱ្យចូលខ្លួន** | ដីកាបង្គាប់ឱ្យចូលខ្លួន ត្រូវឱ្យដំណឹងដល់បុគ្គលដែលពាក់ព័ន្ធដោយមន្ត្រីនគរបាលយុត្តិធម៌ ឬភ្នាក់ងារនគរបាលយុត្តិធម៌ ឬដោយអាជ្ញាសាលា ។<br>បុគ្គលដែលពាក់ព័ន្ធទទួលចុងដីកា ហើយត្រូវចុះហត្ថលេខានៅលើដើមដីកា ដែលត្រូវបង្វិលជូនចៅក្រមស៊ើបសួរវិញ ។<br>មន្ត្រីនគរបាលយុត្តិធម៌ ភ្នាក់ងារនគរបាលយុត្តិធម៌ ឬអាជ្ញាសាលាត្រូវជូនដំណឹងដល់ចៅក្រមស៊ើបសួរអំពីគ្រប់ការលំបាកក្នុងការអនុវត្តបេសកកម្មរបស់ខ្លួន ។ |
| មាត្រា ១៩២<br>**ការអនុវត្តដីកាបង្គាប់ឱ្យនាំខ្លួន** | ការអនុវត្តដីកាបង្គាប់ឱ្យនាំខ្លួន ត្រូវប្រគល់ឱ្យមន្ត្រីនគរបាលយុត្តិធម៌ ។<br>ក្នុងករណីបន្ទាន់ ដីកាបង្គាប់ឱ្យនាំខ្លួនត្រូវផ្សព្វផ្សាយដល់អង្គភាពនគរបាល ឬកងរាជអាវុធហត្ថតាមគ្រប់មធ្យោបាយ ។ ដើមដីកានេះ ត្រូវប្រគល់ជូនជាបន្ទាន់ដល់មន្ត្រីនគរបាលយុត្តិធម៌ដែលទទួលបន្ទុកអនុវត្តដីកានោះ ។ មន្ត្រីនគរបាលយុត្តិធម៌មិនអាចចូលទៅក្នុងលំនៅឋានរបស់បុគ្គលដែលពាក់ព័ន្ធមុនម៉ោង ៧ (ប្រាំមួយ) ព្រឹក និងក្រោយម៉ោង ១៨ (ដប់ប្រាំបី) បានទេ ។ មន្ត្រីនគរបាលយុត្តិធម៌ ត្រូវជូនដំណឹងដល់ចៅក្រមស៊ើបសួរអំពីការលំបាកក្នុងកការអនុវត្តបេសកកម្មរបស់ខ្លួន ។ |
| មាត្រា ១៩៣ | ប្រសិនបើដោយមូលហេតុនៃកាលៈទេសៈបុគ្គលដែលពាក់ព័ន្ធមិនអាចត្រូវនាំទៅបង្ហាញខ្លួនដល់ចៅក្រមស៊ើបសួរក្រោយពេលចាប់ខ្លួនបានទេ បុគ្គលនេះត្រូវតែនាំខ្លួនទៅក្នុងអង្គភាពនគរបាល ឬកងរាជអាវុធហត្ថក្នុងមណ្ឌលឃុំខ្លួន ឬទៅ |

| | |
|---|---|
| **ការបង្ហាញខ្លួនតាមដីកាបង្គាប់ឱ្យនាំខ្លួន** | ក្នុងពន្ធនាគារ។ បុគ្គលនេះត្រូវតែនាំខ្លួនទៅបង្ហាញខ្លួនយ៉ាងយូរបំផុតថ្ងៃបន្ទាប់ ដល់ចៅក្រមស៊ើបសួរ ឬដល់អ្នកជំនួស ។ ប្រសិនបើការបង្ហាញខ្លួនមិនបានប្រព្រឹត្តទៅនៅថ្ងៃបន្ទាប់ទេ បុគ្គលពាក់ព័ន្ធត្រូវបានដោះលែងឱ្យ មានសេរីភាពវិញ ។ |
| មាត្រា ១៩៩<br>**ការអនុវត្តដីកាបង្គាប់ឱ្យចាប់ខ្លួន** | ការអនុវត្តដីកាបង្គាប់ឱ្យចាប់ខ្លួនត្រូវប្រគល់ឱ្យមន្ត្រីនគរបាលយុត្តិធម៌ ។<br>ក្នុងករណីបន្ទាន់ ដីកាបង្គាប់ឱ្យចាប់ខ្លួន ត្រូវផ្សព្វផ្សាយទៅតាមអង្គភាពនគរបាល ឬកងរាជអាវុធហត្ថតាមគ្រប់មធ្យោបាយ ។ ដើមដីកាត្រូវប្រគល់ក្នុងរយៈពេលយ៉ាងខ្លីបំផុតឱ្យដល់មន្ត្រីនគរបាលយុត្តិធម៌ ដែលទទួលបន្ទុក អនុវត្តដីកានោះ ។<br>នគរបាលយុត្តិធម៌ មិនអាចចូលទៅក្នុងលំនៅឋានរបស់បុគ្គលដែលពាក់ព័ន្ធមុនម៉ោង ៦ (ប្រាំមួយ) ព្រឹក និងក្រោយម៉ោង ១៨ (ដប់ប្រាំបី) បានទេ ។ មន្ត្រីនគរបាលយុត្តិធម៌ ត្រូវឱ្យដំណឹងដល់ចៅក្រមស៊ើបសួរអំពីការលំបាកទាំងអស់ក្នុងពេលអនុវត្តបេសកម្មរបស់ខ្លួន ។ |
| មាត្រា ២៣២<br>**របៀបកោះហៅ** | ជនត្រូវចោទនៅក្រៅឃុំ ដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សី ត្រូវបានកោះហៅតាមផ្លូវប្រៃសណីយ៍ តាមផ្លូវរដ្ឋបាល ឬតាមរយៈអង្គភាពនគរបាល ឬកងរាជអាវុធហត្ថ ។<br>ការកោះហៅជនត្រូវចោទ ត្រូវធ្វើទៅតាមអាសយដ្ឋានចុងក្រោយបង្អស់ ដែលបានប្រកាសដូចដែលចែងនៅមាត្រា ១៤៣ (ការជូនដំណឹងអំពីការដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ) នៃក្រមនេះ ។<br>ក្នុងករណីចាំបាច់ ការកោះហៅអាចធ្វើតាមគ្រប់មធ្យោបាយ ។ |
| មាត្រា ២៣៨<br>**ការជូនដំណឹងអំពីដីកាសម្រេចដល់ជនត្រូវចោទ** | ដីការបស់ចៅក្រមស៊ើបសួរដែលត្រូវជូនដំណឹងដល់ជនត្រូវចោទដែលត្រូវបានឃុំខ្លួនតាមរបៀបដូចតទៅ :<br>– ដោយផ្ទាល់មាត់<br>– តាមរយៈប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួន។<br>ដីការបស់ចៅក្រមស៊ើបសួរ ត្រូវជូនដំណឹងដល់ជនត្រូវចោទនៅក្រៅឃុំដល់ដើមបណ្តឹងរដ្ឋប្បវេណីនិងមេធាវីតាមរបៀបដូចទៅនេះ :<br>– ដោយផ្ទាល់មាត់<br>– តាមផ្លូវរដ្ឋបាល ឬ<br>– តាមរយៈអង្គភាពនគរបាល ឬកងរាជអាវុធហត្ថ ។ |





| | |
|---|---|
| | កាលណាការជូនដំណឹងត្រូវបានធ្វើឡើងដោយផ្ទាល់មាត់ នោះក្រឡាបញ្ជីចុះនិទ្ទេសអំពីការជូនដំណឹងនៅរឹមដីការ ។<br>ជនត្រូវចោទ ដើមបណ្តឹងរដ្ឋប្បវេណី ត្រូវចុះហត្ថលេខារបស់ខ្លួន ។<br>នៅក្នុងករណីដទៃទៀត ការជូនដំណឹងត្រូវធ្វើដោយការប្រគល់សេចក្តីចម្លងដីការ ដោយមានចំណាររបស់អ្នកទទួលថាបានទទួលទុកជាសម្គាល់ ។ |
| មាត្រា ២៣៩<br>**ការប្រគល់ដីកាកោះហៅ ឬដីកាផ្សេងៗទៀត** | គ្រប់មន្ត្រីរាជការ គ្រប់អាជ្ញាធររដ្ឋបាលគ្រប់នគរបាល ឬកងរាជអាវុធហត្ថដែលចៅក្រមស៊ើបសួរសុំឱ្យប្រគល់ដីកាកោះហៅ ឬដីកាផ្សេងទៀត ត្រូវតែអនុវត្តតាមបញ្ជារបស់ចៅក្រមនេះ ។<br>បុគ្គល អង្គភាព ឬអាជ្ញាធរដែលចៅក្រមស៊ើបសួរចាត់តាំងនោះ ត្រូវតែប្រគល់ដីកាកោះ ឬដីកាដល់សាមីខ្លួន ដោយមានចំណាររបស់អ្នកទទួលបញ្ជាក់ថា បានទទួល ទុកជាសំគាល់ ។ ដីកាដែលមានចំណារទទួលនេះ ត្រូវបង្វិលជូនទៅចៅក្របស៊ើបសួរក្នុងរយៈពេលយ៉ាងខ្លីបំផុត។ |
| មាត្រា ២៥៨<br>**ការជូនដំណឹងអំពីកាលបរិច្ឆេទនៃសវនាការ** | ប្រធានសភាស៊ើបសួរពិនិត្យផ្ទៀងផ្ទាត់មើលថា តើសំណុំរឿងមានលក្ខណៈគ្រប់គ្រាន់ល្មមជំនុំជម្រះបានឬទេ រួចហើយកំណត់កាលបរិច្ឆេទបើកសវនាការ។ ប្រធានសភាស៊ើបសួរជូនដំណឹងផ្ទាល់មាត់អំពីកាលបរិច្ឆេទនៃការបើកសវនាការ ដល់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ។ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ជូនដំណឹងអំពីកាលបរិច្ឆេទនៃសវនាការនេះដល់គូភាគី និងដល់មេធាវី។<br>ការជូនដំណឹងដល់ជនត្រូវចោទដែលត្រូវបានឃុំខ្លួនត្រូវធ្វើដូចតទៅនេះ<br>– ដោយផ្ទាល់មាត់ ឬ<br>– តាមរយៈប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួន។<br>ការជូនដំណឹងដល់ជនត្រូវចោទនៅក្រៅឃុំ ដល់ដើមបណ្តឹងរដ្ឋប្បវេណី និងដល់មេធាវីត្រូវធ្វើដូចតទៅ :<br>– ដោយផ្ទាល់មាត់<br>– តាមផ្លូលរដ្ឋបាល ឬ<br>– តាមរយៈអង្គភាពនគរបាល ឬកងរាជអាវុធហត្ថ។<br>កាលណាការជូនដំណឹងធ្វើដោយផ្ទាល់មាត់ក្រឡាបញ្ជីចុះនិទ្ទេសអំពីកាលបរិច្ឆេទនៃការជូនដំណឹងនៅរឹមទំព័រនៃដីកា ។ ជនត្រូវចោទ ដើមបណ្តឹងរដ្ឋប្បវេណី ឬមេធាវីចុះហត្ថលេខារបស់ខ្លួន ។ |

<table>
<tr><td></td><td>ក្នុងករណីដទៃទៀត ការជូនដំណឹងត្រូវធ្វើដោយការប្រគល់សេចក្តីចម្លងដីកាដោយមានចំណារទទួល ។</td></tr>
<tr><td colspan="2">គន្ថីទី ៥ ៖ អំពីសាលក្រម<br>មាតិកាទី ១ ៖ សាលក្រមសាលាដំបូង</td></tr>
<tr><td>មាត្រា ៣១០<br>ដីកាបង្គាប់ឱ្យនាំខ្លួនដែលសម្រេចដោយតុលាការ</td><td>នៅក្នុងរឿងមជ្ឈិម និងឧក្រិដ្ឋ ប្រសិនបើជនជាប់ចោទមិនចូលបង្ហាញខ្លួនទេ តុលាការអាចបង្គាប់ឱ្យបង្អង់រឿងនេះទុកសិន និងឱ្យចេញដីកាបង្គាប់ឱ្យនាំខ្លួន។ តុលាការត្រូវតែបញ្ជាក់អំពីកាលបរិច្ឆេទនៃការបើកសវនការថ្មី ។<br>ដីកាបង្គាប់ឱ្យនាំខ្លួនមានចុះនិទ្ទេសដូចតទៅ :<br>– អត្តសញ្ញាណជនជាប់ចោទ<br>– បទល្មើសដែលចោទប្រកាន់ និងអត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើសនេះ<br>– ឈ្មោះ និងឋានៈរបស់ចៅក្រមដែលចេញដីកា ។<br>ដីកាបង្គាប់ឱ្យនាំខ្លួនត្រូវមានចុះកាលបរិច្ឆេទនិងចុះហត្ថលេខាដោយប្រធានសវនការនិងមានបោះត្រាផង ។<br>បទប្បញ្ញត្តិមាត្រា ១៩២ (ការអនុវត្តដីកាបង្គាប់ឱ្យនាំខ្លួន) នៃក្រមនេះ ត្រូវយកមកអនុវត្ត ។<br>ជនជាប់ចោទត្រូវបាននាំខ្លួនទៅកាន់អង្គភាពនគរបាល កងរាជអាវុធហត្ថ មណ្ឌលឃុំខ្លួន ឬពន្ធនាគាររហូតដល់ពេលជនជាប់ចោទនេះចូលបង្ហាញខ្លួននៅមុខតុលាការ ។ ជនជាប់ចោទអាចសុំឱ្យ ព្រះរាជអាជ្ញាស្តាប់ចម្លើយរបស់ខ្លួន។ ព្រះរាជអាជ្ញាធ្វើកំណត់ហេតុស្តីពីការស្តាប់ចម្លើយនេះ ។</td></tr>
<tr><td>មាត្រា ៣២៦<br>ការស្តាប់ចម្លើយរបស់ភាគី</td><td>ប្រធានសវនាការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី ជនរងគ្រោះ សាក្សី និងអ្នកជំនាញតាមលំដាប់លំដោយដែលខ្លួនយល់ឃើញថាមានប្រយោជន៍។ ប្រធានសវនាការអាចស្តាប់នូវចម្លើយមន្ត្រី និងភ្នាក់ងារនគរបាលយុត្តិធម៌ ដែលបានចូលរួមក្នុងការស៊ើបអង្កេតក្នុងឋានៈជាសាក្សី ។<br>ព្រះរាជអជ្ញា មេធាវី និងភាគី អាចត្រូវបានអនុញ្ញាតឲ្យលើកសំណួរសួរ ។ គ្រប់ការលើកសំណួរទាំងអស់ត្រូវតែបានការអនុញ្ញាតពីប្រធានសវនាការ ។ ក្រៅពីសំនួររបស់តំណាងអយ្យាការ និងមេធាវី សំណួរផ្សេងទៀត ត្រូវសួរតាមរយៈប្រធានសវនាការ ។ ក្នុងករណីមានការតវ៉ា ប្រធានសវនាការសម្រេចដោយឥស្សរចិត្តថា តើសំណួរនេះត្រូវតែសួរឬទេ ។</td></tr>
<tr><td>មាត្រា ៣៣០</td><td>ក្នុងករណីចាំបាច់ ប្រធានអាចហៅរកអ្នកបកប្រែ ។</td></tr>
</table>





<table>
<tr><td>ជំនួយ និងសម្បថរបស់អ្នកបកប្រែ</td><td>អ្នកបកប្រែនេះត្រូវស្បថតាមសាសនា ឬជំនឿរបស់ខ្លួន ថាខ្លួននឹងជួយដល់តុលាការ និងបកប្រែចម្លើយឲ្យបានស្មោះត្រង់ ។ នៅក្នុងករណីណាក៏ដោយ អ្នកបកប្រែមិនអាចត្រូវបានជ្រើសរើសក្នុងចំណោមចៅក្រម ក្រឡាបញ្ជី នគរបាល កងរាជអាវុធហត្ថ គូភាគី ឬសាក្សីទេ ។<br>បទបញ្ញត្តិនៃមាត្រា ១៥៦(សាក្សីដែលអនុញ្ញាតឲ្យរួចពីសម្បថ)នៃក្រមនេះត្រូវយកមកអនុវត្តផងដែរ ។</td></tr>
<tr><td>មាត្រា ៣៦៦<br>ទម្រង់ និងភាពដែលអាចទទួលយកបាននៃបណ្តឹងទាស់</td><td>បណ្តឹងទាស់ត្រូវឡើងដោយពាក្យប្តឹងជាលាយលក្ខណ៍អក្សរ:<br>– នៅការិយាល័យក្រឡាបញ្ជីនៃតុលាការដែលបានប្រកាសសាលក្រម<br>– នៅចំពោះមុខព្រះរាជអាជ្ញា អង្គភាពនគរបាល ឬកងរាជអាវុធហត្ថ ឬនៅចំពោះមុខ ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួន។<br>ពិរុទ្ធជនអាចត្រូវបានតំណាងដោយមេធាវី។ មេធាវីត្រូវតែមានលិខិតអនុញ្ញាតឱ្យធ្វើបណ្តឹងទាស់។ ប៉ុន្តែ ពិរុទ្ធជនជាអនីតិជន អាចត្រូវតំណាងដោយឪពុកម្តាយ ឬអ្នកអាណាព្យាបាល។ ក្នុងករណីនេះ អ្នកតំណាងមិនចាំបាច់មានលិខិតប្រគល់សិទ្ធិទេ ។<br>កាលណាបានទទួលពាក្យប្តឹងទាស់ ព្រះរាជអាជ្ញា អង្គភាពនគរបាល និងកងរាជអាវុធហត្ថ ព្រមទាំងប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួន បញ្ជូនបណ្តឹងទាស់នោះភ្លាមទៅក្រឡាបញ្ជី នៃតុលាការដែលបានប្រកាសសាលក្រម។<br>កាលណាអ្នកប្តឹងទាស់មិនចេះចុះហត្ថលេខាទេ អ្នកប្តឹងទាស់នេះត្រូវផ្តិតម្រាមដៃ។</td></tr>
<tr><td colspan="2">គន្ថីទី ៥ ៖ អំពីសាលក្រម<br>មាតិកាទី ២ ៖ បណ្តឹងឧទ្ធរណ៍ចំពោះសាលក្រម</td></tr>
<tr><td>មាត្រា ៤១០<br>ទម្រង់នៃបណ្តឹងទាស់</td><td>បណ្តឹងទាស់អាចធ្វើតាមពាក្យប្តឹងលាយលក្ខណ៍អក្សរ<br>– នៅការិយាល័យក្រឡាបញ្ជីនៃសាលាឧទ្ធរណ៍ដែលបានសម្រេចចេញសាលដីកា ឬ<br>– នៅចំពោះមុខអគ្គព្រះរាជអាជ្ញា អង្គភាពនគរបាល ឬកងរាជអាវុធហត្ថ ឬប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួន ។<br>ពិរុទ្ធជនអាចត្រូវតំណាងដោយមេធាវី ។ មេធាវីត្រូវតែមានលិខិតអនុញ្ញាតឱ្យធ្វើបណ្តឹងទាស់ ។ ប៉ុន្តែពិរុទ្ធជនជាអនីតិជនអាចត្រូវតំណាងដោយឪពុក ម្តាយ ឬអ្នកអាណាព្យាបាល ។ ក្នុងករណីនេះ អ្នកតំណាងមិនចាំបាច់មានលិខិតប្រគល់សិទ្ធិទេ ។</td></tr>
</table>

| | |
|---|---|
| | កាលណាបានទទួលពាក្យប្តឹងទាស់ អគ្គព្រះរាជអាជ្ញា អង្គភាពនគរបាល និងកងរាជអាវុធហត្ថ ព្រមទាំងប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួន បញ្ជូនសំណុំរឿងនោះភ្លាមទៅសាលាឧទ្ធរណ៍ ដែលបានប្រកាសចេញសាលដីកា ។<br>កាលណាអ្នកប្តឹងទាស់មិនចេះចុះហត្ថលេខាទេ សាមីខ្លួនត្រូវផ្តិតម្រាមដៃ ។ |

**គន្ថីទី ៦ ៖ តុលាការកំពូល**
**មាតិកាទី ១ ៖ បណ្តឹងសាទុក្ខ**

| | |
|---|---|
| មាត្រា ៤៣៣<br>**ការជូនដំណឹងអំពីកាលបរិច្ឆេទនៃសវនការចំពោះភាគី** | ប្រធានសភាព្រហ្មទណ្ឌកំណត់កាលបរិច្ឆេទនៃសវនការ និងជូនដំណឹងដោយផ្ទាល់មាត់ដល់អគ្គព្រះរាជអាជ្ញាអំពីកាលបរិច្ឆេទនៃសវនកាលនេះ ។ អគ្គព្រះរាជអាជ្ញាឱ្យដំណឹងអំពីកាលបរិច្ឆេទនេះ ដល់ភាគី និងមេធាវី ។<br>ការឱ្យដំណឹងដល់ជនជាប់ចោទដែលជាប់ឃុំដល់ពិរុទ្ធជនដែលឃុំខ្លួន ឬដល់បុគ្គដែលគេទាមទារនៅក្នុងរឿងបត្យាប័ន ត្រូវធ្វើឡើងដូចរបៀបដូចតទៅ:<br>– ដោយផ្ទាល់មាត់ ឬ<br>– តាមរយៈអង្គភាពនគរបាល ឬកងរាជអាវុធហត្ថ ។<br>ការឱ្យដំណឹងដល់ពិរុទ្ធជន ឬជនជាប់ចោទនៅក្រៅឃុំ ដើមបណ្តឹងរដ្ឋប្បវេណី និងដល់មេធាវីត្រូវធ្វើដូចតទៅ<br>– ដោយផ្ទាល់មាត់<br>– តាមផ្លូវរដ្ឋបាល ឬ<br>– តាមរយៈអង្គភាពនគរបាល ឬកងរាជអាវុធហត្ថ ។<br>កាលណាឱ្យដំណឹងត្រូវធ្វើដោយផ្ទាល់មាត់ ក្រឡាបញ្ជីចុះនិទ្ទេសអំពីកាលបរិច្ឆេទនៃការឱ្យ ដំណឹងទៅលើសំណុំរឿង។ ពិរុទ្ធជន ជនជាប់ចោទដើមបណ្តឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី ឬមេធាវីចុះហត្ថលេខា របស់ខ្លួន ។<br>នៅក្នុងករណីដទៃទៀត ការឱ្យដំណឹងត្រូវធ្វើដោយមានបង្កាន់ដៃបញ្ជាក់ថាបានទទួលសម្រាប់ទុកជាសម្គាល់ ។ |

**គន្ថីទី ៧ ៖ ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ដីកាកោះហៅ និងដីកាជូនដំណឹង**
**មាតិកាទី ១ ៖ ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់**

| | |
|---|---|
| មាត្រា ៤៦៣<br>**របៀបផ្សេងទៀតនៃការប្រគល់ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់** | ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ក៏អាចត្រូវបានប្រគល់ដោយ :<br>– ក្រឡាបញ្ជី<br>– តាមផ្លូវរដ្ឋបាល |





| | |
|---|---|
| | – ដោយប្រធានពន្ធធនាគារ ឬមណ្ឌលឃុំខ្លួន ប្រសិនបើជនជាប់ចោទត្រូវឃុំខ្លួនពីបទល្មើសផ្សេងទៀត<br>– តាមរយៈអង្គភាពនគរបាលជាតិ ឬកងរាជអាវុធហត្ថ ។<br>ក្រឡាបញ្ជី អាជ្ញាធររដ្ឋបាល អាជ្ញាធរពន្ធធនាគារ មន្ត្រីនគរបាលជាតិ ឬអាវុធហត្ថដែលព្រះរាជអាជ្ញាសុំឲ្យប្រគល់ដីកាដោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ត្រូវតែគោរពតាមបញ្ជារបស់ព្រះរាជអាជ្ញា ។<br>ត្រូវបំពេញកិច្ចនេះដូចមានចែងក្នុងមាត្រា ៤៦០ (ការប្រគល់ចុងដីកាកោះហៅដោយអាជ្ញាសាលាដល់ជនជាប់ចោទ) ដល់មាត្រា ៤៦២ (ការប្រគល់ចុងដីកាកោះហៅដោយអាជ្ញាសាលាដល់មេឃុំ ឬចៅសង្កាត់)នៃក្រមនេះ ។ |

**គន្ថីទី ៧ ៖ ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ដីកាកោះហៅ និងដីកាជូនដំណឹង**
**មាតិកាទី ២ ៖ ដីកាកោះហៅជនជាប់ចោទឱ្យចូលសវនាការ**

| | |
|---|---|
| មាត្រា ៤៧២<br>**របៀបផ្សេងទៀតនៃការប្រគល់ដីកាកោះហៅ** | ដីកាកោះក៏អាចត្រូវប្រគល់ឱ្យ<br>– ដោយក្រឡាបញ្ជី<br>– តាមផ្លូវរដ្ឋបាល<br>– ដោយប្រធានពន្ធនាគា ឬមណ្ឌលឃុំខ្លួន ប្រសិនបើជនជាប់ចោទត្រូវឃុំខ្លួនពីបទរឿងមួយផ្សេងទៀត<br>– តាមរយៈអង្គភាពនគរបាល ឬកងរាជអាវុធហត្ថ ។<br>ក្រឡាបញ្ជី អាជ្ញាធររដ្ឋបាល អាជ្ញាធរពន្ធធនាគារ មន្ត្រីនគរបាលជាតិ ឬអាវុធហត្ថដែលព្រះរាជអជ្ញាសុំឱ្យប្រគល់ដីកាកោះ ត្រូវតែគោរពតាមបញ្ជារព្រះរាជអាជ្ញា ។<br>កិច្ចនេះត្រូវធ្វើដូចដែលមានចែងនៅក្នុងមាត្រា៤៦៩(ការប្រគល់ចុងដីកាកោះដោយអាជ្ញាសាលាដល់ជនជាប់ចោទ) ដល់មាត្រា ៤៧១(ការប្រគល់ចុងដីកាកោះហៅដោយអាជ្ញាសាលាដល់មេឃុំ ឬចៅសង្កាត់) នៃក្រមនេះ ។ |

**គន្ថីទី ៧ ៖ ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ដីកាកោះហៅ និងដីកាជូនដំណឹង**
**មាតិកាទី ៤ ៖ ដីកាឱ្យដំណឹងអំពីសេចក្តីសម្រេចរបស់តុលាការ**

| | |
|---|---|
| មាត្រា ៤៨៩<br>**របៀបផ្សេងទៀតនៃការជូនដំណឹង** | ការជូនដំណឹងក៏អាចប្រគល់ឱ្យផងដែរ :<br>– ដោយក្រឡាបញ្ជី<br>– តាមផ្លូវរដ្ឋបាល<br>– ដោយប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួន ប្រសិនបើជនជាប់ចោទត្រូវឃុំខ្លួនពីបទដទៃផ្សេងទៀត |

| | |
|---|---|
| | – តាមរយៈអង្គភាពនគរបាល ឬកងរាជអាវុធហត្ថ ។<br>ក្រឡាបញ្ជី អាជ្ញាធរពន្ធធនាគារ មន្ត្រីនគរបាលជាតិ ឬអាវុជហត្ថដែលព្រះហ្មាជអាជ្ញាសុំឱ្យជូនដំណឹងពីសេចក្តីសម្រេចរបស់តុលាការ ត្រូវតែគោរពតាមបញ្ជារបស់ព្រះរាជអាជ្ញា ។<br>កិច្ចនេះត្រូវធ្វើដូចមានចែងនៅមាត្រា ៤៨៦ ( ការប្រគល់លិខិតចម្លងនៃសេចក្តីសម្រេចជូនដល់ភាគីដែលពាក់ព័ន្ធដោយអាជ្ញាសាលា) ដល់មាត្រា ៤៨៨ ( ការប្រគល់លិខិតចម្លងនៃសេចក្តីសម្រេចដល់ មេឃុំ ឬចៅសង្កាត់) នៃក្រមនេះ ។ |

**គន្ថីទី ៧ ៖ ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ដីកាកោះហៅ និងដីកាជូនដំណឹង**

**មាតិកាទី ៥ ៖ បទប្បញ្ញត្តិរួម**

| | |
|---|---|
| មាត្រា៤៩៣<br>**និទ្ទេសដែលត្រូវកត់ត្រានៅលើដីកាកោះបញ្ជូនទៅជំនុំជម្រះផ្ទាល់ ឬដីកាកោះហៅ** | កាលណាដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ឬដីកាកោះហៅឱ្យចូលខ្លួនត្រូវបានប្រគល់ដោយអាជ្ញាសាលា ដោយក្រឡាបញ្ជី តាមផ្លូវរដ្ឋបាល ដោយប្រធានពន្ធនាគារ ឬ មណ្ឌលឃុំខ្លួន ឬតាមរយៈអង្គភាពនគរបាល ឬកងរាជអាវុធហត្ថ ដីកាកោះនោះត្រូវមានចុះនិទ្ទេសដូចតទៅ :<br>– អត្តសញ្ញាណ និងឋានៈរបស់អ្នកប្រគល់ដីកា<br>– ហត្ថលេខារបស់អ្នកប្រគល់ដីកា។ |

**គន្ថីទី ៨ ៖ នីតិវិធីប្រតិបត្តិ**

**មាតិកាទី ២ ៖ ការប្រតិបត្តិឃុំខ្លួនបណ្តោះអាសន្ន និងទោសដកហូតសេរីភាព**

| | |
|---|---|
| មាត្រា ៥០៥<br>**បញ្ជីជនជាប់ឃុំ** | គ្រប់ព័ន្ធធនាគារ និងមណ្ឌលឃុំខ្លួនទាំងអស់ត្រូវមានបញ្ជីមួយដែលចុះនិទ្ទេសអំពីអត្តសញ្ញាណ ឃុំខ្លួនកាលបរិច្ឆេទ និងកាលបរិច្ឆេទដោះលែង ។ បញ្ជីនេះត្រូវបានត្រួតពិនិត្យជារៀយៗដោយអយ្យការ ។ ទំព័រនីមួយៗត្រូវតែចុះទិដ្ឋាការដោយអយ្យាការ ។<br>គ្រប់ភ្នាក់ងារនៃរដ្ឋបាលពន្ធនាគារនិងមណ្ឌលឃុំខ្លួនត្រូវតែជូនបញ្ជីទៅចៅក្រមពិនិត្យមើលតាមការស្នើសុំព្រមទាំងបង្ហាញដល់មន្ត្រីនគរបាលយុត្តិធិមដែលបំពេញភារកិច្ចតាមការប្រគល់អំណាចពីអាជ្ញាធរតុលាការ ។ |
| មាត្រា ៥០៨<br>**ការបង្ហាញខ្លួនជនជាប់ឃុំតាមការស្នើសុំ** | គ្រប់ភ្នាក់ងាររដ្ឋបាលពន្ធនាគារ ត្រូវតែបង្ហាញខ្លួនជនជាប់ឃុំដល់ចៅក្រមតាមការស្នើសុំព្រមទាំងដល់មន្ត្រីនគរបាលយុត្តិធម៌ដែលបំពេញភារកិច្ចតាមការប្រគល់អំណាចពីអាជ្ញាធរតុលាការ ។ |





**គន្ថីទី ៨ ៖ នីតិវិធីប្រតិបត្តិ**

**មាតិកាទី ៣ ៖ ការបង្ខំដល់រូបកាយ**

| | |
|---|---|
| មាត្រា ៥២៥<br>**ការបង្ខំដល់រូបកាយក្នុងករណីមិនបង់ប្រាក់ពិន័យ ឬប្រាក់ពន្ធនៃនីតិវិធី** | ប្រសិនបើទណ្ឌិតមិនបង់ប្រាក់ពិន័យ ឬប្រាក់ពន្ធនៃនីតិវិធីទេ អង្គភាពរតនាគារជូនដំណឹងដល់ព្រះរាជអាជ្ញានៃតុលាការអមសាលាដំបូង ។<br>ព្រះរាជអាជ្ញាកំណត់រយៈពេលចុងក្រោយដល់ទណ្ឌិតដើម្បីបង់ប្រាក់នោះ ហើយឱ្យដំណឹងថាប្រសិនបើមិនចង់ទេនោះ សាមីខ្លួនអាចត្រូវបង្ខំដល់រូបកាយ ។ រយៈពេលនេះមិនអាចតិចជាង ១០ (ដប់) ថ្ងៃ ទេ ។<br>ការឱ្យដំណឹងត្រូវធ្វើ :<br>– ដោយផ្ទាល់មាត់ ឬ<br>– តាមផ្លូវរដ្ឋបាល ឬ<br>– តាមរយៈអង្គភាពនគរបាល ឬកងរាជអាវុធហត្ថ ។<br>ត្រូវតែមានធ្វើកំណត់ហេតុស្តីពីការឱ្យដំណឹងនេះ។ កំណត់ហេតុនេះត្រូវចុះហត្ថលេខាដោយទណ្ឌិត ។ ប្រសិនបើទណ្ឌិតមិនចេះចុះហត្ថលេខាទេ ទណ្ឌិតត្រូវផ្តិតមេដៃ ។ |

**គន្ថីទី ៩ ៖ នីតិវិធីដោយឡែក**

**មាតិកាទី ២ ៖ ការបាត់បង់លិខិតស្នាម ការបកស្រាយ និងការកែសម្រួលសេចក្តីសម្រេច**

| | |
|---|---|
| មាត្រា ៦០៥<br>**ការបង្កឡើងវិញនូវលិខិតនៃនីតិវិធី** | លិខិតនៃនីតិវិធីត្រូវបង្កឡើងវិញតាមលិខិតចម្លង ដែលរក្សាទុកដោយអង្គភាពនគរបាល ឬ កងរាជអាវុធហត្ថ ភាគីអ្នកជំនាញ ក្រឡាបញ្ជី ឬបុគ្គលផ្សេងទៀត ។ |

**គន្ថីទី ១០ ៖ អន្តរប្បញ្ញត្តិ**

| | |
|---|---|
| មាត្រា ៦០៧<br>**លក្ខខណ្ឌនៃការផ្តល់គុណសម្បត្តិជាមន្ត្រីនគរបាលយុត្តិធម៌ចំពោះនាយនគរបាលជាតិ និងនាយទាហាននៃកងរាជអាវុធហត្ថ** | នាយនគរបាលជាតិ ដែលមានវិញ្ញាបនប័ត្របញ្ជាក់ការសិក្សាស្តីពីមន្ត្រីនគរបាលយុត្តិធម៌ មុនពេលក្រមនេះចូលជាធរមាន ត្រូវទទួលបានដោយស្វ័យប្រវត្តិនូវសញ្ញាប័ត្រជាន់ខ្ពស់ខាងនគរបាលយុត្តិធម៌ ហើយត្រូវតែងតាំងជាមន្ត្រីនគរបាលយុត្តិធម៌ដោយប្រកាសរួមរបស់ក្រសួងមហាផ្ទៃ និង ក្រសួងយុត្តិធម៌ ។ |

| | |
|---|---|
| | នាយទាហាននៃកងរាជអាវុធហត្ថដែលមានវិញ្ញាបនប័ត្រនៃមន្ត្រីប៉ូលីសតុលាការមុនក្រមនេះចូលជាធរមានត្រូវទទួលបានដោយស្វ័យប្រវត្តិ នូវសញ្ញាប័ត្រជាន់ខ្ពស់ខាងនគរបាលយុត្តិធម៌ហើយត្រូវ តែងតាំងជាមន្ត្រីនគរបាលយុត្តិធម៌ ហើយត្រូវតែងតាំងជាមន្ត្រីនគរបាលយុត្តិធម៌ ដោយប្រកាសរួមរបស់ក្រសួងការពារជាតិ និងក្រសួងយុត្តិធម៌ ។<br>បន្ទាប់ពីក្រមនេះចូលជាធរមាន ដើម្បីទទួលបាននូវគុណសម្បត្តិជាមន្ត្រីនគរបាលយុត្តិធម៌ត្រូវបំពេញលក្ខខណ្ឌដែលមានចែងនៅក្នុងមាត្រា ៦០ (មន្ត្រីនគរបាលយុត្តិធម៌) នៃក្រមនេះ ។ |

❖ **រៀបរៀង និងដកស្រង់ចេញពី ក្រមនីតិវិធីព្រហ្មទណ្ឌលេខ នស/រកម/០៧០៨/០២៤ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០៧**